# ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

## អាជ្ញាធរប្រកាសអនុវត្តវិធានចត្តាឡីស័កចំពោះពលរដ្ឋចំណាកស្រុកពីក្រៅប្រទេសវិល ត្រឡប់ចូលរួមពិធីបុណ្យភ្ជុំបិណ្ឌ

http://btv.com.kh/ 31/08/2020

ភ្នំពេញ ៖ សម្រាប់បងប្អូនប្រជាពលរដ្ឋ ដែលធ្វើការងារចំណាកស្រុកមកពីថៃ និងបណ្ដាប្រទេសផ្សេងៗទៀត ដែលនឹងមកលេងស្រុកកំណើត និងបងប្អូនសាច់ញាតិ នៅក្នុងអំឡុងថ្ងៃបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ ដែលនឹងឈានចូលមកដល់នៅថ្ងៃទី៣ ខែកញ្ញានេះ នឹងត្រូវបានអាជ្ញាធរភូមិ ឃុំ សង្កាត់ ត្រូវអោយពួកគាត់ធ្វើចត្តាឡីស័ក ដាក់អោយស្នាក់នៅដាច់ដោយឡែកនៅតាមផ្ទះ ដោយមានតាមដានពិនិត្យសុខភាព វាស់កំដៅ យកចិត្តទុកដាក់ដើម្បីបញ្ជាក់ថា បងប្អូនចំណាកស្រុកគ្មានផ្ទុកមេរោគCOVID-19។

បើតាមលោក ឆេង ឆៃ ចៅសង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល បានថ្លែងប្រាប់BTV នៅថ្ងៃទី៣១ ខែសីហានេះ ថា នៅក្នុងអំឡុងពេលនេះ អាជ្ញាធរសង្កាត់ បាននិងកំពុងបន្តកិច្ចសហការជាមួយបណ្ដាវត្តអារ៉ាម និង បង្កើនការពិនិត្យតាមដានសុខភាព វាស់កំដៅ ដាក់ម៉ាស់អាកុលដែល កន្លែងលាងដៃទឹកសាប៊ូ ជូនចំពោះបងប្អូនពលរដ្ឋទៅវត្តធ្វើបុណ្យទាន នៅក្នុងឱកាសថ្ងៃបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ឈានចូលមក។ លោក បន្តថា បច្ចុប្បន្នមូលដ្ឋានលោក បាននិងកំពុងបង្កើនការគ្រប់គ្រងលំហូរប្រជាពលរដ្ឋចេញចូលមកពីចម្ងាយច្បាស់លាស់ ហើយលោក ក៏បានអំពាវនាវអោយបងប្អូនពលរដ្ឋក្នុងមូលដ្ឋាន បន្តសហការរាយការណ៍មកអាជ្ញាធរ ចំពោះអ្នកចំណាកស្រុក អ្នកចំលែក មកឆ្ងាយ តម្រូវអោយគេទៅធ្វើចត្តាឡីស័ក ពិនិត្យសុខភាពត្រឹមត្រូវ ដើម្បីរួមគ្នាទប់ស្កាត់ COVID-19 ចម្លងចូលក្នុងសហគមន៍និងក្នុងមូលដ្ឋានរបស់គេ។

មិនខុសគ្នានោះទេ បើតាមលោក ឈិន ធន សមាជិកឃុំក្រវ៉ាំ ស្រុកបារាយណ៍ ក៏ដូចបណ្ដាអាជ្ញាធរភូមិឃុំក្នុងស្រុកតាំងគោក ខេត្តកំពង់ធំឯនោះវិញថា នៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌជិតចូលមកដល់នេះ អាជ្ញាធរគ្រប់ផ្នែកនៅក្នុងមូលដ្ឋាន បាននិងកំពុងដាក់ការតាមដានចំពោះបងប្អូនពលរដ្ឋធ្វើការងារចំណាកស្រុកមកពីប្រទេសថៃ ហើយថា នៅពេលគេមកដល់ស្រុកកំណើតពេលណា អាជ្ញាធរនឹងតម្រូវអោយគេធ្វើចត្តាឡីស័កនៅក្នុងផ្ទះ ហើយពេលគេមានអាការៈមិនប្រក្រតី អាជ្ញាធរនឹងរាយការណ៍ក្រសួងសុខាភិបាល ដើម្បីផ្ដល់ការព្យាបាលទាន់ពេលវេលា។

សូមបញ្ជាក់ថា វិធានចត្តាឡីស័កចំពោះអ្នកចំណាកស្រុករបស់អាជ្ញាធរមូលដ្ឋានគឺជាតម្រូវការរបស់ក្រសួងសុខាភិបាល ហើយក្រសួងក៏កំពុងបានអំពាវនាវអោយអាជ្ញាធរមូលដ្ឋានបន្តអនុវត្តវិធានការនេះ ដើម្បីសហការធ្វើអោយសហគមន៍យើងគ្មានការចម្លងមេរោគCOVID-19នេះ៕

## កម្ពុជាមិនខ្វល់នឹងរបាយការណ៍របស់អាមេរិកដែលដាក់ឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ ទាក់ទងនឹងការជួញដូរមនុស្ស

http://btv.com.kh/ 31/08/2020

ភ្នំពេញ ៖ អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិ ឧត្តមសេនីយ៍ឯក ឆាយ គឹមឃឿន បានថ្លែងថា កម្ពុជាមិនបានខ្វល់នឹងរបាយការណ៍របស់អាមេរិក ដែលដាក់ឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ទាក់ទង នឹងការជួញដូរមនុស្ស អ្វីដែលសំខាន់គឺកម្ពុជាខ្លួនឯង ខិតខំធ្វើយ៉ាងណាទប់ស្កាត់ និងជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរនេះ ឲ្យកាន់តែមានប្រសិទ្ធភាពបំផុត។ ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពី កិច្ចប្រជុំស្ដីពីការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០នេះ ក្រោមអធិបតីភាពនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នៅទីស្ដីការក្រសួងមហាផ្ទៃ ឯកឧត្តម ឧត្ត

មសេនីយ៍ឯក ឆាយ គឹមឃឿន បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការទប់ ស្កាត់ និងជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរ ហើយនៅក្នុងកិច្ចប្រជុំខាងលើនេះឯកឧត្តម អគ្គស្នងការនគរបាលជាតិ ក៏បានជំរុញដល់ស្នងការរាជធានីខេត្តទាំងអស់ ត្រូវបង្កើនសកម្មភាពទប់ស្កាត់ និងជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរនេះឲ្យកាន់ខ្លាំងក្លាបន្ថែមទៀតផងដែរ។

យោងតាមរបាយការណ៍អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៧៨ករណី លើ ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។ របាយការណ៍ បានបញ្ជាក់បន្ថែមថា ក្នុងឆមាសទី១នេះ អាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៩៧នាក់ លើ ៨៥នាក់ (កើន១២នាក់ ស្មើនឹង១៤%) ក្នុងនោះស្រី ២២នាក់ អនីតិជន ៩នាក់ ជាជនបរទេស ១៤នាក់ សញ្ជាតិចិន ១២នាក់ និងអាមេរិក ២នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ២៦៣នាក់ (លើ១០៦នាក់) កើន ១៥៧នាក់ ស្មើនឹង ១៤៨% ក្នុងនោះមាន អាយុក្រោម ១៥ឆ្នាំ ៧០នាក់ អាយុ១៥–១៧ឆ្នាំ ៣១នាក់ និងពី ១៨ឆ្នាំឡើង ១៦២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ៧២នាក់ និងប្រគល់ទៅគ្រួសារ១ ៩១នាក់)។

ប្រទេសកម្ពុជា ត្រូវបានសហរដ្ឋអាមេរិកចេញរបាយការណ៍វាយតម្លៃឲ្យខ្លួនជាប់ចំណាត់ថ្នាក់លេខ២ អស់រយៈពេលបីឆ្នាំជាប់ៗគ្នា ទាក់ទងនិងអំពើជួញដូរមនុស្ស ដោយសហរដ្ឋអាមេរិក លើកឡើងថា មកពីកម្ពុជាមានភាពចន្លោះប្រហោងក្នុងការទប់ស្កាត់ និងបង្ក្រាបជាដើមនោះ។ យ៉ាងណាក៏ដោយរាជរដ្ឋាភិបាលកម្ពុជា លើកឡើងថា របាយការណ៍របស់អាមេរិកនេះ ធ្វើឡើងមានលក្ខណៈលំអៀង ហើយពុំដែល បានសួរដល់ប្រទេសកម្ពុជា មុននឹងចេញរបាយការណ៍នេះទេ ខណៈរាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការបង្ក្រាប និងទប់ស្កាត់ការជួញដូរមនុស្សបានយ៉ាងច្រើនជាបន្តបន្ទាប់នោះ៕ អត្ថបទ ៖ បាន ចក់

## បង្ក្រាបខារ៉ាអូខេបង្កប់សេវាកម្មផ្លូវភេទ និងរំដោះនារីរងគ្រោះរកស៊ីបាន៣នាក់

http://kampucheathmey.com/ 31/8/2020 12:32 Pm

**កំពង់ស្ពឺ ៖** កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បានចុះបង្ក្រាបទីតាំងខារ៉ាអូខេបង្កប់សេវាកម្មផ្លូវភេទមួយកន្លែង និងបានរំដោះនារីរកស៊ីផ្លូវភេទ ដែលជាជនរងគ្រោះចំនួន៣នាក់។ ហេតុការណ៍ចុះបង្ក្រាបទីតាំងខារ៉ាអូខេនេះ កាលពីរសៀលថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ការចុះបង្ក្រាបនេះផងដែរ ចូលរួមដោយលោកស្រី វរសេនីយ៍ទោ មួន មល្លិកា នាយការិយាល័យ បានទីតាំងខារ៉ាអូខេមួយកន្លែង យីហោ រាត្រីប្រជុំមិត្ត ដែលមានថៅកែឈ្មោះ សន ស៊ីម ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅភូមិ ស្វាយទាប ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីរសៀល ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០។ តាមការបញ្ជាក់ពីលោកស្រី នាយការិយាល័យថា ទីតាំង ខារ៉ាអូខេ ខាងលើ គឺបានប្រព្រឹត្តផ្ទុយទៅនឹងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ដែលបានហាមប្រាមមិនឲ្យគ្រប់ទីតាំងខារ៉ាអូខេ បម្រើសេវាជាលក្ខណៈបើកច្រៀងក្នុងបន្ទប់ ដោយត្រូវ ប្រែក្លាយមកជាការបើកលក្ខណៈ ភោជនីយដ្ឋានធម្មតា លើសពីនោះ អ្នកជំនាញបានស្រាវជ្រាវរកឃើញថា ទីតាំងនោះមានលួចបើកផ្តល់ឲ្យ មានសេវាផ្លូវភេទ (សញ្ចរកម្ម )។

ដោយបានគោលការណ៍ដ៏ខ្ពង់ខ្ពស់ ពីលោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការនគរបាលខេត្តជំនាញបានបញ្ជូនខ្លួនថៅកែខារ៉ាអូខេរួមជាមួយវត្ថុតាង ៖ ១. ស្រោមអនាម័យ១ថង់ (ប្រើរួច), ២. ផ្ទាំងរូបអាសអាភាស

ចំនួន២ផ្ទាំង យកមករក្សាទុកនៅស្នងការដ្ឋាននគរបាលខេត្តចំណាត់ការតាមនីតិវិធីច្បាប់។ ក្នុងប្រតិបត្តិការនោះដែរ សមត្ថកិច្ចក៏បានរំដោះនារីរងគ្រោះចំនួន៣នាក់ ប្រគល់ឲ្យមជ្ឈមណ្ឌលស្តារនីតិសម្បទា ជួយផ្នែកស្ត្រីងាយរងគ្រោះ ដើម្បីជួយផ្នែកស្មារតី និងផ្តល់ចំណេះជំនាញ ទៅរកមុខរបរថ្មី៕

## រដ្ឋាភិបាលថៃ អនុញ្ញាតឲ្យពលករបរទេស៣សញ្ជាតិស្នាក់នៅប្រទេសថៃអាចបន្តធ្វើការបាន រហូតដល់ឆ្នាំ២០២២

---

http://kampucheathmey.com/ 31/8/2020 6:43 Pm

ភ្នំពេញ ៖ រដ្ឋាភិបាលថៃបានអនុញ្ញាតិឲ្យពលករបរទេស៣សញ្ជាតិរួមមានកម្ពុជា,ឡាវនិងមីយ៉ាន់ម៉ាចំនួន៤ក្រុម ដែលកំពុងស្នាក់នៅប្រទេសថៃអាចបន្តធ្វើការបានរហូតដល់ឆ្នាំ២០២២ខាងមុខ។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានមានប្រសាសន៍នៅថ្ងៃទី៣១ សីហានេះថា ពលករបរទេស ៤ក្រុមនោះគឺទី១ ពលករបរទេសដែលចូលមកធ្វើការស្របតាមកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់តែផុតកំណត់៤ឆ្នាំ។ ទី២ពលករដែលបានបង្ហាញអត្តសញ្ញាណរបស់ពួកគេដូចជាលិខិតឆ្លងដែនឯកសារធ្វើដំណើរ ប័ណ្ណសម្គាល់ខ្លួនដែលបានការងារនិងការអនុញ្ញាតឲ្យស្នាក់នៅក្នុងព្រះរាជាណាចក្រថៃបានផុតកំណត់ថ្ងៃទី ៣០ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។ ប៉ុន្តែមិនបានដំណើរការទេតាមគណៈរដ្ឋមន្ត្រីថ្ងៃទី២០ ខែសីហាឆ្នាំ២០១៩។ ទី៣ពលករបរទេសដែលចូលមកធ្វើការស្របតាមកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់ដែលបានការងារត្រូវបានរៀបចំដោយគោលការណ៍ច្បាប់តាមមាត្រា ៥០, ៥៣, ៥៥ នៃក្រឹត្យបន្ទាន់ស្តីពីការគ្រប់គ្រងការងារសម្រាប់ជនបរទេសដូចជាការចាកចេញពីនិយោជកចាស់ប៉ុន្តែនៅតែមិនអាចរកនិយោជកថ្មីក្នុងរយៈពេល ៣០ថ្ងៃ។ លោកបានបន្តទៀតថា ពលករបរទេសទាំង៣ ក្រុមខាងលើអាចស្នើសុំការងារនៅនាយកដ្ឋានការងារចាប់ពីថ្ងៃទី១៧ ខែសីហាដល់ ថ្ងៃទី៣១ ខែតុលា ២០២០។ ពិនិត្យសុខភាពធានាសុខភាពចាប់ពីថ្ងៃទី៣១មករា ឆ្នាំ២០២១ ពលករផុតវីសាអនុញ្ញាតឲ្យនៅប្រទេសថៃកំឡុងថ្ងៃទី៣១ ខែមករាឆ្នាំ២០២១។ ធ្វើប័ណ្ណសំគាល់ខ្លួនចាប់ពីថ្ងៃទី ១ ខែកុម្ភៈដល់ថ្ងៃទី៣១ខែមីនាឆ្នាំ២០២១។ ចំពោះប័ណ្ណការងារអនុញ្ញាតឲ្យធ្វើការបានដល់ថ្ងៃទី៣១ មីនា ឆ្នាំ២០២២និងអាចបន្តធ្វើការជាមួយនិយោជកនៅការងារគ្រប់ប្រភេទប៉ុន្តែ ពលករបរទេសមិនអាចប្តូរនិយោជកបានទេលុះត្រាតែការចាកចេញពីការងារវាគឺជាកំហុសរបស់និយោជកនិងបានបង់ប្រាក់ឱ្យនិយោជកជាប្រចាំខែ។

លោកបានបន្ថែមទៀតថា ទី៤ចំណែកពលករសញ្ជាតិខ្មែរនិងមីយ៉ាន់ម៉ាចូលមកធ្វើការដោយប្រើ border past យោងតាមកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនដែលចូលមកធ្វើការក្នុងករណីទៅហើយមក ឬ តាមរដូវកាលតាមមាត្រា៦៤ នៃក្រឹត្យបន្ទាន់ស្តីពីការគ្រប់គ្រងការងារសម្រាប់ជនបរទេសដែលគ្រប់៤ ឆ្នាំនៃការងារនិងការអនុញ្ញាតឲ្យស្នាក់នៅក្នុងតំបន់ព្រំដែនដែលបានអនុញ្ញាតត្រូវដាក់ពាក្យសុំប័ណ្ណការងារនៅនាយកដ្ឋានការងារចាប់ពីថ្ងៃទី ១៧ខែសីហាដល់ថ្ងៃទី៣១ខែតុលា ២០២០និងពិនិត្យសុខភាពធានាសុខភាពបានការងារមានសុពលភាពរយៈពេល ៣ខែតែអាចសុំតបានមិនលើសពីថ្ងៃទី៣១ខែសីហា ២០២២និងអាចធ្វើការជាមួយនិយោជកបានចំនួន២ការងារគឺកម្មករសំណង់និងការងារផ្ទះព្រមទាំងធ្វើបានក្នុងតំបន់ដោយយោងតាមកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនរវាងកម្ពុជាថៃ និងមីយ៉ាន់ម៉ា និងក្នុងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចពិសេសប៉ុណ្ណោះ។ ពលករបរទេសមិនអាចប្តូរនិយោជកបានទេ លុះត្រាតែការចាកចេញពីការងារវាគឺជាកំហុសរបស់និយោជក និងបានបង់ប្រាក់ឲ្យនិយោជកជាប្រចាំខែ៕ សំអឿន

## ពលករខ្មែរឆ្លងដែនទៅកាប់ឈើគ្រញូងនៅថៃហើយទើបរួចផុតទោសចំនួន៦នាក់ ត្រូវអាជ្ញាធរថៃប្រគល់ឲ្យភាគីកម្ពុជាវិញ

http://nokorwatnews.com/ 31-09-2020

ខេត្តឧត្តរមានជ័យ៖ ពលករខ្មែរចំនួន៦នាក់ដែលបាន លបលួចឆ្លងដែនដោយខុសច្បាប់ ចូលទៅក្នុងទឹកដីថៃក្នុងបំណងកាប់ឈើគ្រញូង ត្រូវបានសមត្ថកិច្ចថៃចាប់យកទៅផ្តន្ទាទោសតាមច្បាប់នៅប្រទេសថៃហើយជាប់ពន្ធនាគារ ជាងបីឆ្នាំ ទើបរួចផុតទោសត្រូវបានអាជ្ញាធរថៃ ប្រគល់មកភាគីកម្ពុជាវិញ នៅវេលាម៉ោង៣និង១២នាទីរសៀល ថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០២០ តាមច្រកទ្វាអន្តរជាតិជាំ ស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា អាជ្ញាធរថៃបានបញ្ជូនជាពលរដ្ឋខ្មែរចំនួន ៦នាក់មកប្រគល់ឲ្យភាគីកម្ពុជាតាមច្រកអន្តរជាតិជាំមានឈ្មោះដូចខាងក្រោម ៖

ទី១៖ ឈ្មោះ វេង ស្រន់ ភេទប្រុស ៣៧ឆ្នាំរស់នៅភូមិសង្កែរូង ឃុំរហ័ស ស្រុករៀង ខេត្តព្រះវិហារ។

ទី២៖ឈ្មោះ ញៀន គុណ ភេទប្រុស ៥៥ឆ្នាំ

ទី៣៖ឈ្មោះ សៀវ សាន់ ភេទប្រុស ៣៨ឆ្នាំ

ទី៤៖ឈ្មោះ ប៉េង ធូ ភេទប្រុស ៣០ឆ្នាំ

ទី៥៖ឈ្មោះ ធុម ផន ភេទប្រុស ៤១ឆ្នាំ

ទី៦៖ឈ្មោះ ឌុម ឃីម ភេទប្រុស ៣៧ឆ្នាំអ្នកទាំង ៥រស់នៅភូមិមានជ័យ ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

អ្នកទាំង ៦ នេះត្រូវអាជ្ញាធរថៃចាប់ខ្លួននៅថ្ងៃទី ០៣មករា ឆ្នាំ ២០១៧ ពីបទឆ្លងដែនកាប់ឈើគ្រញូងតាមច្រកម៉ាឡៃហើយអ្នកទាំងនេះត្រូវអាជ្ញាធរថៃចាប់កាត់ទោសឲ្យជាប់ពន្ធនាគារនៅខេត្តសុខនបូរីប្រទេសថៃ។ ក្រោយពេលទទួលពលករ៦នាក់នេះពីភាគីថៃ សមត្ថកិច្ចប្រចាំច្រកទ្វារអន្តរជាតិជាំបានធ្វើការអប់រំរួចក៏បានអនុញ្ញាតឲ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញអស់ហើយដែរ៕

## ស្ថានទូតអំពាវនាវឱ្យពលករខ្មែរ រួតរះទៅបំពេញបែបបទ ដើម្បីបន្តសុពលភាពស្នាក់នៅ និងធ្វើការនៅថៃ

http://www.freshnewsasia.com/ 2020-08-31 04:58pm

**(ភ្នំពេញ)៖** ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ បានឱ្យដឹងថា រាជរដ្ឋាភិបាលថៃបានសម្រេចបន្តសុពលភាពស្នាក់នៅ និងធ្វើការជូនពលករដែលហួសសុពលភាពរហូតដល់ចុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១។ **យោងតាមសេចក្តីជូនព័ត៌មានរបស់ស្ថានទូតខ្មែរប្រជានៅប្រទេសថៃ ដែលអង្គភាពព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០នេះ បានឱ្យដឹងថា ពលករខ្មែរដែលថៃអនុញ្ញាតឱ្យបន្តសុពលភាពស្នាក់នៅ និងធ្វើការនេះ មាន ៤ក្រុមរួមមាន៖**

*ក្រុមទី១៖ ពលករដែលចូលមកធ្វើការក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MOU) ចប់កិច្ចសន្យាការងារ ៥ឆ្នាំ

*ក្រុមទី២៖ ពលករដែលចូលមកធ្វើការក្រោមនុស្សរណៈនៃការយោគយល់គ្នា (MOU) បានអស់សុពលភាពស្នាក់នៅ និងធ្វើការ ដោយសារនិយោជកចាស់ឈប់ជួល ហើយមិនអាចធ្វើការប្តូរនិយោជកបានទាន់ពេលវេលាតាមច្បាប់កំណត់

*ក្រុមទី៣៖ ពលករព្រមទាំងអ្នកនៅក្នុងបន្ទុកធ្លាប់បានបញ្ជាក់អត្តសញ្ញាណ និងមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរ ដែលអស់សុពលភាពស្នាក់នៅ និងធ្វើការចាប់ពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០២០ ដោយសារនិយោជកពុំបាននាំទៅដំណើរការ ចុះបញ្ជីឈ្មោះតាមប្រព័ន្ធអនឡាញឱ្យបានទាន់ពេលវេលា។

បើតាមស្ថានទូតខ្មែរ បានឱ្យដឹងថា ពលករទាំង៣ក្រុមខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការបណ្តោះអាសន្នចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១។ ប៉ុន្តែក្នុងអំឡុងពេលនេះ ដើម្បីទទួលបានការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និយោជក ឬតំណាងនិយោជក ត្រូវនាំពលករទៅដំណើរការដាក់ពាក្យស្នើសុំបន្តទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារ ឱ្យបានរួចរាល់ចាប់ពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០»។ ដោយឡែកក្រុមទី៤ គឺពលករដែលចូលមកធ្វើការព្រឹកវិលល្ងាច និងតាមរដូវ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

ស្ថានទូតបានគូសបញ្ជាក់ថា ក្រុមទី៤នេះ ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការបណ្តោះអាសន្នចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។ ប៉ុន្តែក្នុងអំឡុងពេលនេះ ដើម្បីទទួលបានការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការរហូតដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និយោជក ឬតំណាងនិយោជក ត្រូវនាំពលករទៅដំណើរការដាក់ពាក្យស្នើសុំបន្ត ទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារ ឱ្យបានរួចរាល់ចាប់ពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។ ពលករមានចម្ងល់លើបញ្ហានេះ អាចទាក់ទងទៅកាន់ស្ថានទូតតាមរយៈហ្វេសប៊ុកផេក ឬលេខទូរសព្ទ ០៩៨ ០៩២ ៥៩០៥។

ជាមួយនឹងសេចក្តីជូនដំណឹងនេះ មន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ក៏បានអំពាវនាវដល់ពលករកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ រួតរះទៅបំពេញបែបបទលិខិតស្នាមផ្សេងៗ ដើម្បីទទួលបានសុពលភាពស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ តាមការកំណត់របស់រាជរដ្ឋាភិបាលថៃ៕

## អ្នកទោសខ្មែរម្នាក់ ក្រុមអាជ្ញាធរថៃដោះលែង និងប្រគល់ឱ្យកម្ពុជាវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១៨:៥៥ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលេងអ្នកទោសខ្មែរម្នាក់ ឱ្យមានសេរីភាពវិញ និងបញ្ជូនខ្លួនយកមកប្រគល់ឱ្យកម្ពុជាតាមច្រកទ្វារអន្តរជាតិអូរស្មាច់ កាលពីម៉ោង២រសៀល ថ្ងៃទី៣០ សីហា ២០២០ ស្ថិតនៅក្នុងភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរម្នាក់ដែលក្រុមអាជ្ញាធរថៃធ្វើការដោះលែងមានឈ្មោះអឿន កឿន ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលបានជាប់ពន្ធនាគារនៅខេត្តសុរិន្ទ ប្រទេសថៃ រយៈពេល២ឆ្នាំ៤ខែ ពីបទលួចឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងក្នុងដីថៃ ដោយចូលតាមផ្លូវខាងលិចច្រកអន្តរជាតិជាំ និងត្រូវក្រុមទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែសីហា ២០១៧ ត្រង់ចំណុចអូរថ្លាន់ ស្ថិតក្នុងស្រុកប៊ូឆេត ខេត្តសុរិន្ទ ប្រទេសថៃ។

មន្ត្រីកម្ពុជាបម្រើការងារច្រកទ្វារអន្តរជាតិអូរស្មាច់ឱ្យដឹងថា អ្នកទោសខ្មែរម្នាក់ដែលក្រុមអាជ្ញាធរថៃដោះលែង ហើយនាំខ្លួនយកមកប្រគល់ឱ្យនោះ សមត្ថកិច្ចបានធ្វើការអប់រំ និងធ្វើកិច្ចសន្យាឱ្យបញ្ឈប់ធ្វើដំណើរឆ្លងដែនដោយខុសច្បាប់បន្តទៀត និងបានឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញក្នុងថ្ងៃដដែលផងដែរ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៨នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 31-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៨នាក់ ស្រី ២៩នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៥នាក់

https://www.facebook.com/GDIOfficial 31-08-2020

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៥នាក់ ស្រី ២៩នាក់៕

# ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

## អាជ្ញាធរខេត្តបន្ត ចុះផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក

http://nokorwatnews.com/ 01-09-2020

ខេត្តកណ្តាល៖ លោកស្រី ហ៊ិន កុសនី អភិបាលរងខេត្តកណ្តាល និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា គោលបំណងនៃការផ្សព្វផ្សាយច្បាប់ទាក់ទងនឹងការជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើផ្លូវភេទ និងការធ្វើចំណាកស្រុកដោយខុសច្បាប់ ជូនដល់បងប្អូនប្រជាពលរដ្ឋនាថ្ងៃនេះគឺចង់ឲ្យបងប្អូនប្រជាពលរដ្ឋបានជ្រួតជ្រាប ទុកជាចំណេះដឹង និងបទពិសោធន៍ដើម្បីការពារ និងអប់រំកូនចៅ ក្រុមគ្រួសារ បងប្អូន ញាតិមិត្ត កុំឲ្យចាញ់បោកកលល្បិចជនខិលខូចមួយចំនួន ដែលជាមូលហេតុធ្វើឲ្យពួកគាត់ងាយធ្លាក់ទៅក្នុងស្ថានភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម។

លោកស្រី បានបញ្ជាក់ដូច្នេះនៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន ដែលវេទិកានេះត្រូវបានរៀបចំឡើង នៅល្ងាចមិញ កាលពីរសៀលថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០២០ ដោយមានការចូលរួមពី លោកស្រីឧត្តមសេនីយ៍ត្រី ឈឹម វណ្ណនី ស្នងការរងខេត្តកណ្តាល អភិបាលរងស្រុក មន្ទីរពាក់ព័ន្ធ ប្រជាពលរដ្ឋ និងពលករ ពលការិនីជាង ៦០ នាក់។

លោកស្រីបានមានប្រសាសន៍ថា បច្ចុប្បន្ននេះរូបភាពនៃអំពើជួញដូរមនុស្ស មិនត្រឹមតែជាការជួញដូរកេងប្រវ័ញ្ច កម្លាំងពលកម្ម និងផ្លូវភេទតែប៉ុណ្ណោះទេ តែក៏មានការលេចចេញនូវបាតុភាពមួយចំនួន ដែលមានទំនោរទៅរកអំពើជួញដូរសិរីរាង្គ និងបទល្មើសរត់ពន្ធ និងជួញដូរទារកឆ្លងដែន ដែលហៅថាបទអន្តរការី នៃអំពើពរពោះជំនួស ដែលបញ្ហានេះគឺជាកង្វល់របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូច្នេះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវតែដាក់វិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបឲ្យបានទាន់ពេលវេលាចៀសវាងការរីករាលដាលបទល្មើសនិងបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងច្រើនឡើងៗ។

លោកស្រីបាន បញ្ជាក់បន្តថា ការធ្វើចំណាកស្រុកឆ្លងដែនគ្មានឯកសារផ្លូវច្បាប់ត្រឹមត្រូវបានកើតឡើងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយពលករទាំងនោះជារឿយៗត្រូវបានទទួលរងការកេងប្រវ័ញ្ចគ្រប់រូបភាព តាំងពីចេញដំណើរឆ្លងដែនរហូតដល់កន្លែងការងារ ដូចជាទទួលរងគ្រោះដោយការចាប់ឃាត់ខ្លួនដាក់ពន្ធនាគារ ការផាកពិន័យ ការចាប់បញ្ជូនត្រឡប់ ការមិនផ្ដល់ប្រាក់កម្រៃពលកម្មពេញលេញ ការបញ្ជូនបន្តទៅធ្វើការពីកន្លែងមួយទៅកន្លែងមួយ ឬនៅឆ្ងាយដែលមិនអាចទំនាក់ទំនងទៅគ្រួសារបាន មានការដកហូតអត្តសញ្ញាណប័ណ្ណលិខិតឆ្លងដែន ការធ្វើទារុណកម្មរហូតបាត់បង់ជីវិតជាបន្តបន្ទាប់។

ក្នុងវេទិកានោះ លោកស្រីវរសេនីយ៍ឯក ឈឹម វ៉ាន់នី ស្នងការរងនគរបាលខេត្តកណ្ដាល បានធ្វើការផ្សព្វផ្សាយច្បាប់ ជូនដល់អ្នកចូលរួមទាំងអស់ ដោយបញ្ជាក់ជូននូវមាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនិង ការប្រព្រឹត្តរបស់ជនល្មើស ទោសទណ្ឌដែលត្រូវទទួល តាមច្បាប់បានកំណត់ និងជាតុផ្សំដែលនាំឲ្យមានកើតបទល្មើសដោយចេតនាផងដែរ។ យោងតាមមាត្រា១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចែងថា ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំដល់១៥ ឆ្នាំនិង ផ្តន្ទាទោសឧក្រិដ្ឋជន ដាក់ពន្ធនាគារពី ១៥ ឆ្នាំ ទៅ ២០ឆ្នាំ ក្នុងករណីដែល ជនជនរងគ្រោះជាអនីតិជន៕

## ពលករចំនួន ៣២នាក់ ស្រី១២នាក់ កុមារ៤នាក់កម្លាំងប៉ុស្ដិ៍នគរបាលឃុំបឹងបេង ឃាត់ខ្លួន មណ្ឌលចត្តាឡីសក័ទី១ វិទ្យាល័យធ្វើកិច្ចសន្យាឲ្យវិលនៅស្រុកវិញ

---

http://kampucheathmey.com/ 2/9/2020 11:18 Am

**បន្ទាយមានជ័យ** ៖ កងកម្លាំងនគរបាលប៉ុស្តិ៍១ក្រុម ដឹកនាំដោយលោក អនុសេនីយ៍ត្រី ផាន់ សំណាង នាយរងប៉ុស្តិ៍បានសហការជាមួយកម្លាំង ប៉ុស្ដិ៍រដ្ឋបាលឃុំបឹងបេង និងកម្លាំងទាហានផ្នែកសឹករងស្រុកម៉ាឡៃចុះល្បាតឃាត់ខ្លួន ប្រជាពលករចំនួន ៣២នាក់ ស្រី ១២នាក់ កុមារ៤នាក់ នៅព្រឹកថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ នៅចំណុចវិលត្រលប់ពីប្រទេសថៃ តាមភូមិសាស្ត្រប៉ុស្ដិ៍ចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោក ផាន់ សំណាង បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ពលករដែលឃាត់ខ្លួននោះភាគច្រើនមកពីខេត្តមកចំនួន៨ គឺសៀមរាប១៥នាក់ ស្រី៥នាក់ ព្រៃវែង២នាក់ ស្រី១នាក់ បាត់ដំបង ៣នាក់ ស្រី២នាក់ កុមារ១នាក់ ត្បូងឃ្មុំ១នាក់ ភ្នំពេញ១នាក់ ពោធិ៍សាត់៥នាក់ ស្រី២នាក់ កុមារ២នាក់ បន្ទាយមានជ័យ៤នាក់ ស្រី២នាក់ កុមារ១នាក់ កំពង់ស្ពឺ១នាក់។ លោកផាន់ សំណាង បានបញ្ជាក់ឲ្យដឹងទៀតថា រហូតមកដល់ថ្ងៃនេះ សមត្ថកិច្ចខ្មែរ បានដំណឹងពីសមត្ថកិច្ចថៃឲ្យដឹងថា ដោយសារជំងឺកូវីដ-១៩ រាតត្បាតពេញពិភពលោកពិសេសប្រទេសថៃ ធ្វើឲ្យជនជាតិថៃ កើតជំងឺនេះមានស្លាប់ មានឆ្លង បង្ខំឲ្យនាយករដ្ឋមន្ត្រីថៃ ប្រកាសប្រទេសគ្រាមានអាសន្ន ពេលច្រកត្រូវបិទទាំងស្រុង ពលករខ្មែរបង្ខំចិត្តចាកចេញពីស្រុក ថៃស្ទើរអស់ រហូតមកដល់សព្វថ្ងៃនេះប្រទេសថៃមិនទាន់ដំណើរការដូចមុននោះឡើយ ព្រោះសំអាងថា ជំងឺកូវីដ-១៩ មិនទាន់បានធូរស្បើយនៅឡើយប្រជាជនថៃមានការប្រុងប្រយ័ត្ន

ទាំងអស់គ្នា។ សមត្ថកិច្ចថៃ បានបញ្ជាក់ទៀតថា អ្វីៗមិនទាន់ដំណើរការនៅឡើយដូច្នេះពលករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃ ប្រយ័ត្នចាញ់បោកមេខ្យល់។

លោកបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ក្រោយពីឃាត់ខ្លួនពលករចំនួន ៣២នាក់ ស្រី ១២នាក់ កុមារ៤នាក់នោះ បានធ្វើការណែនាំដល់ពលករខ្មែរទាំង៣២នាក់នេះ ឲ្យឈប់ចាញ់ការឃោសនារបស់មេខ្យល់កុំឲ្យចាញ់បោកមេខ្យល់បន្តទៀតហើយ ឲ្យធ្វើកិច្ចសន្យាបញ្ឈប់ការស្វែងរកការងារធ្វើនៅប្រទេសថៃបន្តព្រោះ វាងាយចាញ់បោកមេខ្យល់ណាស់។ លោកបានប្រាប់ឲ្យដឹងទៀតថា ពលករទាំង៣២នាក់បន្ទាប់ពីធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យារួចមកពលករទាំងអស់ត្រូវបាន សមត្ថកិច្ចបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីសក័ទី១ វិទ្យាល័យម៉ាឡៃដើម្បីពិនិត្យសុខភាពតែបើពលករទាំង៣២នាក់នេះ បើគ្មានសញ្ញាមេរោគកូវីដ-១៩នោះទេ ក៏អនុញ្ញាតឲ្យវិលត្រឡប់ទៅផ្ទះរៀងខ្លួនវិញផងដែរ៕ **អត្ថបទ៖ វ៉ាន់ ណាង**

## សមត្ថកិច្ចឃាត់ខ្លួនស្ត្រីចំណាស់ម្នាក់ ដែលគេចប្រទ័ញ្ញកម្លាំងពលកម្មកុមារ៧នាក់ឱ្យដើរសុំទានតាមសួនច្បារ

http://nokorwatnews.com/ 02-09-2020

ភ្នំពេញ៖ ស្ត្រីចំណាស់ម្នាក់ត្រូវបានកម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយមន្ត្រីមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ អង្គការមេត្រីអន្តរជាតិ (AIM) អង្គការពន្លកថ្មី និងអាជ្ញាធរមូលដ្ឋាន ឃាត់ខ្លួនពាក់ព័ន្ធនឹងករណីកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ៧នាក់ឱ្យដើរសុំទាន ។ ស្ត្រីចំណាស់រូបនេះ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន កាលពីរសៀលថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ នៅចំណុចតាមសួនច្បារមុំសណ្ឋាគារសុខា ផ្លូវទន្លេសាប សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា។

សមត្ថកិច្ចបានបញ្ជាក់ប្រាប់ថា ស្ត្រីចំណាស់រូបនេះឈ្មោះ អ៊ុំ យឿន អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅនិងមុខរបរមិនពិតប្រាកដ ។ ស្ត្រីចំណាស់រូបនេះបានសារភាពប្រាប់សមត្ថកិច្ចថា ជារៀងរាល់ព្រឹកគាត់បាននាំក្មេងៗទៅសុំទាននៅតាមសួនច្បារមុំសណ្ឋាគារសុខា រហូតដល់ពេលល្ងាច ទើបឱ្យក្មេងៗដេកនៅតាមសំយាបផ្ទះប្រជាពលរដ្ឋនៅមុំជ្រោយចង្វារវិញ ។ ក្នុងនោះផងដែរ ក្មេងៗម្នាក់ៗក្នុង១ថ្ងៃ អាចសុំទានបានលុយ ពី២ម៉ឺនរៀល ទៅ៣ម៉ឺនរៀល ដែលលុយទាំងនោះគាត់យកទាំងអស់ដោយឱ្យក្មេងៗម្នាក់១,៥០០រៀលឬ២,០០០រៀលប៉ុណ្ណោះគ្រាន់ទិញអីហូប ។

សូមបញ្ជាក់ផងដែរថា ស្ត្រីរូបនេះជាមនុស្សញៀនស្រា ថ្ងៃណាមួយដែលក្មេងៗមិនដើរសុំទាន់ស្ត្រីនោះវ៉ៃដំទៅលើក្មេងៗនោះផងដែរ ។ បច្ចុប្បន្ន ស្ត្រីរូបនេះ សមត្ថកិច្ចកំពុងឃាត់ខ្លួនសាកសួរតាមនីតិវិធី ។ ចំណែកកុមារទាំង៧នាក់ត្រូវបាននគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ៕ **ដោយ៖ចេស្តា**

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៤១នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 01-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤១នាក់ ស្រី ០៨នាក់ និងកុមារ ០៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិន

ទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១១១នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 01-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១១១នាក់ ស្រី ៤៩នាក់ និងកុមារ ០៩នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន០២នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខេត្តកោះកុង

https://www.facebook.com/GDIOfficial 01-09-2020

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតក្នុងភូមិសាស្ត្រស្លាបស្តាំ ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនខុសច្បាប់ចំនួន០២នាក់ និង០២នាក់ទៀត ត្រូវបានភាគីថៃបញ្ជូនមក ដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មានកូវីដ-១៩៕

## ពលរដ្ឋខ្មែរចំនួន ០៤នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្តាំនិងស្លាបឆ្វេង) របស់ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 01-09-2020

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍ចំនួន ០៣នាក់ និងស្លាបឆ្វេងចំនួន ០១នាក់។ នគរបាលប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានសហការជាមួយផ្នែកចត្តាឡីស័ក ធ្វើការអប់រំណែនាំ និងពិនិត្យកំដៅជូនពួកគាត់ រួចបានប្រគល់អ្នកទាំងពីរនាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យ ចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៣នាក់

https://www.facebook.com/GDIOfficial 01-09-2020

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៣នាក់ ស្រី ៧៦នាក់៕

# ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

## លោក នេត សាវឿន ដាក់ផែនការពង្រឹងវិធានការសន្តិសុខ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 02 September 2020 | 09:50 ICT

**ភ្នំពេញៈ** នាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ លោក នេត សាវឿន បានដាក់ចេញនូវផែនការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនៅកម្ពុជាដល់គណៈបញ្ជាការសន្តិសុខសុវត្ថិភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីរៀបចំជាក្រុមការងារជំនាញ និងសហប្រតិបត្តិការជាមួយស្ថាប័នអន្តរក្រសួង និងអន្តរជាតិ។ ការដាក់ចេញផែនការនេះធ្វើឡើងក្នុងកិច្ចប្រជុំស្ដីពីការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាលពីថ្ងៃទី ៣១ សីហា ក្រោមអធិបតីភាព នាយឧត្តមសេនីយ៍ លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងមានការចូលរួមពីអគ្គស្នងការរង ប្រធាននាយកដ្ឋានស្នងការរាជធានី-ខេត្ត និងមន្ត្រីនគរបាលពាក់ព័ន្ធជាច្រើនរូបទៀតនៅទីស្ដីការក្រសួងមហាផ្ទៃ។

លោក ឆាយ គីមខឿន អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិប្រាប់អ្នកសារព័ត៌មានក្រោយបញ្ចប់កិច្ចប្រជុំថា កិច្ចប្រជុំនេះបានដាក់ចេញនូវការពង្រឹងវិធានការទៅលើសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់សង្គម និងពង្រឹងការងារលើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ លោកថ្លែងថា៖ «កិច្ចប្រជុំនេះ គឺបានប្រកាសបែងចែកគណៈបញ្ជាការសន្តិសុខ សុវត្ថិភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបានរៀបចំជាក្រុមការងារ ផ្នែកជំនាញ ផ្នែកសហប្រតិបត្តិការជាមួយអន្តរក្រសួង និងអន្តរជាតិ»។ លោកបន្តថា៖ «កិច្ចប្រជុំនេះ យើងផ្ដោតសំខាន់សំដៅលើការប្រមូលព័ត៌មាន ការបែងចែកប្រគល់ភារកិច្ចច្បាស់លាស់ដល់ក្រុមការងារ ដើម្បីម្ចាស់ការគ្រប់គ្រងសភាពការណ៍ពាក់ព័ន្ធផ្នែកសន្តិសុខ សុវត្ថិភាព និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ»។ បើតាមមន្ត្រីនាំពាក្យរូបនេះ ការងារប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនេះ អគ្គស្នងការនគរបាលជាតិ លោក នេត សាវឿន បានដាក់ទិសដៅស្រួច ទៅលើការឯកភាពគ្នាពាក់ព័ន្ធទៅនឹងការប្រមូលផ្ដុំកងកម្លាំងទៅតាមសភាពការណ៍ ដើម្បីអាចចាត់វិធានការមានប្រសិទ្ធភាពសំដៅរំដោះជនរងគ្រោះ។

ពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់(ការវាយតម្លៃរបស់អាមេរិកមកលើកម្ពុជា) លោក ឆាយ គីមខឿន បញ្ជាក់ថា៖ «អាមេរិកគាត់ដាក់ គាត់អត់ដែលបានសួរយើងផង។ ក៏ប៉ុន្តែរឿងយើងសំខាន់ គឺការសង្គ្រោះជនរងគ្រោះដែលកំពុងតែធ្លាក់ទៅក្នុងរណ្ដៅនៃការជួញដូរ។ ដូច្នេះការដាក់ចេញនូវវិធានការនេះគឺមានវិធានការជំនាញ ការអប់រំ និងពង្រឹងឡើងវិញនូវសុវត្ថិភាពក្នុងការស្រាវជ្រាវស៊ើបអង្កេតរបស់នគរបាល ជាពិសេសមន្ត្រីអនុវត្តច្បាប់»។ លោកថ្លែង

ថាការវាយតម្លៃរបស់អាមេរិកចំពោះកម្ពុជានេះប្រហែលជាអាមេរិកប្រមូលព័ត៌មានមិនអស់ពីកម្ពុជា និងប្រហែលជាមិនបានវាយតម្លៃច្បាស់លាស់ពាក់ព័ន្ធទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា។ លោកបញ្ជាក់ថា៖«ការវាយតម្លៃនេះមានការបាត់តម្លាភាពខ្លះ មិនបានគ្រប់ជ្រុងជ្រោយទេ។ គាត់មិនទាំងដាក់តារាងពិន្ទុនៃការវាយតម្លៃរបស់គាត់នោះឱ្យយើងមើលផង។ ដូច្នេះការវាយតម្លៃរបស់គាត់គឺជាសិទ្ធិរបស់គាត់ ព្រោះគាត់មិនដែលហៅយើងទៅប្រជុំវាយតម្លៃឯណា។ ប៉ុន្តែទោះយ៉ាងណា ការវាយតម្លៃបៀបណា វាក៏ជាផ្នែកមួយដែលបានពាក់ព័ន្ធនឹងកិត្តិយសរបស់កម្ពុជា»។ លោក ឆាយ គឹមខឿន បន្ថែមថា រាជរដ្ឋាភិបាលមានឆន្ទៈច្បាស់លាស់ កងកម្លាំងនគរបាលជាតិ កងកម្លាំងអនុវត្តច្បាប់មានស្មារតីប្ដេជ្ញាចិត្តច្បាស់លាស់ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស សំខាន់បំផុតគឺការរំដោះពលរដ្ឋជាជនរងគ្រោះពីការជួញដូរ។

កាលពីខែមិថុនា ក្រសួងការបរទេសអាមេរិកបានចេញរបាយការណ៍ឆ្នាំ ២០២០ អំពីស្ថានភាពការជួញដូរមនុស្សនៅទូទាំងសកលលោក។ កម្ពុជាត្រូវបានដាក់ក្នុងបញ្ជីឃ្លាំមើលកម្រិត ២ ដែលជាប្រទេសមិនបានបំពេញតាមស្តង់ដាអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្ស។

លោក អំ សំអាត ប្រធានផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សនៃអង្គការ លីកាដូ មើលឃើញថា បញ្ហានៃការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា នៅតែជាក្ដីកង្វល់។ កត្តានេះហើយទើបអាមេរិកបានដាក់កម្ពុជាក្នុងបញ្ជីឃ្លាំមើលកម្រិត ២ ដែលជាប្រទេសមិនបានបំពេញតាមស្តង់ដាអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្ស។ លោក សំអាត បានថ្លែងថា៖ «ដូច្នេះបើឆ្នាំនេះ រាជរដ្ឋាភិបាលមិនខិតខំប្រឹងប្រែងទៀត វាអាចធ្លាក់ចំណាត់ថ្នាក់ទៅដល់លេខ ៣។ ដូច្នេះបញ្ហានេះជាការឆ្លុះបញ្ចាំងមួយដើម្បីឱ្យរាជរដ្ឋាភិបាល ជាពិសេសស្ថាប័នពាក់ព័ន្ធពង្រឹងនូវកិច្ចការពារដល់ជនរងគ្រោះពីការជួញដូរនៅកម្ពុជា»៕

## កម្ពុជា-អូស្ត្រាលី ប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិល្អក្នុងការបង្ការ និងទប់ស្កាត់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែននានា

http://ppd-news.net/ ថ្ងៃចេញផ្សាយ: September 3, 2020

**ភ្នំពេញ** ៖ នៅរសៀល ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានទទួលជួបពិភាក្សាការងារជាមួយលោក ANTHONY MAGUIRE នាយនគរបាលជាន់ខ្ពស់ នៃនគរបាលសហព័ន្ធអូស្ត្រាលី នាឱកាសដែលលោកទើបតែមកបំពេញភារកិច្ច ក្នុងអាណត្តិការងារថ្មី នៅព្រះរាជាណាចក្រកម្ពុជា។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន របស់តំណាងនគរបាលសហព័ន្ធអូស្ត្រាលី និងបានបង្ហាញក្តីរំពឹងយ៉ាងមុតមាំថា ក្នុងអាណត្តិថ្មីរបស់លោក ANTHONY MAGUIRE នាយនគរបាលជាន់ខ្ពស់ នៃនគរបាលសហព័ន្ធអូស្ត្រាលី កម្ពុជា និងអូស្ត្រាលី នឹងនៅតែបន្តកិច្ចសហប្រតិបត្តិល្អ ក្នុងការបង្ការ និងទប់ស្កាត់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែននានា ដែលមានដូចជាអំពើជួញដូរគ្រឿងញៀនខុសច្បាប់គ្រប់រូបភាព អំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្សជាដើម ដោយទទួលបានជោគជ័យជាបន្តបន្ទាប់។

ជាមួយគ្នានេះផងដែរ លោក ANTHONY MAGUIRE នាយនគរបាលជាន់ខ្ពស់ នៃនគរបាលសហព័ន្ធអូស្ត្រាលី ក៏បានថ្លែងអំណរគុណអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលបានផ្តល់នូវកិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក តាមរយៈកិច្ចសហប្រតិបត្តិការត្រីភាគី ដែលឱ្យឈ្មោះ Strikeforce Dragon សំដៅបង្ការ និងទប់ស្កាត់បទល្មើសឧក្រិដ្ឋកម្មឆ្លងដែននានា ដែលអាចបង្កហានិភ័យដល់សន្តិសុខជាតិនៃប្រទេសទាំងពីរ។

ផ្ទៀតក្នុងឱកាសនៃជំនួបពិភាក្សានេះផងដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះរដ្ឋាភិបាលអូស្ត្រាលី តាមរយៈស្ថានទូតអូស្ត្រាលី និងនគរបាលសហព័ន្ធអូស្ត្រាលី ដែលតែងតែយកចិត្តទុកដាក់ផ្តល់ជាជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនានា ដល់មន្ត្រីអន្តោប្រវេសន៍កម្ពុជា នាបណ្តាឆ្នាំកន្លងមក ក្នុងភាពជាដៃគូកិច្ចសហប្រតិបត្តិការ លើការងារអន្តោប្រវេសន៍៕

## ឧត្តមសេនីយ៍ទោ កឹង យន បើកកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារ ស្តីពីការពង្រឹង វិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://cambodiapolice.com/policekh/ 12:32 pm 2 កញ្ញា 2020

ខេត្តស្វាយរៀង ៖ ព្រឹកថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នៅស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានបើកកិច្ចប្រជុំ ផ្សព្វផ្សាយខ្លឹមសារ ស្តីពីការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ កិច្ចប្រជុំស្ថិតក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ទោ កឹង យន ស្នងការនគរបាលខេត្តស្វាយរៀង ដោយមានការអញ្ជើញចូលរួមពីលោក លោកស្រី ស្នងការរង លោកអនុប្រធានផែនការងារសេនាធិការ និងសន្តិសុខ លោក លោកស្រីនាយ នាយរងការិយាល័យសរុបផែនការ ការិយាល័យចំណុះផែនការងារសន្តិសុខ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការិយាល័យ គ្រប់គ្រងការស្នាក់នៅ លោកអធិការ អធិការរងទទួលការងារសេនាធិការ សន្តិសុខ និងប្រឆាំងការជួញដូរមនុស្ស នៃអធិការដ្ឋាននគរបាលក្រុង/ស្រុកទាំង៨ លោកមេបញ្ជាការ មេបញ្ជាការរងទទួលការងារសេនាធិការ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកទាំងពីរ ។

បន្ទាប់ពីមានប្រសាសន៍ផ្សព្វផ្សាយខ្លឹមសារ ស្តីពីការពង្រឹង វិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួចមកលោកឧត្តមសេនីយ៍ទោ ស្នងការនគរបាលខេត្ត បានធ្វើការផ្សព្វផ្សាយផែនការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងឱកាសបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌឆ្នាំ២០២០ ព្រមទាំងប្រគល់ត្រាស្ទួត បោះលើរូបថត សម្រាប់ធ្វើសៀវភៅគ្រួសារ ដល់ប្រជាពលរដ្ឋ ជូនអធិការដ្ឋាននគរបាលក្រុង/ស្រុកទាំង៨ផងដែរ ៕

## ឧត្តមសេនីយ៍ទោ ឯម កុសល ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងផ្សព្វផ្សាយផែនការក្នុងការរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

http://cambodiapolice.com/policekh/ 11:30 am 2 កញ្ញា 2020

កំពង់ចាម ៖ នៅព្រឹកថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ ឯម កុសល ស្នងការនគរបាលខេត្តកំពង់ចាម បានដឹកនាំកិច្ចប្រជុំស្តីពី ៖

-ការបូកសរុបសភាពការណ៍ លទ្ធផលកិច្ចប្រតិបត្តិការ រក្សាសន្តិសុខសង្គម ការងារនគរបាលសហគមន៍ប្រចាំខែសីហា និងរយៈពេល០៩ខែ និងលើកទិសដៅខែកញ្ញា។

-ផ្សព្វផ្សាយផែនការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២០-២០២១។

-ផ្សព្វផ្សាយផែនការ ដែលទទួលបានពីកិច្ចប្រជុំនៅក្រសួងមហាផ្ទៃ ស្តីពីវិធានការសន្តិសុខ និងការប្រយុទ្ធប្រឆាំងអំពើការជួញដូរមនុស្ស។

-ផ្សព្វផ្សាយ ផែនការការពារ សន្តិសុខ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ក្នុងពិធីបុណ្យ កាន់បិណ្ឌ និង បុណ្យ កឋិនទាន ឆ្នាំ២០២០ ខាងមុខនេះ ។

កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅសាលប្រជុំធំ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដោយមានការចូលរួមពី លោក លោកស្រីស្នងការរង លោកអនុប្រធានផែន លោក លោកស្រីនាយការិយាល័យជំនាញគ្រប់រូប លោក លោកស្រីនាយរងការិយាល័យ (ទទួលការងាររដ្ឋបាលសរុបគ្រប់រូប) លោក លោកស្រីអធិការ-អធិការរងនគរបាលស្រុក ក្រុងទាំង១០ និងលោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង១០៩ សរុបអ្នកចូលរួមមានចំនួន ២៧៨នាក់ ៕

## ថៃសម្រេចបន្តសុពលភាពនៃការស្នាក់នៅ និងធ្វើការសម្រាប់ពលករខ្មែរដល់ឆ្នាំ ២០២២

https://www.postkhmer.com/ មុំ គន្ធា | Publication date 02 September 2020 | 10:47 ICT

**ភ្នំពេញៈ** រាជរដ្ឋាភិបាលរបស់ប្រទេសថៃ បានសម្រេចបន្តសុពលភាពនៃការស្នាក់នៅ និងធ្វើការដល់ពលករ ខ្មែររហូតដល់ខែមីនា ឆ្នាំ ២០២២ ដោយតម្រូវឱ្យនិយោជក ឬតំណាងនិយោជកត្រូវនាំពលករទៅដាក់ពាក្យស្នើសុំ បន្តទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារចាប់ពីខែសីហា ដល់ចុងខែតុលា ឆ្នាំ ២០២០។

យោងតាមសេចក្តីជូនដំណឹងរបស់ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ ស្តីពីការបន្ត ស្នាក់នៅ និងធ្វើការសម្រាប់បងប្អូនពលករខ្មែរក្នុងស្ថានភាពនៃជំងឺកូវីដ ១៩ ដែលកាសែតភ្នំពេញប៉ុស្តិ៍ទទួលបាន កាលពីថ្ងៃអង្គារម្សិលមិញនេះបានឱ្យដឹងថា ចំពោះពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ក្នុង ស្ថានភាពការរីករាលដាលនៃជំងឺកូវីដ ១៩ នេះ រដ្ឋាភិបាលថៃបានសម្រេចបន្តសុពលភាពការស្នាក់នៅ និងធ្វើការ ដល់ពលករខ្មែរចំនួន ៤ ក្រុម។

សម្រាប់ក្រុមទី១ គឺពលករដែលចូលមកធ្វើការក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MoU) ចប់កិច្ច សន្យាការងារ ៤ ឆ្នាំ។

ក្រុមទី២ គឺជាក្រុមពលករដែលចូលមកធ្វើការក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MoU) បានអស់សុ ពលភាពស្នាក់នៅ និងនៅធ្វើការដោយសារនិយោជកចាស់ឈប់ជួល ហើយមិនអាចធ្វើការប្តូរនិយោជកបានទាន់ ពេលវេលាតាមច្បាប់កំណត់។

ឯពលករក្រុមទី៣ គឺពលករព្រមទាំងអ្នកនៅក្នុងបន្ទុកធ្លាប់បានបញ្ជាក់អត្តសញ្ញាណ និងមានលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរដែលអស់សុពលភាពស្នាក់នៅ និងធ្វើការចាប់ពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ដោយសារនិយោជកពុំបាននាំទៅដំណើរការចុះបញ្ជីឈ្មោះតាមប្រព័ន្ធអនឡាញឱ្យបានទាន់ ពេលវេលា។

សម្រាប់ក្រុមចុងក្រោយគឺក្រុមទី៤ គឺពលករដែលចូលមកធ្វើការព្រឹកវិលល្ងាច និងតាមរដូវតាមបណ្តាខេត្ត ជាប់ព្រំដែនកម្ពុជា-ថៃ។

ស្ថានទូតកម្ពុជាបានបញ្ជាក់ថា៖ «សម្រាប់ក្រុមទី១ ទី២ និងទី៣ ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការប ណ្តោះអាសន្នចាប់តាំងពីដើមខែសីហា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២១ ប៉ុន្តែក្នុងអំឡុង ពេលនេះ ដើម្បីទទួលបានការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ និយោជក ឬតំណាងនិយោជកត្រូវនាំពលករខ្មែរទៅដំណើរការដាក់ពាក្យស្នើសុំបន្តទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារ ឱ្យបានរួចរាល់ចាប់ពីថ្ងៃទី ១៧ ខែសីហា ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០២០»។

សេចក្តីជូនដំណឹងនេះបានឲ្យដឹងថា សម្រាប់ពលករក្នុងក្រុមទី៤ គឺត្រូវបានអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការ បណ្តោះអាសន្នចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២០ ប៉ុន្តែក្នុងអំឡុងពេល នេះ ដើម្បីទទួលបានការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ និងនិយោជក ឬ

តំណាងនិយោជកត្រូវនាំពលករទៅធ្វើដំណើរការដាក់ពាក្យស្នើសុំបន្តទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតការងារឱ្យបានរួចរាល់ចាប់ពីថ្ងៃទី ១៧ ខែសីហា ដល់ខែតុលា ឆ្នាំ ២០២០។

លោក ហេង សួរ អ្នកនាំពាក្យនៃក្រសួងការងារមិនអាចសុំការអធិប្បាយបានទេកាលពីថ្ងៃអង្គារម្សិលមិញនេះ។ ចំណែកលោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថា ការបន្តសុពលភាពនៃការស្នាក់នៅ និងធ្វើការគឺជារឿងមួយល្អសម្រាប់ពលករដែលកំពុងនៅប្រទេសថៃ ប៉ុន្តែមានចំណុចមួយចំនួនដែលរដ្ឋាភិបាលកម្ពុជាត្រូវគិតចំពោះពលករខ្មែរនៅពេលដែលថៃបន្តបិទប្រទេសរបស់គេដែលស្ថានភាពសេដ្ឋកិច្ចនៅប្រទេសគេក៏មិនទាន់បានល្អប្រសើរដែរ ដោយសារមានក្រុមហ៊ុនឯកជនជាច្រើនទទួលរងនូវផលប៉ះពាល់ពីជំងឺកូវីដ ១៩ ដោយបន្តព្យួរ បិទ និងកាត់បន្ថយកម្លាំងពលកម្មកម្មករជាដើម។

លោក មឿន តុលា បានថ្លែងថា៖ «ខ្ញុំគិតថា អ្វីដែលរដ្ឋាភិបាលរបស់យើងត្រូវធ្វើគឺគួរពិចារណាជួយពលករខ្មែរយើងដែលបាត់បង់ការងារ បាត់បង់ចំណូលនៅថៃដោយការផ្តល់នូវជំនួយឧបត្ថម្ភផ្សេងៗ ស្បៀងអាហារ ឬថវិកាជាដើម។ មួយវិញទៀតគឺការជួយដោះបន្ទុករបស់ក្រុមគ្រួសារពួកគាត់នៅស្រុកកំណើតដែលជំពាក់បំណុលធនាគារ ឬអ្នកណាម្នាក់ គួរតែរដ្ឋាភិបាលជួយសម្រួលដោយការបន្ថយការប្រាក់ ឬពន្យារការបង់មួយរយៈដើម្បីដោះស្រាយជីវភាព»៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧២នាក់

https://www.facebook.com/GDIOfficial 02-09-2020

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧២នាក់ ស្រី ៨២នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

# ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០

## សមត្ថកិច្ចក្រុងតាខ្មៅបង្ក្រាបកន្លែងម៉ាស្សាកោសជប់មួយកន្លែងបង្កប់សេវាកម្មពិសេស និងរកឃើញស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើមួយចំនួន

https://khmernote.com.kh/ September 4, 2020 Khmernote Media

ខេត្តកណ្ដាល៖ សមត្ថកិច្ចបានចេញប្រតិបត្តិការបង្ក្រាបកន្លែងម៉ាស្សាកោសជប់មួយកន្លែង ដែលលួចបង្កប់បំរើសេវាផ្លូវភេទ។ ហេតុការណ៍នេះបានកើតឡើងកាលពីយប់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ស្ថិតនៅចំណុចផ្ទះម៉ាស្សាកោសជប់យីហោ ៦៦៦ ភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ នៅក្នុងប្រតិបត្តិការនោះផងដែរ មានជនរងគ្រោះចំនួន០៦នាក់៖

១-ឈ្មោះចាន់ រតនា ភេទស្រី អាយុ២០ឆ្នាំ ទីលំនៅ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរ ស្ត្រីបំរើសេវា។

២-ឈ្មោះជិន ឧស្សាហ៍ ភេទស្រី អាយុ២០ឆ្នាំ ទីលំនៅ ភូមិចំបក់ទ្រាប់ ឃុំព្រែកការ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មុខរបរ ស្ត្រីបំរើសេវា។

៣-ឈ្មោះជួប ស្រីម៉ុច ភេទស្រី អាយុ២០ឆ្នាំ ទីលំនៅ ភូមិលេខ២ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល មុរបរ ស្ត្រីបំរើសេវា។

៤-ឈ្មោះនី ស្រីនីត ភេទស្រី អាយុ២០ឆ្នាំ ទីលំនៅ ខេត្តរតនគិរី មុខរបរ ស្ត្រីបំរើសេវា

៥-ឈ្មោះខៀវ សិរីសួស្តី ភេទស្រី អាយុ២២ឆ្នាំ ទីលំនៅ ខេត្តពោធិ៍សាត់ មុខរបរ ស្ត្រីបំរើសេវា

៦-ឈ្មោះង្វៀង ធីកាំធូ ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិវៀតណាម ទីលំនៅ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ ស្ត្រីបំរើសេវា។

ចំណែកឯជនសង្ស័យចំនួន០១នាក់មានឈ្មោះចិន ស៊ាប ភេទស្រី អាយុ៣៧ឆ្នាំ ទីលំនៅ ផ្ទះលេខ៣៣១ ភូមិរមាសឈរ ឃុំគោខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មុខរបរ ម្ចាស់ហាងម៉ាស្សាកោជប់ឃីហោ៦៦(ឃាត់ខ្លួន)។ វត្ថុតាងដែលសមត្ថកិច្ចចាប់បានរួមមាន៖

-ស្រោមអណាម័យប្រើប្រាស់រួច និងមិនទាន់ប្រើប្រាស់មួយចំនួន។

-ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនមេតំហ្វេតាមីនម៉ាទឹកកក ice ចំនួន ២កញ្ចប់តូច និងឧបករណ៍សំរាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន។

នៅវេលាកើតហេតុខាងលើ មានប្រជាពលរដ្ឋល្អបានរាយការណ៍ថា:មានហាងម៉ាស្សាកោសជប់ឃីហោ៦៦៦មួយកន្លែងបានបើកបង្កប់កន្លែងជួញដូរផ្លូវភេទ ហើយកំលាំង នៃអធិការដ្ឋាននគរបាលក្រុងតាខ្មៅសហការណ៍ជាមួយកំលាំងជំនាញប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន កំលាំងការិយាល័យព្រហ្មទណ្ឌកំរិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល ដែលមានការចូលរួមពីបុគ្គលិកអង្គការកុមារមេត្រីបានចុះទៅបង្ក្រាបនៅទីតាំងខាងលើភ្លាមដោយបានធ្វើការឆែកឆេររកឃើញវត្ថុតាងដូចខាងលើ ឃាត់ខ្លួនជនសង្ស័យ និងស្ត្រីបំរើសេវាផ្លូវភេទយកទៅសាកសួរនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីចាត់ការតាមនីតិវិធី៕

## ពលរដ្ឋខ្មែរ ជិត២០០នាក់បន្តវិលចូលប្រទេសវិញ តាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ

https://kbn.news/ September 3, 2020

**រាជធានីភ្នំពេញ÷** នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទីពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៧២នាក់ ស្រី ៨២នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ៤នាក់ ស្រី ១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព។

បើតាមអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន៕

## បញ្ជូនស្ត្រីបង្ខំក្មេងឲ្យដើរសុំទាននៅតុលាការ

https://www.postkhmer.com/ គីម សារុំ | Publication date 03 September 2020 | 13:13 ICT

**ភ្នំពេញៈ** សមត្ថកិច្ចប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរៀបចំបញ្ជូនស្ត្រីចំណាស់ម្នាក់ទៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃនេះ បន្ទាប់ពីឃាត់ខ្លួនកាលពីថ្ងៃទី១ កញ្ញា ពាក់ព័ន្ធករណីបង្ខំក្មេងប្រុស-ស្រី ៧ នាក់ឲ្យដើរសុំទាននៅរាជធានីភ្នំពេញ។

លោក កែវ ជា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញប្រាប់ពីម្សិលមិញថា ស្ត្រីសង្ស័យមាននោះ ឈ្មោះ អ៊ុ យឿន អាយុ ៥៨ ឆ្នាំជាជនជាតិខ្មែរ តែមិនមានមុខរបរ និងលំនៅច្បាស់លាស់ទេ។ សមត្ថកិច្ចរបស់លោកបានសាកសួរស្ត្រីសង្ស័យម្នាក់នោះរួចរាល់ហើយ ហើយត្រូវបញ្ជូនគាត់បន្តមកសាលាដំបូងរាជធានី-ភ្នំពេញនៅថ្ងៃទី ៣ កញ្ញានេះ។ លោកថ្លែងថា៖ «ស្ត្រីចំណាស់ម្នាក់នោះបានឲ្យកុមារៗដើរសុំទានហើយកុមារដែលខាងការិយាល័យខ្ញុំប្រមូលបាន ៧ នាក់នោះ ខ្ញុំបានបញ្ជូនទៅមន្ទីរសង្គមកិច្ចអស់ហើយ»។ លោក កែវ ជា ឲ្យដឹងបន្តថា បើតាមចម្លើយសារភាពរបស់ស្ត្រីសង្ស័យថា ជារៀងរាល់ព្រឹកគាត់បាននាំក្មេងៗទៅសុំទាននៅតាមសួនច្បារម្តុំសណ្ឋាគារសុខាត្រើយខាងកើតរហូតដល់ពេលល្ងាច ទើបគាត់នាំពួកគេទៅដេកនៅតាមសំយាបផ្ទះពលរដ្ឋនៅម្តុំសង្កាត់ជ្រោយចង្វារវិញ។ ចំពោះក្មេងម្នាក់ៗក្នុង ១ ថ្ងៃ ដើរសុំទានពីភ្ញៀវបានលុយចន្លោះពី ២ ម៉ឺន ទៅ ៣ ម៉ឺនរៀល ប៉ុន្តែស្ត្រីនោះយកទាំងអស់ដោយទុកឲ្យពួកគេម្នាក់ៗចាយពី ១ ពាន់ទៅ ២ ពាន់រៀលប៉ុណ្ណោះ។ លោកឲ្យដឹងដែរថា ប្រតិបត្តិការចាប់ខ្លួននេះគឺមានការចូលរួមសហការពីមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ, អង្គការមេត្រីអន្តរជាតិ (AIM), អង្គការពន្លកថ្មី និងអាជ្ញាធរមូលដ្ឋានដែលនៅចំណុចតាមសួនច្បារម្តុំសណ្ឋាគារសុខា ផ្លូវទន្លេសាប សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ក្នុងនោះសមត្ថកិច្ចលោកបានឃាត់ខ្លួនបានស្ត្រីម្នាក់ និងរំដោះបានកុមារា-កុមារីចំនួន ៧ នាក់។ បន្ទាប់មកបានប្រគល់កុមារទាំងនោះទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ពាក់ព័ន្ធនឹងបញ្ហានេះ លោកស្រី មុំ ចាន់ដានី ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ភ្នំពេញឲ្យដឹងពីម្សិលមិញដែរថា កុមារទាំង ៧ នាក់នោះមាន ៥ នាក់ ជាកុមារា និង ២ នាក់ ជាកុមារី ដែលមានអាយុចន្លោះពី ២ ឆ្នាំទៅ ៦ ឆ្នាំ ប៉ុន្តែពួកគេសុទ្ធតែមិនចេះអក្សរ។ តាមចម្លើយរបស់កុមារនោះថា ពួកគេរស់នៅម្តុំច្រាំងចំរេះប៉ុន្តែលោកស្រីមិនទាន់យកជាការបានទេព្រោះខ្លាចក្មេងទាំងនោះនៅតូចមិនស្គាល់លំនៅច្បាស់លាស់។ លោកស្រីបានបន្តថា បន្ទាប់ពីទទួលបានកុមារទាំង ៧ នាក់មកគឺមន្ត្រីរបស់លោកស្រីកំពុងសួរពីប្រវត្តិរបស់ពួកគេជាមួយនឹងការពិនិត្យសុខភាព និងផ្តល់អាហារឲ្យហូបចុកផង។ ចំណែកម្តាយឪពុក ឬសាច់ញាតិរបស់ពួកគេវិញគឺមន្ត្រីរបស់លោកស្រីកំពុងស្រាវជ្រាវរកមិនទាន់ឃើញទេ។ តែបើក្នុងករណីពួកគេមិនមានម្តាយឪពុកវិញ គឺខាងមន្ទីរសង្គមកិច្ចមានមណ្ឌលមួយសម្រាប់ឲ្យពួកគេស្នាក់នៅដែលហៅថាមណ្ឌលថែទាំជំនួស។ លោកស្រីបានឲ្យដឹងដែរថា បច្ចុប្បន្នខាងមន្ទីរសង្គមកិច្ចរាជធានីមានដៃគូសហការក្នុងការថែទាំក្មេងទាំងរដ្ឋ និងអង្គការព្រមទាំងមានមណ្ឌលគាំទ្រកុមារនៅតាមសហគមន៍ផងដែរ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 03-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ វ៉ាន់ វ៉ាត់ ភេទប្រុស អាយុ ២៤ឆ្នាំ មានទីលំនៅភូមិកោងកាង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ, ២-

ឈ្មោះ អៀង សុអៀប ភេទប្រុស អាយុ ៤៦ឆ្នាំ មានទីលំនៅភូមិវត្តថ្មី ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ, ៣-ឈ្មោះ ហួត រ៉េន ភេទប្រុស អាយុ ៣២ ឆ្នាំ មានទីលំនៅភូមិព្រៃខ្លា ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង, ៤-ឈ្មោះ សុង សិទ្ធ ភេទប្រុស អាយុ ២៤ឆ្នាំ មានទីលំនៅភូមិព្រៃទទឹង ឃុំព្រៃទទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និង បានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ១៣នាក់ដែលអាជ្ញាធរថៃបញ្ជូនមក

https://www.facebook.com/GDIOfficial 03-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៣នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១០១នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 03-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០១នាក់ ស្រី ៥១នាក់ និងកុមារ ១១នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១០នាក់

https://www.facebook.com/GDIOfficial 03-09-2020

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១០នាក់ ស្រី ៦៣នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ០៣នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្បូងជី

https://www.facebook.com/GDIOfficial 03-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្បូងជី នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបឆ្វេង) របស់ប៉ុស្តិ៍ចំនួន ០៣នាក់ និងបានសហការជាមួយផ្នែកចត្តាឡីស័ក ធ្វើការអប់រំណែនាំ និងពិនិត្យកំដៅជូនពួកគាត់ រួចបានប្រគល់អ្នកទាំងបីនាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យ ចូល-ចេញ ជាធម្មតា៕

## ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០

## កម្ពុជាមិនអស់ចិត្តការវាយតម្លៃរបស់អាមេរិកឲ្យខ្លួនជាប់ចំណាត់ថ្នាក់លេខ២រឿងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

http://btv.com.kh/ 07/09/2020

ភ្នំពេញ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង បានសម្តែងការមិនអស់ចិត្ត និងកំពុងតែឆ្ងល់ចំពោះអាមេរិក ដែលបានវាយតម្លៃដោយដាក់ចំណាត់ថ្នាក់លេខ២ដល់កម្ពុជា ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងចាត់ទុកថាការដាក់នេះជារឿងអយុត្តិធម៌បំផុតសម្រាប់កម្ពុជានោះ។ ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពីចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសសន្តប្រវេសន៍ នាព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០នេះ នៅ សណ្ឋាគារកាំបូឌីយ៉ាណាលោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងការជួយដូរមនុស្ស ហើយរបាយការណ៍ដែលអាមេរិកបានដាក់ឲ្យ កម្ពុជានេះគឺមិនដឹងបានមកពីខាងណានោះទេ ខណៈរបាយការណ៍ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់នោះបែរគេចោទថា មានការចន្លោះប្រហោងច្រើននោះ។

យោងតាមរបាយការណ៍អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៧៨ករណី លើ ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។ របាយការណ៍បានបញ្ជាក់បន្ថែមថា ក្នុងឆមាសទី១នេះ អាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៩៧នាក់ លើ ៨៥នាក់ (កើន១២នាក់ ស្មើនឹង១៤%) ក្នុងនោះស្រី ២២នាក់ អនីតិជន ៩នាក់ ជាជនបរទេស ១៤នាក់ សញ្ជាតិចិន ១២នាក់ និងអាមេរិក ២នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ២៦៣នាក់ (លើ១០៦នាក់) កើន ១៥៧នាក់ ស្មើនឹង ១៤៨% ក្នុងនោះមាន អាយុក្រោម ១៥ឆ្នាំ ៧០នាក់ អាយុ១៥-១៧ឆ្នាំ ៣១នាក់ និងពី ១៨ឆ្នាំឡើង ១៦២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ៧២នាក់ និងប្រគល់ទៅគ្រួសារ១ ៩១នាក់)។

ប្រទេសកម្ពុជា ត្រូវបានសហរដ្ឋអាមេរិកចេញរបាយការណ៍វាយតម្លៃឲ្យខ្លួនជាប់ចំណាត់ថ្នាក់លេខ២អស់រយៈពេលបីឆ្នាំជាប់ៗគ្នា ទាក់ទង និងអំពើជួញដូរមនុស្ស ដោយសហរដ្ឋអាមេរិកលើកឡើងថា មកពីកម្ពុជាមានភាពចន្លោះប្រហោងក្នុងការទប់ស្កាត់ និងបង្ក្រាបជាដើមនោះ។ យ៉ាងណាក៏ដោយលោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា របាយការណ៍របស់អាមេរិកនេះធ្វើឡើងមានលក្ខណៈលំអៀង ហើយពុំដែល បានសួរដល់ប្រទេសកម្ពុជា

មុននឹងចេញរបាយការណ៍នេះទេ ខណៈរាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការបង្ក្រាប និងទប់ស្កាត់ការជួញដូរមនុស្សបានយ៉ាងច្រើនជាបន្តបន្ទាប់នោះ៕

## ឆ្មក់ចូលបង្ក្រាបទីតាំងបម្រើសេវាផ្លូវភេទមួយកន្លែងចាប់ម្ចាស់ទីតាំង និងប្រមូលបាននារីបម្រើសេវា៤នាក់ ក្នុងនោះ មានអនីតិជនម្នាក់

http://peoplenews.asia ដោយៈ សុខ សាន្ត ថ្ងៃទី 06 ខែ09 ឆ្នាំ2020 ម៉ោង 11: 52 AM

ខេត្តសៀមរាបៈ ក្រុមមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសម្រុកចូលបន្ទប់ក្នុងហាងម៉ាស្សាស្រីពៅរកឃើញស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើប្រាស់ជាច្រើន និងរំដោះនារីបម្រើសេវាផ្លូវភេទ៤នាក់ ក្នុងនោះមានអនីតិជន អាយុ១៦ឆ្នាំម្នាក់ផងដែរ។ ការបង្ក្រាបនេះធ្វើឡើងនៅវេលាម៉ោង ១០យប់ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១០ ស្ថិតនៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប។

លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ខេត្តសៀមរាប បានឲ្យដឹងថា ករណីបង្ក្រាបការជួញដូរមនុស្សក្នុងហាងម៉ាស្សា ស្រពៅនេះ បុរសជាថៅកែហាងម៉ាស្សាម្នាក់ត្រូវឃាត់ខ្លួនបញ្ជូនទៅតុលាការ ក្រោមបទចោទអំពើសញ្ចារកម្ម។ លោកវរសេនីយ៍ឯក ជា ហេង បានឲ្យដឹងថា ជនសង្ស័យមានឈ្មោះ យិន ង៉ែត ភេទប្រុស អាយុ៤៩ឆ្នាំ ស្នាក់នៅហាងម៉ាស្សាខាងលើ។ លោកបន្តថា ក្នុងប្រតិបត្តិការនេះដឹកនាំសម្របសម្រួលនីតិវិធីដោយលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប។ ជនសង្ស័យម្ចាស់ហាងបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធី។ ចំណែកនារីបម្រើសេវាផ្លូវភេទទាំង៤នាក់ ជាជនរងគ្រោះប្រគល់ឲ្យមន្ទីរសង្គមកិច្ច ដើម្បីអប់រំណែនាំ។

## ប្រជាពលរដ្ឋខ្មែរចំនួន ០៣នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 06-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមរូវច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍ចំនួន ០៣នាក់ និងបានសហការជាមួយផ្នែកចត្តាឡីស័ក ធ្វើការអប់រំណែនាំ និងពិនិត្យកំដៅជូនពួកគាត់ រួចបានប្រគល់អ្នកទាំងបីនាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យ ចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន២៥០នាក់

https://www.facebook.com/GDIOfficial 06-09-2020

នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៥០នាក់ ស្រី ១២៥នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៦១នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 05-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦១នាក់ ស្រី ២៨នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់

https://www.facebook.com/GDIOfficial 05-09-2020

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៤៩នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៦៨នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 04-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦៨នាក់ ស្រី ២២នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០៦នាក់

https://www.facebook.com/GDIOfficial 04-09-2020

នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២០៦នាក់ ស្រី ៩៥នាក់៕

## ទាហានថៃ ដាក់ពង្រាយបន្លាលួស ៣ ជាន់ ទប់ស្កាត់ពលករខ្មែរ ដែលឆ្លងព្រំដែនខុសច្បាប់

http://www.arey-news.com/ (ថ្ងៃទី 06 September 2020 ម៉ោង 9:37 am)

ប្រទេសថៃ ៖ ខ្សែលួសបន្លាកំពស់៣ជាន់ត្រូវបានកម្លាំងយោធាថៃ ដាក់ពង្រាយយ៉ាងល្អិតល្អន់ ដោយមានបំពាក់តេឡេ សម្រាប់ផ្តល់ជាសម្លេងផងដែរនៅពេលដែលមានមនុស្ស ទៅប៉ះពាល់ វាដែលបន្លាលួសនេះត្រូវបានគេដាក់នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនខេត្តស្រះកែវជាមួយ និងព្រំដែនប្រទេសកម្ពុជាក្នុងរយៈចម្ងាយប្រមាណ១០គីឡូម៉ែត្រលើផ្ទៃដីរាបស្មើយោងតាមរបាយការណ៍ថៃបានបញ្ជាក់ថានៅរសៀលថ្ងៃទី៣ខែកញ្ញាឆ្នាំ ២០២០នេះនៅចំណុចឃុំប៉ារ៉ៃក្នុង ស្រុកអារញ្ញប្រាថេតខេត្តស្រះកែវប្រទេសថៃមានការចុះត្រួតពិនិត្យតាមបណ្តោយខ្សែបន្ទាត់ព្រំដែន ពីសំណាក់លោកត្រាផុងម៉ាឡៈខាំមេបញ្ជាការកងរយ១២០៥ ដែលក្នុងនោះមានយោធាឈុតខ្មៅលេខ១២ លេខ១៣ និងតម្រួតការពារព្រំដែនលេខ១២ផងដែរនៅត្រង់ចំណុចខាងលើ គឺក្រុមទាហានថៃ បានដាក់ពង្រាយខ្សែលួសបន្លាដែលមានកំពស់៣ជាន់និងមានប្រវែង១០គីឡូម៉ែត្រ ដែលរយៈចម្ងាយសរុបរវាងខ្សែបន្ទាត់ព្រំដែនខេត្តស្រះកែវជាមួយនិងព្រំដែនកម្ពុជា មានប្រវែង១៥៦ គីឡូម៉ែត្រ ឯផ្ទៃដីរាបស្មើគ្មានភ្នំនិងគ្មានអូរជាប់នឹងខ្សែ បន្ទាត់ព្រំដែនកម្ពុជាមានតែ១០គីឡូម៉ែត្រតែប៉ុណ្ណោះ។

លោកមេបញ្ជាការរូបនេះបានលើកឡើងថា ពលករខ្មែរដែលចូលទៅបម្រើការងារនៅក្នុងប្រទេស ថៃគឺមានចំនួនច្រើនហើយម៉្យាងទៀតនៅពេលដ៏ខ្លីខាងមុខនេះប្រទេសកម្ពុជា និងមានពិធីបុណ្យភ្ជុំស្របពេលដែលរដ្ឋមន្រ្តីថៃនិងកម្ពុជាសម្រេចបិទខ្សែបន្ទាត់ព្រំដែនជាបណ្តោះអាសន្ន ដោយសារតែរោគកូវីដ-១៩ កំពុងរាតត្បាតដូច្នេះទើបសមត្ថកិច្ចថៃចាប់ផ្តើម ដាក់ពង្រាយខ្សែលួសដើម្បីការពារការលបឆ្លងដែន ចេញចូលរបស់ពលករខ្មែរនាឱកាសបុណ្យភ្ជុំខាងមុខ ៕

## ជនជាតិវៀតណាមចំនួន ៣នាក់ ត្រូវបានចាប់ខ្លួន ពីបទរត់ពន្ធមនុស្សពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម

https://khmernote.com.kh/ September 4, 2020 lyda

ជនជាតិវៀតណាម ៣នាក់ ត្រូវបានចាប់ខ្លួនពីបទរត់ពន្ធមនុស្សពីប្រទេសកម្ពុជា ទៅកាន់ប្រទេសវៀតណាម តាមច្រកព្រំដែនខេត្តបិញភឿក (Bình Phước)។ កម្លាំងព្រំដែនវៀតណាមបានចាប់ខ្លួនបុរស ៣នាក់ ពីបទប្រតិបត្តិការក្រុមទំនើងមួយ ដើម្បីរត់ពន្ធមនុស្សពីប្រទេសកម្ពុជាចូលទៅប្រទេសវៀតណាម។ ឆ្នាំនៅច្រកទ្វារព្រំដែន

ហ៍រលួ ក្នុងខេត្តបិញភឿកភាគខាងត្បូង បានចាប់ខ្លួនបុរស ២នាក់ កាលពីរសៀលថ្ងៃអង្គារ ខណៈពួកគេកំពុងព្យាយាមរត់ពន្ធជនជាតិខ្មែរ ៣នាក់ ចូលមកប្រទេសវៀតណាម។

ជនទាំង ២ មានឈ្មោះថា Dao Duy Nhat អាយុ ២៩ ឆ្នាំ និង Dao Tuan Anh អាយុ ២៣ឆ្នាំ ដែលជាអ្នករស់នៅស្រុក Loc Ninh ខេត្តបិញភឿកបានអះអាងថា ពួកគេទទួលបានប្រាក់ចំនួន ៨០០,០០០ ដុង (៣៤ ដុល្លារ) សម្រាប់មនុស្សគ្រប់រូប ដែលពួកគេបានរត់ពន្ធចូលប្រទេសវៀតណាម។

ដោយធ្វើការរួមគ្នាជាមួយសមភាគីកម្ពុជា ក្រុមមន្ត្រីព្រំដែននិងប៉ូលីសបានតាមដានរឿងក្តីនេះ ហើយបានចាប់ខ្លួនមេក្លោងឈ្មោះ Tran Ngoc Duy អាយុ ២៨ឆ្នាំ ដែលជាអ្នកនៅ Loc Ninh ដូចគ្នា ពីក្នុងប្រទេសកម្ពុជាផងដែរ។ គួឱ្យដឹងដែរថា រហូតមកដល់ពេលនេះ ក្នុងឆ្នាំនេះ ឆ្មាំព្រំដែននៅខេត្តបិញភឿក បានចាប់ខ្លួនមនុស្សចំនួន ៥៣នាក់ ដែលប៉ុនប៉ងរត់ពន្ធមនុស្សចំនួន ១២១នាក់ ចូលមកប្រទេសវៀតណាម៕

## សមត្ថកិច្ចថៃដេញបង្ក្រាបរថយន្តលួចដឹកពលករខ្មែរខុសច្បាប់ក្រឡាប់របួសធ្ងន់ស្រាល ៨នាក់

http://peoplenews.asia ដោយ៖ ហេង រតនៈ ថ្ងៃទី 05 ខែកញ្ញា ឆ្នាំ2020 ម៉ោង 8 : 59 AM

ប្រទេសថៃ៖ ពលករខ្មែរចំនួន ០៨នាក់ ក្នុងនោះមានប្រុស ៥នាក់ និងស្រី ៣នាក់ ខណៈលួចឆ្លងដែនទៅរកការងារធ្វើនៅក្នុងប្រទេសថៃដោយខុសច្បាប់ត្រូវបានសមត្ថកិច្ចថៃ ស៊ើបដឹងថា មានឡានដឹកពលករខ្មែរ ទើបសមត្ថកិច្ចនាំគ្នាបើកដេញតាម បណ្តាលឲ្យក្រឡាប់រងរបួដធ្ងន់ស្រាលទាំង៨នាក់ ហើយអ្នកបើកបរជនជាតិថៃ បានរត់គេចចេញពីកន្លែងកើតហេតុបាត់ស្រមោល។ យោងការសែតថៃបានឲ្យដឹងថា ករណីនេះបានកើតឡើងកាលពីថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០២០ ខណៈកងកម្លាំងសមត្ថកិច្ចចម្រុះថៃចុះត្រួតពិនិត្យក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ ដើម្បីរឹតបន្តឹងការលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ក្នុងអំឡុងស្ថានការណ៍កូវីដ-១៩ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចាប់ពីទឹកដីស្រុកគោកឃ្សូង ដល់ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ សមត្ថកិច្ចបានសង្កេតឃើញរថយន្តអ៊ីស៊ុយហ្សុយឌីមេក ពណ៌ផ្ទៃមេឃ ពាក់ស្លាកលេខ ៩៩៣៨ ស្រះកែវ ១គ្រឿង មានលក្ខណៈផ្ទុកធ្ងន់ខុសធម្មតាសមត្ថកិច្ចក៏ផ្តល់សញ្ញាឲ្យចត តែអ្នកបើកបរខាងលើមិនព្រមចូលចត និងបានបង្កើនល្បឿនបើកគេចទៅផ្លូវភូមិគោកឡាន ឆ្ពោះទៅស្រុកវឌ្ឍនា ណៈខន ខេត្តស្រះកែវ។ សមត្ថកិច្ចបានបើករថយន្តដេញតាមពីក្រោយរហូតដល់វីសេតភូ កាដេន ភូមិគោកឡាន ឃុំគោកឡាន ស្រុក តាព្រះយ៉ា ខេត្តស្រះកែវ ត្រង់បង្គោលគីឡូម៉ែត្រ AT 481478 រថយន្តខាងលើបានរេចង្កូតធ្លាក់ផ្លូវ ដោយឡែកអ្នកបើកបរ បានបើកទ្វាររថយន្តរត់ចូលព្រៃបាត់ស្រមោល សមត្ថកិច្ចតាមមិនទាន់។

ក្រោយពីធ្វើការត្រួតពិនិត្យក្នុងរថយន្ត សមត្ថកិច្ចបានប្រទះឃើញមានពលករខ្មែរចំនួន៨នាក់ ក្នុងនោះមានប្រុស ៥នាក់ និងស្រី ៣នាក់។ យ៉ាងណាក៏ដោយបន្ទាប់ពីធ្វើការសួនាំជំហានដំបូងពលករខ្មែរទាំងអស់បានសារភាពថា ពួកគេចង់ធ្វើដំណើរទៅធ្វើការផ្សារថៃ បាងពូ និងព្រះរាម២ ទើបលួចចូលមកប្រទេសថៃតាមច្រករបៀងវាងចំណុចត្រួតពិនិត្យ ១៥-១៦ ភូមិខ្លងផែង ឃុំទ័ពស្តេច ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ដោយបានចំណាចលុយជួលអ្នកនាំផ្លូវឆ្លងដែន ក្នុងម្នាក់ ៣០០បាត និងចំណាយលុយឲ្យមេខ្យល់ក្នុងម្នាក់ ២៥០០បាត ដែលបានប្រគល់លុយឲ្យអ្នកបើកបររថយន្តរួចរាល់ហើយ។

បន្ទាប់មកសមត្ថកិច្ចក៏បានធ្វើកំណត់ហេតុឃាត់ខ្លួន រួចបញ្ជូនពលករទាំងអស់ទៅឲ្យសមត្ថកិច្ចជំនាញស្រុកព្រះយ៉ា ដើម្បីអនុវត្តតាមច្បាប់បន្ត។

## ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ ការដាក់ឲ្យកម្ពុជា ជាប់ចំណាត់ថ្នាក់លេខ២ រឿងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺជារឿងអយុត្តិធម៌បំផុតសម្រាប់កម្ពុជា

http://kampucheathmey.com/ 7/9/2020 4:33 Pm

**ភ្នំពេញ** ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស បានចាត់ទុកការដាក់ឲ្យកម្ពុជា ជាប់ចំណាត់ថ្នាក់លេខ២ រឿងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺជារឿងអយុត្តិធម៌បំផុតសម្រាប់កម្ពុជា។ ថ្លែងប្រាប់អ្នកយកព័ត៌មាន ក្រោយពីចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសសន្តប្រវេសន៍នៅព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០នេះ នៅ សណ្ឋាគារកាំបូឌីយ៉ាណា លោកស្រីបានបន្តថា«ខ្ញុំហាក់ដូចជាមិនអស់ចិត្ត និងកំពុងតែឆ្ងល់ចំពោះអាមេរិក ដែលបាន វាយតម្លៃដោយដាក់ចំណាត់ថ្នាក់លេខ២ដល់កម្ពុជា ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នេះខណៈរាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការប្រយុទ្ធប្រឆាំងការជួយដូរមនុស្ស ហើយរបាយការណ៍ដែលអាមេរិកបានដាក់ឲ្យកម្ពុជានេះ គឺមិនដឹងបានមកពីខាងណានោះទេ ខណៈរបាយការណ៍ដែលរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់នោះបែរគេចោទថា មានការចន្លោះប្រហោងច្រើនទៅវិញ »។

ប្រទេសកម្ពុជា ត្រូវបានសហរដ្ឋអាមេរិកចេញរបាយការណ៍វាយតម្លៃឲ្យជាប់ចំណាត់ថ្នាក់លេខ២អស់រយៈពេលបីឆ្នាំជាប់ៗគ្នា ទាក់ទងនិងអំពើជួញដូរមនុស្ស ដោយសហរដ្ឋអាមេរិកលើកឡើងថា មកពីកម្ពុជាមានភាពចន្លោះប្រហោង ក្នុងការទប់ស្កាត់ និងបង្ក្រាបជាដើមនោះ។ យ៉ាងណាក៏ដោយលោកស្រី ជូ ប៊ុនអេង បានលើកឡើងថា របាយការណ៍របស់អាមេរិកនេះ ធ្វើឡើងមានលក្ខណៈលំអៀង ហើយពុំដែល បានសួរដល់ប្រទេសកម្ពុជាមុននឹងចេញរបាយការណ៍នេះទេ ខណៈរាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការបង្ក្រាប និងទប់ស្កាត់ការជួញដូរមនុស្សបានយ៉ាងច្រើនជាបន្តបន្ទាប់នោះ។

បើយោងតាមរបាយការណ៍អំពីការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ បានបង្ហាញថា អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៧៨ករណី លើ ៦២ករណី (កើនឡើង១៦ករណី ស្មើនឹង២៥%)។ របាយការណ៍បានបញ្ជាក់បន្ថែមថា ដោយឡែកនៅ ក្នុងឆមាសទី១នេះ វិញអាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៩៧នាក់ លើ ៨៥នាក់ (កើន១២នាក់ ស្មើនឹង១៤%) ក្នុងនោះស្រី ២២នាក់ អនីតិជន ៩នាក់ ជាជនបរទេស ១៤នាក់ សញ្ជាតិចិន ១២នាក់ និងអាមេរិក ២នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ២៦៣នាក់ (លើ១០៦នាក់) កើន ១៥៧នាក់ ស្មើនឹង ១៤៨% ក្នុងនោះមានអាយុក្រោម ១៥ឆ្នាំ ៧០នាក់ អាយុ១៥-១៧ឆ្នាំ ៣១នាក់ និងពី ១៨ឆ្នាំឡើង ១៦២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ៧២នាក់ និងប្រគល់ទៅគ្រួសារ១ ៩១នាក់)៕

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ចំនួន ០៦អង្គការ

https://www.facebook.com/ 07-09-2020 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ទីស្តីការក្រសួង៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ចំនួន ០៦អង្គការ រួមមាន៖ អង្គការស្ពាន អង្គការគ្រិតភីសកម្ពុជា អង្គការម្លប់តាប៉ាង អង្គ

ការបម្រើកម្ពុជា អង្គការសាម៉ារីតាន់គីសសង្គ្រោះអន្តរជាតិ និងអង្គការ DAIL COMMUNITY ដើម្បីជួយក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយផ្ដោតសំខាន់លើវិស័យសុខុមាលភាពសង្គម សុខុមាលភាពកុមារ និងប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។

ពិធីចុះហត្ថលេខានៃកិច្ចព្រមព្រៀង (MoU) នាពេលនេះបានរៀបចំឡើងជាផ្លូវការ នារសៀលថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាពឯកឧត្តម តូច ចាន់នី អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការរួមពីថ្នាក់ដឹកនាំក្រសួ ងនិងថ្នាក់ដឹកនាំអង្គការស្ពាន អង្គការគ្រិតគីសកម្ពុជា អង្គការម្លប់តាប៉ាង អង្គការបម្រើកម្ពុជា អង្គការសាម៉ារីតាន់គីសសង្គ្រោះអន្តរជាតិ និងអង្គការ DAIL COMMUNITY រួមនឹងមន្ត្រីរាជការពាក់ព័ន្ធ របស់ក្រសួងសង្គមកិច្ចជាច្រើនរូបទៀតផងដែរ។

នៅក្នុងឱកាសនោះ ឯកឧត្តម តូច ចាន់នី បានលើកឡើងថា ការចូលរួមសហការរបស់អង្គការដៃគូ ពិតជាសំខាន់ខ្លាំងណាស់ ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ បន្ថែមពីលើនោះ ឯកឧត្តម តូច ចាន់នី បានស្នើឲ្យក្រុមការងារក្រសួង និងអង្គការដែលសហការនាពេលនេះរួមគ្នា ដើម្បីធ្វើការងារ ដោយយកចិត្តទុកដាក់ឲ្យខ្លាំងបំផុត តាមដែលអាចធ្វើបាន។ សម្រាប់ក្រសួងសង្គមកិច្ចវិញ នៅតែស្វាគមន៍ជានិច្ចជាមួយ ដៃគូពាក់ព័ន្ធ និងអង្គការនានា ដើម្បីជួយដល់វិស័យសុខុមាលភាពសង្គម សុខុមាលភាពកុមារ និងប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះនៅកម្ពុជា ឲ្យមានជីវភាព និងជីវិតរស់នៅ ល្អប្រសើរថែមមួយកម្រិតទៀត។

គួរបញ្ជាក់ថា អង្គការឆាលហ្វាន់ ដែលបានចុះហត្ថលេខា លើកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាពេលនេះ សុទ្ធសឹងតែដែលបានចូលរួមចំណែកជួយការពារកុមាររងគ្រោះពីការជួញដូរមនុស្ស ករណីកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្មកុមារស្នាក់ក្នុងមណ្ឌល កុមារនៅតាមសហគមន៍ កុមារទំនាស់នឹងច្បាប់ កុមារតាមផ្លូវសាធារណៈជាដើម។ ជាមួយគ្នានោះ ឯកឧត្តម តូច ចាន់នី បានក្រើនរំលឹកដល់អង្គការស្ពាន អង្គការគ្រិតគីសកម្ពុជា អង្គការម្លប់តាប៉ាង អង្គការបម្រើកម្ពុជា អង្គការសាម៉ារីតាន់គីសសង្គ្រោះអន្តរជាតិ និងអង្គការ DAIL COMMUNITY ដែលបានចុះកិច្ចព្រមព្រៀង (MOU) នាពេលនេះ សូមបន្តអនុវត្ត វិធីការពារជំងឺកូវីដ-១៩ តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសុខាភិបាល និងសេចក្ដីណែនាំរបស់ក្រសួងសង្គមកិច្ច កន្លងមក៕

## នាយឧត្តមសេនីយ៍ នេត សាវឿន ៖ ត្រូវរឹតបន្តឹងសភាពការណ៍ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ទប់ស្កាត់បទល្មើសរត់ពន្ធគ្រឿងញៀន និងការលួចឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ដើម្បីទៅធ្វើការនៅប្រទេសថៃ

https://www.cen.com.kh/ September 8, 2020

បន្ទាយមានជ័យ ៖ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានណែនាំឲ្យ ស្នងការដែលទើបទទួលតំណែងថ្មី ត្រូវរឹតបន្តឹងសភាពការណ៍នៅតាមបន្ទាត់ព្រំដែន ដោយត្រូវសហការជាមួយភាគីថៃ ទប់ស្កាត់ឲ្យបានរាល់បទល្មើស រត់ពន្ធគ្រឿងញៀន បង្ក្រាបឲ្យបានកុំឲ្យមានការហូរចូលមកទឹកដីកម្ពុជា និង ទប់ស្កាត់ការរត់ពន្ធទំនិញខុសច្បាប់ផ្សេងៗ ការលួចឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ដើម្បីទៅធ្វើការនៅប្រទេសថៃ។

នៅព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០នេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតី ពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយ

មានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ។ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ មានប្រសាសន៍ ក្នុងពិធីតែងតាំងថា ដើម្បីរក្សាបាននូវសន្តិសុខ និងសុវត្ថិភាពជូនប្រជាពលរដ្ឋ ស្នងការដែលទើបទទួលតំណែងថ្មី ត្រូវរឹតបន្តឹងសភាពការណ៍នៅតាមបន្ទាត់ព្រំដែន ដោយត្រូវសហការជាមួយភាគីថៃ ទប់ស្កាត់ឲ្យបានរាល់បទល្មើសផ្សេងៗតាមបន្ទាត់ព្រំដែន ពិសេសករណីរត់ពន្ធគ្រឿងញៀន ដែលលជាចំណុចមួយដែលសមត្ថកិច្ចត្រូវធ្វើការ ទប់ស្កាត់ បង្ក្រាបឲ្យបានកុំឲ្យមានការហូរចូលមកទឹកដីកម្ពុជា នឹងត្រូវបន្តក្តាប់ឲ្យបាននូវសភាពការតាមព្រំដែន ទប់ស្កាត់ការរត់ពន្ធទំនិញខុសច្បាប់ផ្សេងៗ ពិសេសការលួចឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ដើម្បីទៅធ្វើការនៅប្រទេសថៃ ត្រូវរួមចំណែក។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានជំរុញអោយស្នងការដែលតែងតាំងថ្មីត្រូវចាត់ទុកខេត្តបន្ទាយមានជ័យ ជាខេត្តគំរូមួយ ទាំងការអនុវត្តវិន័យ ទាំងកងកម្លាំងអន្តរាគមន៍ ការចល័តទ័ព និងមធ្យោបាយប្រើប្រាស់ ជាពិសេសកម្លាំងនគរបាលខេត្តបន្ទាយមានជ័យ ជាគំរូល្អមួយក្នុងការចុះជួយប្រជាពលរដ្ឋនៅពេលមានគ្រោះអាសន្នអន់ក្រ ដូចជាខ្យល់ព្យុះ ទឹកជំនន់ ប្រក់ផ្ទះ លើកផ្ទះ ជួយប្រូតស្រូវក្នុងទឹកផងដែរ។ ឯកឧត្តមអគ្គស្នងការនគរបាលជាតិ បានមានប្រសាសន៍បន្ថែមអោយដឹងទៀតថា ជោគជ័យទាំងអស់ត្រូវតែមានការសហការជាមួយអាជ្ញាធរគ្រប់ជាន់ថ្នាក់ ហើយថែមទាំងមានការចូលរួមពីប្រជាពលរដ្ឋផងដែរ។ ឯកឧត្តមអគ្គស្នងការនគរបាលជាតិ ក៏បានជម្រុញអោយស្នងការថ្មីត្រូវចេះព្យាករណ៍នូវសភាពការដែលកើតមានឡើងនៅពេលខាងមុខ ជាពិសេសពួកឧទ្ទាមអមិត្តមិន ដែលបោះបង់បំណងបំផ្លាញរាជរដ្ឋាភិបាលស្របច្បាប់ ដឹកនាំឲ្យមានបាតុកម្ម ជាពិសេសគឺមិនអនុញ្ញាតអោយជនទាំងនោះមកបំផ្លាញសេចក្តីសុខប្រជាពល រដ្ឋនោះឡើយ។

ក្នុងនាមជាស្នងការថ្មីត្រូវជួយដោះស្រាយទុកកង្វល់របស់ប្រជាពលរដ្ឋ អ្វីដែលជាទុក្ខព្រួយរបស់ប្រជាពលរដ្ឋករណីបទល្មើស លួច ឆក់ ប្លន់នៅក្នុងមូលដ្ឋាន ត្រូវតែអនុវត្តនូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ជួយទប់ស្កាត់បញ្ហាគ្រឿងញៀន ទប់ស្កាត់កុំអោយមានការរីករាលដាល ជាពិសេសខេត្តនៅជាប់ព្រំដែនផងនោះ ត្រូវជួយដោះស្រាយសំដៅកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍ ដែលជាក្តីកង្វល់របស់ប្រជាពលរដ្ឋ ត្រូវជួយផ្សព្វផ្សាយអប់រំច្បាប់ និងអប់រំដល់អ្នកដែលកាន់ចង្កូតផ្ទាល់ ដើម្បីឲ្យពួកគាត់បានយល់រួមចំណែកក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

ជាចុងក្រោយ ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន បានផ្តាំផ្ញើឲ្យស្នងការថ្មីចំនួន៥ចំណុច ដើម្បីអនុវត្តក្នុងតួនាទីភារកិច្ចទទួលបានជោគជ័យ៖

ទី១-ស្នងការថ្មីត្រូវពង្រឹងតួនាទីដឹកនាំដោយផ្សារភ្ជាប់ និង៣បញ្ហា ត្រូវទទួលខុសត្រូវខ្ពស់ជាងគេ ត្រូវចាត់ទុកខ្លួនឯងជាអាណាព្យាបាល ជាអ្នកដឹកនាំត្រូវកសាងមនោសញ្ចេតនាក្នុងអង្គភាព ចុះសាកសួរសុខទុក្ខនៅពេលមានមន្ត្រីឈឺស្កាត់ អនុវត្តតាមសមាគមមិត្តនគរបាល ត្រូវធ្វើជាគំរូគេក្នុងការបំពេញភារកិច្ច ប្រចាំការ ប្រចាំបញ្ជាចុះជាប់ជាប្រចាំជាមួយបងប្អូន។

ទី២-ត្រូវធ្វើជាសេនាធិការគ្រប់ជ្រុងជ្រោយដល់គណៈបញ្ជាការឯកភាព ដើម្បីបំពេញការងារ សំដៅការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋក្នុងខេត្តទាំងមូល។

ទី៣-ត្រូវជួយលើកកម្ពស់សេវាចាំបាច់ដើម្បីបំរើជូនប្រជាពលរដ្ឋ ការបំពេញលិខិតស្នាមរដ្ឋបាល និងធ្វើកិច្ចការដោយស្មោះត្រង់ដោយឥតលក្ខខណ្ឌ និងទទួលខុសត្រូវ មិនកោសរូសចាត់ទុកប្រជាពលរដ្ឋជាឪពុកម្តាយ។

ទី៤-ពង្រឹងគុណភាពស្នងការ និងមន្ត្រីនគរបាលទាំងអស់ ក្នុងនាមជាកងកម្លាំងត្រូវមានសមត្ថភាព វិន័យគុណធម៌ សីលធម៌សូមអោយយកចិត្តទុកដាក់បំប៉នការរៀនសូត្រ។

ទី៥-ត្រូវពង្រឹងសាមគ្គីភាព សហការ ការហ្មឹកហាត់ ក្រោមដំបូលរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ត្រូវរួមរួមគ្នា ដើម្បីទទួលបានភាពជោគជ័យ ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។

ទន្ទឹមនឹងនោះ ដើម្បីរក្សាបាននូវសន្តិសុខ សណ្តាប់ ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការដ្ឋាននគរបាលជាតិ បានណែនាំអោយអាជ្ញាធរត្រូវចាត់កម្លាំងយាមកាម ឲ្យបានល្អប្រសើរ ដើម្បីធានារក្សាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់ជូនពលរដ្ឋ ភ្ញៀវជាតិ- អន្តរជាតិ នៅតាមគោលដៅទីវត្តអារាម តាមផ្លូវជាតិ តំបន់ទេសចរណ៍ និងរមណីដ្ឋាននានា និងត្រូវប្រកាន់ភ្ជាប់នៅវិធានការអនាម័យ ឲ្យបានខ្ជាប់ខ្ជួន តាមការណែនាំរបស់ក្រសួងសុខាភិបាល។

សូមជម្រាបថា លោកឧត្តមសេនីយ៍ត្រី សិទ្ធិ ឡោះ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ ត្រូវបានតែងតាំងជាស្នងការថ្មី នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ជំនួសលោកឧត្តមសេនីយ៍ទោ អាត់ ខែម ដែលត្រូវបានដាក់អោយចូលនិវត្តន៍ និងត្រូវបានតែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃ៕ **ដោយៈកូឡាប**

## ថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់ ក្រោយជាប់ពន្ធនាគារ ជិត៣ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូង

http://www.freshnewsasia.com/ 2020-09-07 07:00pm

**(ឧត្តរមានជ័យ)៖** ប្រជាពលរដ្ឋខ្មែរម្នាក់ទៀត ត្រូវបានអាជ្ញាធរប្រទេសថៃ បញ្ជូនខ្លួនត្រលប់មកកម្ពុជាវិញ តាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ នៅល្ងាចថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០នេះ ក្រោយជាប់ពន្ធនាគារជិត៣ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់ ដើម្បីកាប់ឈើគ្រញូង។

បើតាមរបាយការណ៍របស់សមត្ថកិច្ច បានបញ្ជាក់ថា នៅវេលាម៉ោង០៤៖៤៩នាទី ល្ងាចថ្ងៃនេះ អាជ្ញាធរថៃ បានបញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរម្នាក់មានឈ្មោះ រឿន រ៉ា ភេទប្រុស អាយុ៣៤ឆ្នាំ រស់នៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ត្រូវបានទាហានថៃចាប់ខ្លួនយកទៅឃុំឃាំង នៅខេត្តសុរិន្ទ អស់រយៈពេល២ឆ្នាំ ១១ខែ ១៧ថ្ងៃ ពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូង តាមច្រកអូរខ្លាឃ្មុំ។ បន្ទាប់ពីបានអប់រំណែនាំឱ្យបញ្ឈប់សកម្មភាពឆ្លងដែនខុសច្បាប់ ស្កែនកំដៅរកជំងឺកូវីដ-១៩ និងលាងសម្អាតខ្លួនប្រាណដោយទឹកអាល់កុលរួចមក សមត្ថកិច្ចបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៦៤នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 07-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦៤នាក់ ស្រី ២៤នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២២០នាក់

https://www.facebook.com/GDIOfficial 07-09-2020

នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២២០នាក់ ស្រី ៩៣នាក់៕

## អាជ្ញាធរថៃចាប់ខ្លួនពលករកម្ពុជា ១៣នាក់ ព្យាយាមឆ្លងដែនខុសច្បាប់ត្រលប់មកប្រទេសកម្ពុជាវិញ ដោយសារខ្លាចឆ្លងជំងឺកូវីដ១៩ នៅថៃ

https://khmernote.com.kh/ September 7, 2020 Iyda

ថៃ៖ យោងតាមសារព័ត៌មាន Bangkok Post បានរាយករណ៍ថា មានពលករជនជាតិកម្ពុជាចំនួន ១៣ រូបត្រូវបានចាប់ខ្លួននៅឯច្រកព្រំដែនបន្ទាប់ពីពួកគេព្យាយាមឆ្លងដែនពីប្រទេសថៃត្រលប់មកកាន់កម្ពុជាវិញ កាលពីថ្ងៃអាទិត្យ ទី០៦ ខែកញ្ញា ឆ្នាំ២០២០។ ប្រភពខាងលើបានបន្តថា ការចាប់ខ្លួននេះត្រូវបានធ្វើឡើងនៅច្រកព្រំដែនក្នុងខេត្តសាកែវ ប្រទេសថៃ ដែលមានព្រំប្រទល់ជាប់នឹងខេត្តបន្ទាយមានជ័យប្រទេសកម្ពុជា។ យ៉ាងណាក្តី បន្ទាប់ពីទីក្រុងបាងកកមានផ្ទុះករណីរាតត្បាតជំងឺកូវីដ ១៩ ដែលជារលកទី ២ នោះ ពលករទាំងអស់នេះក៏មានការភ័យខ្លាចហើយក៏នាំគ្នាត្រលប់មកកាន់ប្រទេសកម្ពុជាវិញ។ ក្នុងដំណើរវិលត្រលប់មកកាន់ប្រទេសកំណើតវិញនេះ ពួកគេបានចែកគ្នាជា ៣ក្រុម ហើយពួកគេបានព្យាយាមដើរគេចចេញពីច្រកដែលមានការត្រួតពិនិត្យ ទើបត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ សូមបញ្ជាក់ជូនថា ករណីនេះមិនមែនជារឿងថ្មីឡើយ ព្រោះកន្លងមកមានពលរដ្ឋកម្ពុជាជាច្រើននាក់ដែលបានចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ ហើយត្រូវអាជ្ញាធរចាប់ខ្លួននិងបញ្ជូនមកប្រទេសកម្ពុជាវិញ៕

អត្ថបទ៖ ភក្តី ប្រភព៖ Bangkok Post

# ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

## ថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច ចុះពិនិត្យទីតាំងសាងសង់ និងជួសជុលអគារមណ្ឌលទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ

http://kampucheathmey.com/ 8/9/2020 6:10 Pm

កណ្តាល ៖ ក្រោយពីមានការគិតគូររបស់រាជរដ្ឋាភិបាល និងសាមីក្រសួង ព្រមទាំងអង្គការសប្បុរសធម៌នានារួចមកលោកញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានដឹងនាំក្រុមការងារចុះពិនិត្យទីតាំងសម្រាប់សាងសង់ និងជួសជុលអគារមណ្ឌលទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទឲ្យស្នាក់នៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលវែង ដែលមានទីតាំងស្ថិតនៅឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលនាថ្ងៃទី ០៨ កញ្ញា ឆ្នាំ២០២០។

ថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាលោកញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ បានថ្លែងនូវការអរគុណ និងគាំទ្រសកម្មភាពមនុស្សធម៌របស់អង្គការនានាពិសេសសាមីក្រសួង និងរាជរដ្ឋាភិបាល ដែលតែងតែជួយទំនប់បម្រុងដល់កុមារនៅកម្ពុជា ពិសេសនៅខេត្តកណ្តាល។ ក្នុងនាមក្រសួងសង្គមកិច្ចលោក ញ៉ឹក វណ្ណារ៉ា បានថ្លែងថា ប្រាកដណាស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានគិតគូរខ្ពស់ដល់ពលរដ្ឋក្រីក្រជនពិការ កុមារ ដោយមិនឲ្យពួកគេនៅឯកោនោះឡើយ គឺរាជរដ្ឋាភិបាលក៏ដូចថ្នាក់ដឹកនាំក្រសួងបានសម្របសម្រួលឲ្យជនពិការភាព ជនក្រីក្រ និងកុមារទទួលបានការគាំទ្រនានាសំដៅដល់ការលើកកម្ពស់ជីវភាពរបស់ជនពិការភាព ជនក្រីក្រ កុមារតែម្តងដែលពួកគេត្រូវជំនួយចាំបាច់បំផុត។ នេះជាការគិតគូរខ្ពស់របស់សម្តេចតេជោនិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ានី ហ៊ុន សែន ដែលជានិច្ចកាលសម្តេចទាំងទ្វេតែងតែយកចិត្តទុក្ខដាក់ និងព្រួយបារម្ភបំផុតពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងកុមារនៅទូទាំងប្រទេសជាធំពិសេសបងប្អូនពលរដ្ឋទីទាល់ក្រ និងជនងាយរងគ្រោះតែម្តងដែលជួបផលប៉ះពាល់ធ្ងន់ធ្ងរដោយជំងឺរាតត្បាតកូវីដ ១៩ ដ៏កាចសាហាវនេះ។

គួរបញ្ជាក់ថា កាលព្រឹកថ្ងៃទី២៦ សីហា ឆ្នាំ២០២០ កន្លងទៅនេះលោកញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលជួបពិភាក្សាការងារជាមួយអង្គការ Samaritan នៅទីស្តីការក្រសួង។ ខ្លឹមសារសំខាន់ក្នុងជួបពិភាក្សាការងារជាមួយអង្គការ Samaritan នោះគឺសិក្សាលើលទ្ធភាពសាងសង់ឬជួសជុលអគារមណ្ឌល សម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទឲ្យស្នាក់នៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលវែង ដែលមានទីតាំងស្ថិតនៅឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ លោករដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានថ្លែងអរគុណចំពោះសប្បុរសជននានាក៏ដូចអង្គការអង្គការ Samaritan ដែលតែងតែចូលរួមជាមួយក្រសួងសង្គមកិច្ចនិងរាជរដ្ឋាភិបាលក្នុងការផ្តល់អំណោយដល់កុមារជារៀងរហូត ក៏ដូចការគិតគូរសុខទុក្ខកុមារគ្រប់ពេលវេលាទើបមកដល់ថ្ងៃនេះ លោកក៏បានដឹកនាំក្រុមការងារចុះពិនិត្យទីតាំង ដើម្បីសាងសង់អាគារទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ៕ វិមាន

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៣នាក់

https://www.facebook.com/GDIOfficial 08-09-2020

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៣នាក់ ស្រី ៤៩នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន០៣នាក់ ពីសមត្ថកិច្ច ថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 08-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១. ឈ្មោះ ហាវ ខាវ ភេទ ស្រី អាយុ ៣៩ឆ្នាំ, ២. ឈ្មោះ ចាន់ ភារះ ភេទប្រុស អាយុ ០៩ឆ្នាំ មានទីលំនៅភូមិត្រពាំងលាន ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ, ៣. ឈ្មោះ សុវណ្ណ ចាន់ ភេទស្រី អាយុ ២៤ឆ្នាំ មានទីលំនៅភូមិដូង ឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូល រួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយ ឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នក បើកបរយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំង ភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៨នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 08-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្ម តា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៨នាក់ ស្រី ១៨នាក់ និង កុមារ ០៧នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថា ប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅ លំនៅដ្ឋានរៀងៗខ្លួន៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារបរព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ

https://www.facebook.com/GDIOfficial 08-09-2020

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាល ច្រកទ្វារបព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកតាថាវ ខេត្ត ព្រះវិហារ៕

## ដើរកាត់ព្រៃផង ជិះម៉ូតូឌុបផង ទំរាំដល់តាក់ស៊ី ទីបំផុតនៅតែគេចមិនរួចដដែល

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២០ ម៉ោង ១០:១៤ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពិតជាគួរឲ្យអាណិតណាស់ បើមើលតាមការរៀបរាប់លើគេហទំព័រ និងកាសែតថៃ មួយ ដែលបានបង្ហោះ ឬផ្សាយថា ពលករខ្មែរចំនួន៩នាក់ត្រូវសមត្ថកិច្ចចម្រុះថៃចាប់ខ្លួនតាមដងផ្លូវ ខណៈពេល កំពុងជិះតាក់ស៊ី ក្រោយពីដើរកាត់ព្រៃផង ជិះម៉ូតូឌុបផង ទម្រាំតែដល់គោលដៅ រួចចង់ជិះរថយន្តតាក់ស៊ីទៅហើយ

ប៉ុន្តែទីបំផុតនៅតែត្រូវគេចាប់ខ្លួនបានដដែល។ ករណីឃាត់រថយន្តតាក់ស៊ី២គ្រឿង និងឃាត់បានពលករខ្មែរ៩នាក់ខាងលើនេះ បានកើតឡើងកាលពីម៉ោង៤និង៣០នាទីព្រឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០ ស្ថិតនៅក្នុងស្រុកតាប្រយ៉ា ខេត្តស្រះកែវ។

ពាក់ព័ន្ធករណីខាងលើនេះ គេនៅមិនទាន់ស្គាល់អត្តសញ្ញាណពលករខ្មែរទាំង៩នាក់នៅឡើយទេ គ្រាន់តែដឹងថា ក្នុងនោះមានប្រុស៥នាក់ និងស្រីចំនួន៤នាក់ ។ ហើយពេលសាកសួរនោះ ក្រុមពលករខ្មែរទាំង៩នាក់បានប្រាប់សមត្ថកិច្ចថៃថា មុនពេលឡើងជិះរថយន្តតាក់ស៊ីនោះ គឺត្រូវចំណាយប្រាក់២ដងរួចមកហើយ ដោយលើកទី១ចំណាយម្នាក់៩០០បាតឲ្យមេខ្យល់ខ្មែរនាំដើរកាត់ព្រៃពីព្រំដែនចូលទឹកដីថៃ លុះលើកទី២ គឺជិះម៉ូតូឌុបរបស់ថៃដោយចំណាយម្នាក់៥០០បាត និងលើកទី៣ ចំណាយម្នាក់១៨០០បាតទៀត លើរថយន្តតាក់ស៊ី សរុបទាំងអស់៣២០០បាត ក្នុងគោលដៅទៅរកការងារធ្វើនៅខេត្តនគររាជសីមា និងខេត្តសមុទ្រប្រាកាន តែមិនទាន់ទាំងទៅដល់ផង ក៏ត្រូវគេចាប់ខ្លួនទាំងអស់គ្នា រួមទាំងអ្នកបើកបររថយន្តស្លាកលេខថៃ និងជាជនជាតិថៃប្រុស២នាក់ទៀតផង។ ក្រោយពេលចាប់ខ្លួន ទាំងពលករខ្មែរ ទាំងបុរសជនជាតិថៃ ត្រូវបានគេបញ្ជូនទៅស្ថានីយតម្រួតស្រុកតាប្រយ៉ាដើម្បីធ្វើកាសាសួរ និងចាត់ការបន្តទៀត៕

## ទី១០ ខែកញ្ញា ឆ្នាំ២០២០

### ១ថ្ងៃពលរដ្ឋខ្មែរជិត៦០០នាក់ ត្រឡប់ពីថៃតាមច្រកអូរបីជាន់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២០ ម៉ោង ១៨:២៥ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ តាមតួលេខដែលទទួលបានបង្ហាញថា ពលរដ្ឋក្នុង១ថ្ងៃពលរដ្ឋខ្មែរជិត៦០០នាក់បានត្រឡប់ពីថៃតាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ជាមួយនេះដែរ លោកអភិបាលខេត្តសុំស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ជួយម៉ាស៊ីបាញ់ថ្នាំសម្លាប់កូវីឌ ក្នុងឱកាសជួបសំណេះសំណាជាមួយអង្គការទេសន្តរប្រវេសន៍ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ មានប្រសាសន៍កោតសសើរចំពោះដំណើរទស្សនកិច្ចរបស់អង្គការទេសន្តរប្រវេសន៍ (IOM) សហការជាមួយស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ដែលមកជួបសំណេះសំណាលដើម្បីសិក្សាស្វែងយល់អំពីការងារទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ១៩ នៅតាមបន្ទាត់ព្រំដែនជាមួយពលករកម្ពុជាដែលវិលត្រឡប់មកពីប្រទេសថៃ ។ ឯកឧត្តមបានបញ្ជាក់ថា នៅអំឡុងថ្ងៃបុណ្យភ្ជុំបិណ្ឌប្រពៃណីព្រះពុទ្ធសាសនាខ្មែរ ឃើញមានពលរដ្ឋខ្មែរជាង៦០០នាក់ ជារៀងរាល់ថ្ងៃ បានចូលមកតាមច្រកព្រំដែនអូរបីជាន់ក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ ត្រូវបានធ្វើការពិនិត្យ(ចត្តាឡីស័ក)ហើយណែនាំដល់ពួកគាត់ចូលរួមបង្ការ និងទប់ស្កាត់កូវីដ១៩ នៅពេលដែលប្រទេសជិតខាងកំពុងយកចិត្តទុកដាក់បង្ការ និងទប់ស្កាត់ដូចគ្នា។ ឯកឧត្តមអភិបាលខេត្តបានបញ្ជាក់ថា ខេត្តបន្ទាយមានជ័យមានព្រំដែនជាប់កម្ពុជា-ថៃប្រវែង១៥៣គីឡូម៉ែត្រ ហើយមានច្រកទ្វេភាគីចំនួន៣កន្លែង និងច្រកអន្តរជាតិប៉ោយប៉ែត១-ចំណែកច្រកតំបន់មាន បឹងត្រកួន ស្រុកថ្មពួក ច្រកតំបន់ព្រំដែនម៉ាឡៃ ស្រុកម៉ាឡៃ ហើយច្រកដែលប្រជាពលរដ្ឋចូលមកកម្ពុជាមានច្រករបៀងអូរបីជាន់ ស្រុកអូរជ្រៅ និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។

លោកស្រី គ្រីស្ទីន ផាកូ ប្រធានអង្គការ (IOM)បានមានប្រសាសន៍ថា ក្រោយដំណើរទស្សនកិច្ចអង្គការទេសន្តរប្រវេសន៍(IOM)សហការជាមួយស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ដែលជួបសំណេះសំណាល ដើម្បីសិក្សាស្វែងយល់អំពីការងារទប់ស្កាត់ ការរាលដាលនៃជំងឺកូវីដ១៩ នៅតាមបន្ទាត់ព្រំដែនជាមួយពលករកម្ពុជា ដែលវិលត្រឡប់មកពីប្រទេសថៃ កោតសរសើរចំពោះអភិបាលខេត្ត និងមន្ត្រីជំនាញដែលបានយកចិត្តទុកដាក់ ។

លោកឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជាបានបញ្ជាក់ថា អ្វីដែលជាការស្នើសុំពីអភិបាលខេត្ត ឯកឧត្តម អ៊ុំ រាត្រី គឺឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា និងអង្គការទេសន្តរប្រវេសន៍ (IOM) គ្រោងពិភាក្សា និងធ្វើគម្រោងស្នើសុំ ដើម្បីផ្តល់ម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគកូវីដ១៩ សម្រាប់ពលរដ្ឋកម្ពុជាដែលមកពីប្រទេសថៃ គឺជាវិធីការពារទប់ស្កាត់កូវីដ១៩ដ៏ល្អ ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៨នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 09-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២៥នាក់ ស្រី ០៥នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៣នាក់

https://www.facebook.com/GDIOfficial 09-09-2020

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៣នាក់ ស្រី ៩៦នាក់៕

## អ្នកទោសម្នាក់ត្រូវអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពឡើងវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២០ ម៉ោង ១៥:៤១ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរម្នាក់ត្រូវបានក្រុមអាជ្ញាធរថៃធ្វើការដោះលែងឲ្យមានសេរីភាពវិញ និងបញ្ជូនយកមកប្រគល់ឲ្យក្រុមអាជ្ញាធរកម្ពុជាតាមច្រកទ្វារអន្តរជាតិអូរស្មាច់កាលពីវេលាម៉ោង៨រសៀលថ្ងៃទី៧ កញ្ញា ឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

អ្នកទោសម្នាក់ដែលក្រុមអាជ្ញាធរថៃដោះលែងឲ្យមានសេរីភាពឡើងវិញឈ្មោះរឿន រ៉ា ភេទប្រុស អាយុ៣៤ ឆ្នាំ រស់នៅភូមិសង្កាត់ខាងលើ បានជាប់ពន្ធនាគារនៅខេត្តសុរិន្ទ ប្រទេសថៃ ហើយត្រូវអាជ្ញាធរថៃចាប់ខ្លួនកាលពីថ្ងៃទី២៤ កញ្ញា ឆ្នាំ២០១៧ ពីបទឆ្លងដែនចូលកាប់ឈើគ្រញូងក្នុងដីថៃ ចូលតាមច្រកអូរខ្លាឃ្មុំ ស្ថិតក្នុងភូមិសាស្រ្តភូមិអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

មន្ត្រីបម្រើការងារនៅច្រកទ្វារអន្តរជាតិអូរស្មាច់បានឲ្យដឹងថា អ្នកទោសម្នាក់ដែលក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនយកមកប្រគល់ឲ្យកម្ពុជា ខាងសមត្ថកិច្ចកម្ពុជាបានធ្វើការអប់រំ និងឲ្យធ្វើកិច្ចសន្យារួចឲ្យវិលត្រឡប់ទៅជួបជុំប្រពន្ធកូនក្នុងថ្ងៃដដែល។ គួររំលឹកថា ក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនអ្នកទោសពីបទឆ្លងដែនកាប់ឈើគ្រញូងនេះមែនជាលើកទីមួយទេកន្លងមកបញ្ជូនជាបន្តបន្ទាប់ផងដែរ៕ សារឿន

## ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

### អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០៦នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial/ 10-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៦នាក់ ស្រី ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរអាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

### ប្រជាពលរដ្ឋខ្មែរចំនួន ៨១នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial/ 10-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៨១នាក់ ស្រី ៣៤នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១៩នាក់

https://www.facebook.com/GDIOfficial/ 10-09-2020

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១៩នាក់ ស្រី ១០០នាក់៕

## ពលករខ្មែរមិនអោយគេជិះជាន់ស្រេចចិត្តទេ បាននាំគ្នាសម្រុកទៅប្ដឹងប៉ូលីសរឿងកាត់លុយ

https://www.facebook.com/CambodianWorkerInThailand/ ១០.០៩.២០២០ ពីខ្ញុំពលករខ្មែរនៅថៃ

នៅល្ងាចថ្ងៃព្រហស្បតិ៍ទី១០ ខែកញ្ញា ឆ្នាំ២០២០ នៅមុខស្ថានីយតម្រួតប៉ុស្តិ៍ផានថងខេត្តរ៉ាក់យ៉ងប្រទេសថៃ ក្រុមពលករខ្មែរចំនួន៤០០នាក់ ធ្វើការ នៅក្រុមហ៊ុនក្នុងតំបន់ឧស្សាហកម្ម ខេត្តរ៉ាក់យ៉ង នាំគ្នាទៅប្ដឹងប៉ូលីសប៉ុស្តិ៍ផានថងខេត្តរ៉ាក់យ៉ង បន្ទាប់ពីត្រូវថៅកែកាត់លុយថ្លៃធ្វើវីសាចំនួន១ម៉ឺន៥ពាន់បាត រយៈពេលជាងមួយឆ្នាំហើយនៅមិនទាន់ទទួលបានវីសារបានទៀត ហើយឥឡូវត្រូវកាត់លុយមួយខែ២៥០បាត ដើម្បីបង់អោយប៉ូលីសទៀត។ រឿងនេះបានធ្វើពលករមានការធ្ងល់ និងមិនសប្បាយចិត្ត ហើយក៏សម្រេចចិត្តលើកគ្នាទៅប្ដឹងសមត្ថកិច្ចតម្រួតប៉ុស្តិ៍ផានថង ដើម្បីអោយជួយរកយុត្តិធម៌ជូនពួកគាត់។

## លោក អ៊ីវ លាង ចូលរួមកិច្ចប្រជុំពិភាក្សា ស្ដីពីការរៀបចំពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករ ពលករចំណាកស្រុក

http://nokorwatnews.com/ 10-09-2020

ភ្នំពេញ៖ ខាងអគ្គាធិការដ្ឋានបានឱ្យដឹងថា៖ ព្រឹកថ្ងៃសុក្រទី១១ ខែកញ្ញា ឆ្នាំ២០២០ លោក អ៉ីវ លាង អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយស្រុកបាភ្នំ អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្ដីពីការរៀបចំពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករ ពលករចំណាកស្រុក ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនាថ្ងៃទី១៦-១៧-១៨ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាព លោក ព្រុំ សុខា ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយស្រុកបាភ្នំ និងជាប្រធានក្រុមការងារកម្មករ ពលករចំណាកស្រុកខេត្តព្រៃវែង។ កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅសាលប្រជុំសាលាខេត្តព្រៃវែង និងមានការអញ្ជើញចូលរួមពី លោក លោកស្រី ជាអនុប្រធានទី១ ក្រុមការងារចុះជួយក្រុង ស្រុក អនុប្រធាន សមាជិកក្រុមការងារចំណាកស្រុក និងអភិបាលរងក្រុង ស្រុក ទទួលបន្ទុកការងារចំណាកស្រុក៕

## ពលរដ្ឋខ្មែរ១៧នាក់ត្រូវទាហានថៃឃាត់ខ្លួនមួយរយៈ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២០ ម៉ោង ១៣:៥០ ដោយ ពិសម័យ

ខេត្តបាត់ដំបង ៖ យ៉ាងហោចណាស់ ពលរដ្ឋខ្មែរចំនួន១៧នាក់ដែលក្នុងចំណោមនោះមានស្ត្រីចំនួន៤នាក់ផង ត្រូវបានកងទាហានឈុតខ្មៅថៃឃាត់ខ្លួនយកទៅសួរនាំ ខណៈដែលពួកគេបានឆ្លងដែនចូលទៅលួចជីករ៉ែមាសនៅក្នុងទឹកដីបរទេសថៃដោយខុស ច្បាប់ កាលពីវេលាម៉ោង៣និង៣០នាទីរសៀលថ្ងៃទី ៩ កញ្ញា នៅក្នុងទឹកដីស្រុកខ្លុងហាត ខេត្តស្រះកែវ ទល់មុខភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ប្រភពពីមន្ត្រីនគរបាលការពារព្រំដែនលេខ៨១៧បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង១៧នាក់ បាននាំគ្នាឆ្លងដែនចូលទឹកដីថៃ ដើម្បីលួចជីកយករ៉ែមាសនៅត្រង់ចំណុចខាងលើ តែត្រូវកម្លាំងទាហានឈុតខ្មៅថៃ ដើរល្បាតក៏ប្រទះឃើញ ទើបឃាត់ខ្លួនពួកគេនាំយកទៅសួរនាំតែម្ដង ។ មន្ត្រីបានប្រាប់ថា ពលរដ្ឋទាំងនោះ មានសម្ភារសម្រាប់ជីករ៉ែការ៉ុងសម្រាប់រ៉ែ និងឧបករណ៍វែងមាស នៅជាប់ជាមួយផង។ បើតាមព័ត៌មាននៅទីនោះថា ជារឿយៗ ពលរដ្ឋខ្មែរមួយចំនួនតែលួចឆ្លងដែនចូលទឹកដីថៃ នៅជាប់ព្រំដែនក្នុងតំបន់នោះ ដើម្បីលួចជីកកកាយរករ៉ែមាស ហើយទាហានថៃ ក៏ធ្លាប់ដេញចាប់ផងដែរ តែពួកគេនៅតែប្រថុយនឹងគ្រោះថ្នាក់នេះដដែលដោយសារតែជីវភាព។ ប្រភពបានបញ្ជាក់ថា កន្លងទៅ ពួកគេតែងជីករុករករ៉ែមាសនៅលើទឹកដីខ្មែរខ្លួនឯង នៅជាប់អូរព្រំដែន តែក្រោយមកពួកគេកាន់តែហ៊ានលួចឆ្លងដែនខុសច្បាប់ ចូលទៅជីករករ៉ែមាសដល់ក្នុងទឹកដីថៃ ហេតុត្រូវក្រុមទាហានឈុតខ្មៅថៃ

ឃាត់ខ្លួនបានទាំងហ្វូងតែម្តង។ នេះចាត់ទុកថា ជាសំណាងល្អដែរ ដែលទាហានថៃ មិនប្រើប្រាសអាវុធបាញ់ប្រហារ ដូចក្រុមអ្នកចូលលួចកាន់ឈើ នៅតាមព្រំដែនស្រុកសំឡូត។

លោក សុងសុភ័ក្រ អភិបាលស្រុកភ្នំព្រឹក បានថ្លែងប្រាប់កោះសន្តិភាព តាមទូរស័ព្ទថា ពិតជាមានពលរដ្ឋខ្មែរត្រូវក្រុមទាហានថៃចាប់ខ្លួនមែន។ លោកថា ការចាប់ខ្លួននោះ ដោយសារតែពលរដ្ឋទាំង១៧នាក់នោះ បានឆ្លងដែនដោយខុសច្បាប់ ទៅលួចជីករ៉ែមាសនៅក្នុងទឹកដីគេ (ដីថៃ)។ ហើយនេះមិនមែនជាលើកដំបូងទេ ដែលពលរដ្ឋខ្មែរយើងមួយចំនួនចូលលួចជីកយករ៉ែមាសនៅទឹកដីថៃ។ យើងបានអប់រំណែនាំដល់ពលរដ្ឋទាំងនោះជាបន្តបន្ទាប់ កុំឲ្យលួចឆ្លងដែលទៅប្រព្រឹត្តបទល្មើសក្នុងទឹកដីថៃបែបនេះចៀសវាងក្រែងមានបញ្ហា តែពួកគេនៅតែលួចចូលម្តងម្កាលរហូតត្រូវទាហានថៃ ដើរល្បាតប្រទះឃើញធ្វើការឃាត់ខ្លួនតែម្តង។ ប៉ុន្តែយ៉ាងណា លោកសុង សុភ័ក្រ បានបញ្ជាក់ថា ក្រោយពីត្រូវទាហានថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ និង បាននាំទៅសួរនាំ ប៉ុន្មានមោងក្រោយ ទើបអាជ្ញាធរស្រុក និង មន្ត្រីនគរបាល វរៈការពារព្រំដែនលេខ៨១៧ ចុះទៅសម្របសម្រួលជាមួយភាគីថៃ ដើម្បីធានា និង ដោះស្រាយយកពលរដ្ឋទាំង១៧នាក់នោះ ត្រឡប់ចូលប្រទេសខ្លួនវិញ។ លោកបានបន្ថែមថា ជាមួយនឹងការធានាយកមកវិញនេះ ភាគីថៃក៏បានឲ្យពលរដ្ឋខ្មែរទាំងនេះធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពឆ្លងដែនខុសច្បាប់ ទៅលួចជីករ៉ែក្នុងទឹកដីគេបន្តទៀតដែរ តែយើងក៏បានធ្វើការអប់រំដល់ពលរដ្ឋទាំងនេះឲ្យបញ្ឈប់នូវសកម្មលួចឆ្លងដែននេះផងដែរ ៕

## ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០

## សមត្ថកិច្ចនៅតាមច្រកព្រំដែនបន្តពង្រឹងវិធានធ្វើចត្តាឡីស័កចំពោះពលករចេញចូលតាមច្រកព្រំដែនក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ

https://www.information.gov.kh/ ថ្ងៃទី11 ខ កញ្ញា ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា៖ ដោយ អ៊ី កនិកា ១១.៩.២០២០

MC៖ សមត្ថកិច្ចនៅតាមច្រកព្រំដែនបន្តពង្រឹងវិធានធ្វើចត្តាឡីស័កចំពោះពលករចេញចូលតាមច្រកព្រំដែនក្នុងឱកាសបុណ្យភ្ជុំបិណ្ឌដើម្បីការពារសុវត្ថិភាពនិងទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩កុំឱ្យរីករាលដាលចូលសហគមន៍។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ថា ពលករខ្មែរនាំគ្នាធ្វើដំណើរត្រឡប់មកប្រទេសវិញ ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្យនេះ គឺប្រឈមនឹងការឆ្លងជំងឺកូវីត-១៩ ពិសេសងាយប្រឈមឆ្លងចូលក្នុងសហគមន៍ប្រសិនបើមានការធ្វេសប្រហែស ដោយបណ្តោយឲ្យពួកគាត់ចេញចូលគ្មានការត្រួតពិនិត្យឲ្យបានច្បាស់លាស់ ។ លោកជំទាវបានបន្តថា មានតែវិធានការពាររឹតបន្តឹងការចេញចូលនេះឲ្យបានម៉ត់ចត់ ហើយត្រូវអនុវត្ត ឱ្យពួកគាត់ធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃសិន ដើម្បីតាមដានសុខភាព និងត្រូវអនុវត្តអនាម័យជាប្រចាំផង ទើបអាចទប់ស្កាត់ជំងឺកូវីត-១៩ មិនឱ្យរីករាលដាល ចូលសហគមន៍បាន។

សំឡេង៖ «តែនៅខាងនេះពួកយើងព្យាយាមទទួលគាត់ មានក្រុមការងារតាមបណ្តាខេត្ត ក៏ដូចជាខេត្តបន្ទាយមានជ័យ ឬតាមច្រកអូពាជាន់ ។យើងឃើញពួកគាត់ ឆ្លងមកដល់យើងចាំទទួលគាត់ ដោយសារតែប្រជាជនយើង ទោះបីដឹងហើយគាត់មក ដោយខុសច្បាប់ ម្សិលមិញពលករត្រលប់មកជាង៥០០នាក់។ យើងមើលឃើញថាយើងត្រូវប្រឈមដែរ ដំណាក់កាលកូវីដ-១៩ វាមិនទាន់ស្រាកស្រាន្ត យើងនៅតែប្រុងប្រយ័ត្ន ធ្វើឲ្យពួកគាត់ជួបការលំបាក១ជាន់ទៀតនៅពេលយើងឲ្យពួកគាត់ធ្វើចត្តាឡីស័ក។ យើងត្រូវតែការពារសហគមន៍ដែរ ពីព្រោះរាល់ថ្ងៃប្រទេសមួយចំនួនធំគេកំពុងប្រឈមនៅតាមសហគមន៍។ចឹងហើយបានជាយើងត្រូវពិនិត្យព្យាបាលឬមួយក៏ ពិនិត្យតាមដានស្ថានភាពនៃជំងឺរបស់គាត់ ស្ថានភាពសុខភាពរបស់ពួកគាត់តាំងពីពេលគ្រាន់តែចេញមកពីព្រំដែនយើងមានពេទ្យមន្ត្រីរដ្ឋបាលយើងនៅតាមបណ្តាខេត្តយើងចាំទទួល»។ លោកជំទាវបានបញ្ជាក់ថា ការពង្រឹងវិធានការ

ទប់ស្កាត់ជំងឺកូវីដ-១៩នៅតាមច្រកចេញចូលព្រំដែននេះ គឺស្របពេលដែលពលករខ្មែរ បានចាប់ផ្តើមធ្វើដំណើរមកកាន់ស្រុកកំណើតដើម្បីជួបជុំក្រុមគ្រួសារ នាឱកាសបុណ្យភ្ជុំបិណ្ឌ ៕

## កម្ពុជានិងសហការជាមួយប្រទេស៤នៅអាស៊ាន រៀបចំការអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករធ្វើការនៅក្រៅប្រទេស

http://kampucheathmey.com/ 12/9/2020 8:30 Pm

ភ្នំពេញ ៖ កម្ពុជានឹងសហការជាមួយប្រទេសចំនួន៤នៅអាស៊ាន( CLMTV) ដើម្បីរៀបចំឲ្យមានការអនុវត្តរបបសោធននិវត្តន៍ សម្រាប់ពលករធ្វើការនៅបរទេសឲ្យទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗ មុនពេលត្រឡប់មកស្រុកកំណើតវិញ។ ការអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករខ្មែរ ថៃ វៀតណាម ឡាវ និងមីយ៉ាន់ម៉ា ដែលធ្វើការនៅក្រៅប្រទេសនេះគឺ ដើម្បីឲ្យពលករប្រទេសនីមួយៗ អាចផ្ទេរសមាជិកភាព អតីតភាពការងារនិងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ។ គម្រោងនេះ ត្រូវបានប្រទេសទាំង៥លើកយកមកពិភាក្សាគ្នា នៅក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារលើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (6th SLOM CLMTV Meeting) ក្រោមប្រធានបទ "ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម" តាមរយៈប្រព័ន្ធវីដេអូ (Video Conference)ដែល ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

តាមរយៈទំព័រហ្វេប៊ុកផ្លូវការរបស់ក្រសួងការងារ លោកសោម ចំណាន អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងប្រធានអង្គប្រជុំបានឲ្យដឹងថា កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងពិនិត្យលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីការងារ ស្តីពី ចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ ដើម្បីឈានទៅរកការបង្កើតយន្តការរួមមួយក្នុងការធ្វើចល័តភាពអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមពីប្រទេសមួយ ទៅប្រទេសមួយទៀតក្នុងចំណោមប្រទេស CLMTV និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ ក៏ដូចជាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងាររវាងប្រទេស CLMTV។ លោកសោម ចំណាន បានថ្លែងអំណរគុណចំពោះគណៈប្រតិភូនៃប្រទេសទាំងបួន និងដៃគូពាក់ព័ន្ធទាំងអស់ដែលបានចូលរួមសហការយ៉ាងសកម្មក្នុងការព្រាងសេចក្តីថ្លែងការណ៍ខាងលើ ដែលជាយន្តការរួមមួយដើម្បីលើកកម្ពស់កិច្ចគាំពារសង្គម និងជួយសម្រួលដល់ចល័តភាពអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមដែលផ្តោតលើប្រាក់សោធន និងតាវកាលិករយៈពេលវែងនៃរបបហានិភ័យការងារសម្រាប់ពលករទេសន្តរប្រវេសក៍ក្នុងប្រទេស CLMTV។

ជាលទ្ធផល កិច្ចប្រជុំបានពិនិត្យ ផ្លាស់ប្តូរយោបល់លើខ្លឹមសារសេចក្តីព្រាងសេចក្តីថ្លែងការណ៍នេះ និងដាក់ឲ្យក្រុមការងារបច្ចេកទេសនៃប្រទេសទាំង៥ ពិនិត្យ និងកែសម្រួលនៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ខាងមុខ។ សេចក្តីព្រាងសេចក្តីថ្លែងការណ៍នេះនឹងត្រូវពិនិត្យជាចុងក្រោយនៅក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារលើកទី៧ មុននឹងត្រូវដាក់ឲ្យពិនិត្យ និងអនុម័តក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារនៃប្រទេស CLMTV លើកទី៤ ដែលគ្រោងនឹងរៀបចំនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាខែឧសភា ឆ្នាំ២០២១ ដូចដែលបានកំណត់ក្នុង "ផែនទីបង្ហាញផ្លូវសៀមរាបឆ្ពោះទៅកាន់សេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីការងារនៃប្រទេស CLMTV ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គម" ដែលត្រូវបានអនុម័តនិងប្រកាសក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារនៃប្រទេស CLMTV លើកទី៣ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នៅខេត្តសៀមរាប។

តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា កម្ពុជាបានបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសប្រមាណ១លាន២សែននាក់ ក្នុងនោះប្រទេសថៃមានជាង១លាននាក់និងក្រៅពីនេះបញ្ជូនទៅប្រទេសម៉ាឡេស៊ី សិង្ហបុរី កូរ៉េខាងត្បូង ជប៉ុន និងតំបន់រដ្ឋបាលពិសេសហុងកុង ដោយបានផ្ញើថវិកាមកក្រុមគ្រួសារប្រមាណជាង ២ ពាន់ពាន់លានដុល្លារក្នុង១ឆ្នាំៗដែលជួយលើកស្ទួយដល់ក្រុមគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិរីកចម្រើន៕ សំអឿន

## ជិតដល់បុណ្យភ្ជុំបិណ្ឌ៖ ពលករខ្មែរ វិលពីធ្វើការនៅថៃ កើនឡើង

https://www.rasmeinews.com/ September 12, 2020, 6:36 PM

ដោយ ៖ ភ្នំស្វាយ/ បន្ទាយមានជ័យ៖ ជិតដល់ថ្ងៃឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ ដែលបានកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លំហូរពលករខ្មែរ វិលពីធ្វើការនៅថៃ ធ្វើមាតុភូមិនិវត្តន៍ បានកើនឡើងហើយសម្រាប់ភូមិសាស្ត្រ ខេត្តបន្ទាយមាជ័យ ភាគច្រើន ពួកគេវិលមក តាមច្រករបៀងអូរបីជាន់ នាស្រុកអូរជ្រៅនិងតាមច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។ ចំណែកមណ្ឌលចត្តាឡីស័ក នៅទីតាំងសាលារៀននានា ត្រូវបង្រួមបន្ថយ មកទុកនៅតែ ២ កន្លែងប៉ុណ្ណោះ ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានថ្លែងក្នុងជំនួបជាមួយ ប្រតិភូចម្រុះរបស់បរទេស រួមទាំងអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) ថា៖ ជាមធ្យម មានពលករកម្ពុជា ដែលធ្វើការនៅប្រទេសថៃ ប្រមាណ ៦០០ ទៅ ៨០០ នាក់ ក្នុង១ថ្ងៃៗ បានវិលមាតុភូមិនិវត្តន៍ ក្នុងរដូវបុណ្យកាន់បិណ្ឌ និងកៀកនឹងបុណ្យភ្ជុំបិណ្ឌនេះពោលគឺពួកគេ ត្រូវមកជួបជុំក្រុមគ្រួសារ និងធ្វើបុណ្យទាន តាមប្រពៃណី នៃព្រះពុទ្ធសាសនា ។ ចំពោះការត្រួតពិនិត្យសុខភាព ពិសេសទាក់ទិននឹងការបង្ការ ទប់ស្កាត់ការឆ្លង រីករាលដាលជំងឺកូវីដ-១៩ លោកអភិបាលខេត្ត បានបញ្ជាក់ថា៖ នៅច្រកព្រំដែន មានគណៈកម្មាធិការខេត្ត និងអនុគណៈកម្មាធិការស្រុក រង់ចាំធ្វើចត្តាឡីស័ក លើពលករទាំងនោះ ហើយមកដល់ក្នុងប្រទេសកម្ពុជាវិញ រដ្ឋបាលខេត្ត ក៏នៅរក្សាមណ្ឌលចត្តាឡីស័ក ២ កន្លែង សម្រាប់ត្រួតពិនិត្យគឺ៖ ១. នៅមណ្ឌលសំចត នាសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត និង ២. នៅអគារសាលាពេទ្យ នៃសាកលវិទ្យាល័យ មានជ័យ នាសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ពោលគឺរដ្ឋបាលខេត្ត បានរំសាយមណ្ឌលចត្តាឡីស័ក តាមសាលារៀន ៨ កន្លែង និងសណ្ឋាគារ ផ្ទះសំណាក់ ២ នៅក្នុង ៨ ស្រុក ក្រុង នាពេលកន្លងមក ៕V

## ប្រជាពលរដ្ឋខ្មែរចំនួន ៥៧នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 13-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៧នាក់ ស្រី ២១នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៨៨នាក់

https://www.facebook.com/GDIOfficial 13-09-2020

ឈ្មោះឃឿក ភេទប្រុស អាយុ៤៣ឆ្នាំ អះអាងថាមានទីលំនៅក្នុងខេត្តបន្ទាយមានជ័យបំរុងធ្វើដំណើរទៅធ្វើការជាមួយថៅកែចាស់នៅក្នុងស្រុកថាន់បូរី ខេត្តប៉ាក់ធុមថានី ដោយចំណាយប្រាក់ថ្លៃផ្លូវចំនួន៣០០០បាត ប៉ុន្តែមិនទាន់ដល់គោលដៅផង ក៏ត្រូវគេចាប់តែម្តង។ ទោះយ៉ាងណាក៏ដោយ ករណីនេះសមត្ថកិច្ចថៃមិនត្រឹមតែឃាត់ខ្លួនពលករខ្មែរចំនួន១៣នាក់ទេ ថែមទាំងឃាត់ខ្លួនជនជាតិថៃ២នាក់ម្នាក់ជាអ្នកបើកបររថយន្ត និងម្នាក់ជាប់ចោទមេខ្យល់ ប្រគល់ឲ្យសមត្ថកិច្ចជំនាញនៅស្រុកអារញ្ញដើម្បីយកទៅសាកសួររួមគ្នានិងចាត់ការបន្តតាមនិតិវិធីច្បាប់៕ (កែសម្រួលដោយ ៖ ជីតា)

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ៤នាក់មកប្រទេសដើមវិញបន្ទាប់ពីដោះលែងពីពន្ធនាគារ

https://www.rasmeinews.com/ September 24, 2020, 4:28 PM

ដោយបាយ័ន/ឧត្តរមានជ័យ: ប្រជាពលរដ្ឋខ្មែរចំនួន៤នាក់ ត្រូវបានអាជ្ញាធរថៃបានបញ្ជូនឱ្យវិលត្រឡប់ទៅកាន់លំនៅស្ថានវិញបន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ ពិធី

ប្រគល់និងទទួល បានធ្វើឡើងកាលពីម៉ោង១១និង៣៨នាទី ថ្ងៃទី២៤ ខែកញ្ញា ឆ្នំ២០២០នេះ ស្ថិតនៅច្រកអន្តរជាតិជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថាប្រជាពលរដ្ឋខ្មែរចំនួន ៤ នាក់ដែលត្រូវបានភាគីថៃបញ្ជូនមកស្រុកកំណើតវិញនោះគឺមានទី១,ឈ្មោះ ម៉េង មុល ភេទប្រុសអាយុ២៧ឆ្នាំ រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ត្រូវបានចាប់ខ្លួនថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងទៅនេះ ដោយចូលតាមច្រកចំការស្វាយ។ ទី ២,ឈ្មោះ ថៃ កេត ភេទប្រុស អាយុ៣៦ឆ្នាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យត្រូវបានចាប់ខ្លួនថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៨កន្លងទៅនេះ ដោយ ចូលតាមច្រកចំការខ្នុរ ។ទី ៣,ឈ្មោះ ធើម ស៊ឹម ភេទប្រុសអាយុ២៧ឆ្នាំ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ត្រូវបានចាប់ខ្លួនថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨កន្លងទៅនេះ ដោយ ចូលតាមច្រកចំការខ្នុរ។ ទី៤,ឈ្មោះ វិត វែង ភេទប្រុស អាយុ៣០ឆ្នាំ នៅ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ត្រូវបានចាប់ខ្លួនថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨កន្លងទៅនេះ ដោយ ចូលតាមច្រកអូរចារ ។អ្នកទាំង០៤ ត្រូវបានចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងហើយបញ្ជូនយកទៅដាក់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ រហូតដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០នេះ ទើបដោះលែង៕S/

## កម្ពុជា និងបណ្តាប្រទេសជាដៃគូសន្យារួមគ្នាបន្ថែមទៀត ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន

http://btv.com.kh/ 24/09/2020

ភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ និងបណ្តាប្រទេសជាដៃគូក្នុងតំបន់អាស៊ាន និងពិភពលោក បានសន្យារួមគ្នាឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ខណៈបទឧក្រិដ្ឋ មួយនេះ ពុំមានប្រទេសណាមួយជាឯកឯងអាចទប់ស្កាត់បាននោះទេ ប្រសិនបើគ្មានកិច្ចសហការនោះ។ ថ្លែងប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនអាស៊ាន លើកទី២០ តាមរយៈវីដេអូ ខនហ្វើរិន ដែលប្រទេសហ្វីលីពីនធ្វើជាម្ចាស់ផ្ទះ នៅព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០នេះ ឯកឧត្តម មៀច សុផាន់ណា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានឲ្យដឹងថា នៅក្នុងកិច្ចប្រជុំតាមរយៈវីដេអូនេះ ភាគីពាក់ព័ន្ធបាននិយាយគ្នាជាច្រើនទាក់ទង នឹងអំពើភេរវកម្ម ការសារាចរឧសថក្លែងក្លាយ គ្រឿងញៀន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មជាច្រើនទៀត ដែលកំពុងបន្តកើតមានឡើងនៅក្នុងតំបន់ និងពិភពលោក។

យ៉ាងណាក៏ដោយ ឯកឧត្តមរដ្ឋលេខាធិការ បានលើកឡើងទៀតថា បទឧក្រិដ្ឋកម្មឆ្លងដែននេះ គឺជាបញ្ហាមួយដែលប្រទេសនៅក្នុងតំបន់ក៏ដូចជាពិភពលោកកំពុងព្រួយបារម្ភនៅឡើយ ហើយភាគីទាំងអស់សន្យាប្តេជ្ញារួមគ្នាបន្ថែមទៀតក្នុងការទប់ស្កាត់ឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីសន្តិសុខសង្គម តំបន់ និងពិភពលោកទាំងមូលនោះ។ បើតាម ឯកឧត្តម មៀច សុផាន់ណា ដដែល ក៏បានឲ្យដឹងផងដែរថា នៅក្នុងកិច្ចប្រជុំតាមរយៈវីដេអូ ខនហ្វើរិននេះ ភាគីពាក់ព័ន្ធទាំងអស់នឹងខិតខំផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកបន្ថែមទៀត ក្នុងកិច្ចការពារ នឹងទប់ស្កាត់នូវបទល្មើសមួយនេះ ហើយមួយវិញទៀត នឹងផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមកដោយឆាប់រហ័សបំផុត បន្ទាប់ពីមានតម្រុយណាមួយទាក់ទង នឹងបទឧក្រិដ្ឋកម្មឆ្លងដែន និងបទល្មើសទាក់ទង នឹងផលិតផលក្លែងក្លាយជាដើមនោះ៕

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ ជួយសម្រួលឯកសារឱ្យបានក្នុងថ្ងៃតែ១ ដល់បងប្អូនខ្មែរក្នុងកំឡុងការរីករាលដាលជំងឺកូវីដ-១៩

http://nokorwatnews.com/ 23-09-2020

ភ្នំពេញ៖ នាថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២០ លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាលសួរសុខទុក្ខ ចែកម៉ាសនិងជែលអាល់កុលលេងដៃ ព្រមទាំងបានបើកផ្តល់ឯកសារដល់បងប្អូន ពលករខ្មែរដែលមកទទួលសេវានៅស្ថានទូត។ លោកឯកអគ្គរាជទូត បានជម្រាបថា ក្នុងគោលបំណង បង្កិតសេវាដល់បងប្អូនពលករខ្មែរក្នុងប្រទេសថៃ ស្ថានទូតបានជួយ សម្រួលផ្តល់សេវាបញ្ជាក់ឯកសារនានាឱ្យបានក្នុងថ្ងៃតែមួយជូនដល់បងប្អូនខ្មែរ ដើម្បីកាត់បន្ថយការចំណាយ និងពេលវេលាធ្វើដំណើរ ព្រមទាំងការលំបាកនានា។ ក្នុងកម្មវិធីសំណេះសំណាលនេះ លោកទូត បានផ្តាំផ្ញើរការសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដល់បងប្អូន ពលករទាំងអស់ និងបានណែនាំផងដែរថា ក្នុងស្ថានការណ៍ រីករាលដាលជំងឺកូវីដ-១៩នេះ សូមបងប្អូនថែរក្សាសុខភាព អនាម័យអោយបានខ្ជាប់ខ្ជួន លាងដៃនឹងសាប៊ូ ពាក់ម៉ាស ពេលចេញទៅកន្លែងសាធារណៈ។

លើសពីនេះទៅទៀត ក្រុមការងារស្ថានទូតបានធ្វើការពន្យល់ណែនាំ អំពីសេវាបញ្ជាក់លិខិតផ្សេង ច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករ ជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។ បងប្អូនពលករខ្មែរទាំងអស់ ពិតជាមានការសប្បាយរីករាយ និងកក់ក្តៅយ៉ាងខ្លាំង ដែលស្ថានទូតក៏ដូចជារាជរដ្ឋាភិបាល ដែលតែងតែយកចិត្តទុកដាក់អំពីសុខទុក្ខរបស់ពួកគាត់៕

## ពលករខ្មែរមួយចំនួនធ្វើការនៅប្រទេសថៃជួបការលំបាកអំឡុងមានវិបត្តិជំងឺកូវីដ-១៩

https://www.rfa.org/khmer/ ដោយ សុជីវី 2020-09-23

ពលករខ្មែរមួយចំនួន ដែលធ្វើការងារនៅប្រទេសថៃ (Thailand) ត្អូញត្អែរថា ពួកគេជួបការលំបាករឿងបំពេញឯកសារស្នាក់នៅ និងមានជីវភាពខ្វះខាតដោយសារធ្វើការងារមិនបានទៀតទាត់ បណ្តាលមកពីការរាតត្បាតជំងឺកូវីដ១៩។ ពលករខ្លះនៅតែបន្តខាំស្មៅយ៉ាងលំបាកលំបិននៅប្រទេសថៃដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ។

ក្រុមពលករខ្មែរមួយចំនួនដែលធ្វើការងារនៅប្រទេសថៃ លើកឡើងស្រដៀងគ្នាថា ការរាតត្បាតជំងឺកូវីដ១៩ នៅតែបន្តផលប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់ពួកគេដដែល ដោយមិនទាន់បានប្រសើរឡើងវិញ នៅឡើយទេ។ ពលករខ្លះបានសម្រេចចិត្តវិលត្រឡប់ទៅស្រុកកំណើតវិញ ដោយសារតែពួកគេអត់ការងារធ្វើ ហើយគ្មានប្រាក់ចាយវាយក្នុងពេលស្នាក់នៅប្រទេសថៃ។ ចំណែកពលករខ្លះទៀតបន្តស្នាក់នៅប្រទេសថៃ ដោយសារជីវភាពក្រីក្រ ហើយនៅស្រុកខ្មែរគ្មានការងារធ្វើរកប្រាក់ចំណូល។

ពលការិនីធ្វើការផ្នែកកាត់ដេរសំលៀកបំពាក់នៅទីក្រុងបាងកក លោកស្រី យ៉ាត កញ្ញា ថ្លែងថា លោកស្រីមកធ្វើការនៅប្រទេសថៃប្រមាណ ៦ឆ្នាំហើយ ដោយពុំធ្លាប់ពិបាករកប្រាក់ដូចឆ្នាំនេះឡើយ។ ពលករវ័យ ៣១ឆ្នាំរូបនេះ ឱ្យដឹងថា ចាប់តាំងពីការរាតត្បាតជំងឺកូវីដ១៩ មក លោកស្រីធ្វើការមិនបានទៀងទាត់នោះទេ គឺធ្វើការពីរប្តីរបស់លោកស្រីបានប្រាក់ប្រមាណ ១ម៉ឺន ៥ពាន់បាតស្មើប្រហែល ៥០០ដុល្លារអាមេរិក (១៥.០០០) ក្នុងមួយខែ ដោយខុសពីពេលមិនទាន់មានការរាតត្បាតជំងឺកូវីដ១៩ ដែលលោកស្រីមានការងារទៀតទាត់រកប្រាក់ចំណូលបានជាង ២ម៉ឺនបាត (២០.០០០) ក្នុងមួយខែ។ ពលករមានស្រុកកំណើតនៅបាត់ដំបងរូបនេះបន្ថែមថា ប្រាក់ចំណូលលោកស្រីធ្វើការងារបានសព្វថ្ងៃ សម្រាប់តែចាយវាយនៅក្នុងប្រទេសថៃ ដោយពុំបានប្រាក់ផ្ញើទៅឱ្យពុកម្តាយនៅស្រុកកំណើតឡើយ៖ «ដូចថាការងារមិនសូវមានអីចឹងទៅ ហើយសេដ្ឋកិច្ចប្រទេសថៃកាន់តែធ្លាក់ចុះ ការងារពិបាក

រក ពេលខ្លះក៏មានធ្វើពេលខ្លះក៏អត់ធ្វើ ហើយដល់ពេលបន្ទប់ក៏ជួលគេអីចឹងទៅខ្វះខាតខ្លាំងណាស់ ហើយបើចុះទៅផ្ទះក៏ចុះទៅអត់បាន។ ខ្ញុំមិនមានលុយផ្ញើទៅផ្ទះទេរកតែលុយហូបមិនចង់បានផង ហើយយើងមានកូនតូច ត្រូវចំណាយថ្លៃទឹកដោះគោកូន»។

លោកស្រីឱ្យដឹងទៀតថា ក្រៅពីនេះលោកស្រីជួបការលំបាកបញ្ហាការអស់សុពលភាពលិខិតឆ្លងដែន។ លោកស្រីបន្តថា នៅតំបន់លោកស្រីធ្វើការមានពលករខ្មែរប្រមាណ ២០នាក់ ដែលមានលិខិតឆ្លងដែន អស់សុពលភាពនៅចុងឆ្នាំ២០២០ នេះ ហើយថ្មីៗ នេះពួកលោកស្រីបានរកអន្តរាគមន៍ពីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីឱ្យជួយពន្យារសុពលភាពលិខិតឆ្លងដែនដែរ ក៏ប៉ុន្តែមន្ត្រីស្ថានទូតមិនបានជួយអ្វីដល់ពួកលោកស្រីឡើយ៖ «អ្នកខ្លះក៏អស់ខែ១០ នេះ អ្នកខ្លះក៏អស់សុពលភាពខែ១២ អីចឹងទៅហើយយើងចុះទៅផ្ទះអត់បានអីចឹងទៅយើងរត់ទៅសុំគាត់ជួយអីចឹងនៅស្ថានទូតខ្មែរ។ គាត់ឆ្លើយមកតែមួយម៉ាត់ថា តសុពលភាពក៏អត់បានហើយចុះទៅផ្ទះក៏អត់បានដែរ បានន័យថាគាត់អត់ខ្វល់ខ្វាយពីប្រជាជនខ្មែរយើងដែលនៅប្រទេសថៃតែម្តង។ដូចថាគេគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនគេអត់គិតប្រយោជន៍រួមអីចឹងដល់ពេលយើងធ្វើប៉ាស្ព័រផងអស់ច្រើនណាស់គ្រាន់តែមួយភ្លេចតវីសាផង តប៉ាស្ព័រតេកាតធ្វើការផងអស់ច្រើនណាស់»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី២៣ កញ្ញា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។ ប៉ុន្តែគេហទំព័រស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃចុះផ្សាយ កាលពីថ្ងៃទី២២ កញ្ញាថា ឯកអគ្គរាជទូតខ្មែរប្រចាំទីក្រុងបាងកកលោក អ៊ូក សោភ័ណ មានប្រសាសន៍ក្នុងពេលជួបសំណេះសំណាលជាមួយកម្មករខ្មែរប្រមាណ ៥០នាក់ នៅក្នុងស្ថានទូតថា ស្ថានទូតបានផ្តល់សេវាបញ្ជាក់ឯកសារផ្សេងៗ ជូនពលករខ្មែរមួយថ្ងៃរួចរាល់ ដើម្បីកាត់បន្ថយការចំណាយ និងពេលវេលាធ្វើដំណើររបស់ពលករ។ មន្ត្រីស្ថានទូតបន្ថែមថា ប្រសិនបើពលករមានបញ្ហាក្នុងពេលធ្វើការនៅប្រទេសថៃ អាចទាក់ទងស្ថានទូតធ្វើលិខិតស្នាមផ្សេងៗ បាន។

អាស៊ីសេរីក៏បានព្យាយាមទាក់ទងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បន្ថែមទៀត ក៏ប៉ុន្តែទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

ចំណែកពលករខ្មែរធ្វើការសំណង់នៅទីក្រុងបាងកកលោក ប៊ុន វីរៈ វិញ ថ្លែងថា ចាប់ពីខែមីនាមក លោកមិនបានផ្ញើប្រាក់ទៅឱ្យឪពុកម្តាយនៅស្រុកកំណើតនោះទេ ដោយសារនៅប្រទេសថៃមិនសូវមានការងារធ្វើ។ លោកបន្ថែមថា បច្ចុប្បន្នលោកធ្វើការងារបានប្រាក់ប្រមាណ ៧ពាន់បាត (៧.០០០) ស្មើប្រមាណ ២៣០ដុល្លារ ក្នុងមួយខែ គឺថយចុះប្រហែល ៥០ភាគរយ បើធៀបកាលពីមិនទាន់មានការរាតត្បាតជំងឺកូវីដ១៩។ លោកបញ្ជាក់ថា ប្រាក់ដែលរកបានលោកចាយវាយ៉ាងត្បិតត្បៀតបំផុត និងនៅពេលលោកទំនេរពីការងារលោកតែងតែដើរដាក់មងតាមដងអូរ និងបេះត្រកួនព្រមទាំងផ្កាស្នោយកម្ហូប ដើម្បីកាត់បន្ថយការចំណាយប្រចាំថ្ងៃក៏មានដែរ៖ «ក្នុងពេលមានជំងឺកូវីដនេះអ្នកណាក៏ដូចអ្នកណាដែរ បើខ្ញុំវិញអត់មានលុយផ្ញើទៅផ្ទះបណ្តោយបង ទី១ អត់ការងារធ្វើពេញថ្ងៃ ថ្ងៃណាទៅគេបិទទៅគេអត់ឱ្យធ្វើ ថ្ងៃណាគេនេះគេក៏បើកឱ្យធ្វើទៅ ហើយធ្វើការបន្ថែមម៉ោងក៏អត់សូវមាន។ ប្រាក់ចំណូលកាល ដែលមិនទាន់ជំងឺកូវីដ យើងបានធ្វើការពេញថ្ងៃ យើងបានប្រាក់បន្ថែមម៉ោងជួយ។ ពេលយើងអត់មានប្រាក់ចាយយើងខ្ចីប្រាក់ពីថៅកែបាន ដល់ពេលយើងធ្វើការបានយើងសង់គេវិញ។ វាលំបាកដែរទីមួយយើងអត់មានប្រាក់ផ្ញើទៅស្រុក យើងបានតែម៉ាស៊ីៗ»។ ក្រុមពលករទាំងនេះឱ្យដឹងថា នៅកន្លែងខ្លះដោយពលករគ្មានការងារធ្វើនោះទេ ហើយពលករមួយចំនួនបានសម្រេចចិត្តត្រឡប់ទៅផ្ទះវិញ ដោយសារគ្មានប្រាក់បង់ថ្លៃបន្ទប់ជួលនិងប្រាក់ទិញអាហារហូបចុកប្រចាំថ្ងៃ។

មន្ត្រីអង្គការសិទ្ធិការងារសង់ត្រាល់ (Central ) ទទួលបន្ទុលផ្នែកពលករ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរធ្វើការនៅប្រទេសថៃជាច្រើននាក់នៅតែបន្តអត់ការងារធ្វើ និងមួយចំនួនធ្វើការមិនបានពេញលេញ បណ្ដាលមកពីវិបត្តិជំងឺកូវីដ១៩។ លោកបន្ថែមថា ប្រមាណ ៣ខែចុងក្រោយនេះយ៉ាងហោចណាស់មានពលករខ្មែរជិត ១ពាន់ ២០០នាក់ (១.១៥០) ហើយត្រូវបានប៉ូលិសថៃចាប់ខ្លួន ដោយសារតែពួកគេលួចធ្វើការងារដោយខុសច្បាប់នៅប្រទេសថៃ និងប្តូរកន្លែងធ្វើការងារដោយបានបំពេញឯកសារត្រឹមត្រូវជាដើម។ លោកបន្តថា ក្នុងចំណោមពលករទាំងនោះ មានពលករប្រមាណ ៥០ភាគរយជាប់ឃុំនៅពន្ធនាគារក្នុងប្រទេសថៃ និង ៥០ភាគរយទៀតបានបញ្ជូនត្រឡប់ទៅកម្ពុជាវិញ៖ «ខ្ញុំសំណូមពរដល់រដ្ឋាភិបាលកម្ពុជាត្រូវសហការជាមួយរដ្ឋាភិបាលថៃ ធ្វើយ៉ាងណាចរចាឱ្យគេអនុគ្រោះដល់ពលករខ្មែរ ដែលត្រឡប់ទៅប្រទេសក្នុងពេលមានវិបត្តិជំងឺកូវីដ១៩ កុំឱ្យមានការដាក់ទោស ដូចជាដាក់ពន្ធនាគារ និងពិន័យជាប្រាក់អីជាដើមអីចឹង។ បើចាប់បានហើយសូមបញ្ជូនត្រឡប់ទៅខ្មែរវិញចុះ។ ទី២ ត្រូវតែផ្ដល់ការគាំពារសង្គមដល់ពលករ ដែលគាត់ត្រឡប់មកពីថៃវិញ ធ្វើយ៉ាងណាឱ្យពួកគាត់អាចរស់បាន»។

លោក ឌី ថេហូយ៉ាង ឱ្យដឹងថា ចាប់តាំងពីការរាតត្បាតជំងឺកូវីដ១៩ មកមានពលករខ្មែរ ប្រមាណ ១៤ម៉ឺននាក់ (១៤០.០០០) ហើយ ដែលបានត្រឡប់ទៅកម្ពុជាវិញ ដោយសារអត់ការងារធ្វើក្នុងនោះពលករប្រមាណ ៩០ភាគរយបានត្រឡប់ទៅធ្វើការនៅប្រទេសវិញ ដោយសារតែពួកគេចាញ់បោកមេខ្យល់ ស្របពេលដែលនៅស្រុកកំណើតអត់ការងារធ្វើ ដែលគ្មានប្រាក់សង់ធនាគារ និងប្រាក់ដោះស្រាយជីវភាពគ្រួសារ។ របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរទាំងស្របច្បាប់ និងមិនស្របច្បាប់ប្រមាណ២លាននាក់ (២.០០០.០០០) កំពុងធ្វើការងារនៅប្រទេសថៃ៕

## ពលរដ្ឋខ្មែរចំនួន០៤នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 22-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍ចំនួន ០៤នាក់ និងបានសហការជាមួយផ្នែកចត្តាឡីស័ក ធ្វើការអប់រំណែនាំ និងពិនិត្យកំដៅជូនពួកគាត់ រួចបានប្រគល់អ្នកទាំងបីនាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យ ចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 22-09-2020

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៥៩នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 22-09-2020

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៦និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ លី សុខ ភេទប្រុស អាយុ ៣៤ឆ្នាំ ភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម, ២-ឈ្មោះ គង់ នឿន ភេទប្រុស អាយុ ៤២ឆ្នាំ ភូមិកណ្តាល ឃុំសុង ស្រុកសំលោត ខេត្តបាត់ដំបង, ៣-ឈ្មោះ ឈុន ចន្ថា ភេទស្រី អាយុ ៣៤ឆ្នាំ ភូមិ៤ ឃុំដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្រ្តីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបរយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 23-09-2020

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៥៤នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣៨នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 23-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៨នាក់ ស្រី ១៥នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយ

ស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពរស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩១នាក់

https://www.facebook.com/GDIOfficial 24-09-2020

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩១នាក់ ស្រី ៣៩នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 24-09-2020

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១.ឈ្មោះ ឡឹក ឌី ភេទប្រុស អាយុ ១៥ឆ្នាំ, ២.ឈ្មោះ ជាង ឡុង ភេទប្រុស អាយុ ១៥ឆ្នាំ ភូមិថ្មី ឃុំ៣ ស្រុកមិត្តភាព ខេត្តព្រះសីហនុ, ៣.ឈ្មោះ ជា ជីវ ភេទប្រុស អាយុ ១៦ឆ្នាំ ភូមិអូត្រេះ ឃុំអូត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៣១នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 24-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣១នាក់ ស្រី ០៩នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣៩នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 24-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៩នាក់ ស្រី ១៦នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

# ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

## ពលករខ្មែរ៧នាក់ លួចឆ្លងដែនដោយខុសច្បាប់ ត្រូវទាហានថៃ ចាប់ត្រង់បរិវេណភូមិប៉ារ៉ៃ ស្រុកអរញ្ញ ខេត្តស្រះកែវ

http://btv.com.kh/ 27/09/2020

ស្រះកែវ ៖ កម្លាំងទាហានថៃ ចុះល្បាត និងឃ្លាំមើលនឹងទប់ស្កាត់ការលបលួចចូលប្រទេសដោយខុសច្បាប់របស់ពលករខ្មែរ នៅបរិវេណជាយដែនតាមច្រករបៀង ក្នុងទឹកដីទទួលខុសត្រូវក្នុងឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ បានចាប់ឃុំខ្លួនពលករខ្មែរបានចំនួន៧នាក់ ខណៈកំពង់លួចចូលមកប្រទេសដោយខុសច្បាប់ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ ។

សមត្ថកិច្ច បានឲ្យដឹងថា ខណៈពេលដែលសមត្ថកិច្ចក្រុមចាប់ឃុំខ្លួន បានប្រទះឃើញក្រុមបុគ្គលគួរឲ្យសង្ស័យថា ជាពលករខ្មែរ កំពង់លួចធ្វើដំណើរចូលមកតាមច្រករបៀងពីខាងប៉ោយប៉ែត ប្រទេសកម្ពុជា ត្រង់បរិវេណភូមិដុង ង្វ ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ដើម្បីធ្វើដំណើរឆ្ពោះទៅឯផ្សាររោងគ្លឿ ក្នុងស្រុកអារញ្ញ ។ សមត្ថកិច្ច ក៏បាននាំកម្លាំងទៅឡោមព័ទ្ធ នឹងចាប់ខ្លួនពលករខ្មែរបានចំនួន៧នាក់ ក្នុងនោះប្រុស២ ស្រី៤នាក់ នឹងក្មេងប្រុស១នាក់ ពេលត្រួតពិនិត្យមិនមានឯកសារធ្វើដំណើរ នឹងឯកសារអនុញ្ញាតធ្វើការនៅប្រទេសថៃ ទើបឃុំខ្លួនពលករខ្មែរទាំងអស់យកទៅសួរនាំនៅឯទីបញ្ជាការកងរយលេខ1205ភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ។

យ៉ាងណាក៏ដោយ ពលករខ្មែរទាំងអស់ បានសារភាពថា បានលួចធ្វើដំណើរឆ្លងដែនចូលមកប្រទេសថៃ ដើម្បីទៅធ្វើការនៅផ្សាររោងគ្លឿ ដោយសារនៅកម្ពុជាមិនមានការងារធ្វើ នឹងមិនមានចំណូល ទើបនាំគ្នាធ្វើដំណើរលួចចូលមកប្រទេសថៃ ដើម្បីមករកការងារធ្វើ បន្ទាប់មក សមត្ថកិច្ចទាហានបានថតរូបនឹងធ្វើកំណត់ហេតុ មុនហ្នឹងទំនាក់ទំនងទៅខាងភាគីកម្ពុជា នឹងនាំពលករទាំងអស់នោះបញ្ជូនត្រឡប់ទៅប្រទេស តាមច្រកដែលបានចុះMOU ជាមួយគ្នា៕ ដោយ ៖ បាន ចក់

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 27-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបាន

កម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨១នាក់

https://www.facebook.com/GDIOfficial 27-09-2020

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨១នាក់ ស្រី ៣៧នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៣៧នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 26-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៧នាក់ ស្រី ១៤នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៦នាក់

https://www.facebook.com/GDIOfficial 26-09-2020

នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៦នាក់ ស្រី ៦០នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 25-09-2020

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៧និង៤០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មាន ១. ឈ្មោះ ឈឹម សុខុម ភេទប្រុស អាយុ ៣១ឆ្នាំ ភូមិទូកមាស ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត, ២. ឈ្មោះ វុន សារៀក ភេទប្រុស អាយុ ២៩ឆ្នាំ ភូមិជុំនិតឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង, ៣. ឈ្មោះ ឡេង ឆៃយ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ, ៤. ឈ្មោះ គី សួន ភេទប្រុស អាយុ ២០ឆ្នាំ ភូមិដើមចំរៀក ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត, ៥. ឈ្មោះ រី ប៉ូ ភេទស្រី អាយុ ៤០ឆ្នាំ ភូមិវត្តខ្នុរជ័យ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង, ៦. ឈ្មោះ គង់ ស៊ីលាប ភេទស្រី អាយុ ៣២ឆ្នាំ ភូមិ២ ឃុំដងទង់ ស្រុកដងទង់ ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្រ្តីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣២នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 25-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣២នាក់ ស្រី ១៥នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧២នាក់

https://www.facebook.com/GDIOfficial 25-09-2020

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។

ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧២នាក់ ស្រី ៣៧នាក់៕

## ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

### លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានដំណើរការកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០២០

https://www.facebook.com/deputygovernoryousophear/ 28-09-2020

ខេត្តសៀមរាប៖ ព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ ខ ប ជ) បានដំណើរការកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ ដើម្បីធ្វើការតាមដាននិងត្រួតពិនិត្យលើការអនុវត្តសកម្មភាពក្នុងការបង្ការ ទប់ស្កាត់ ការស្រាវជ្រាវបទល្មើស និងការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ការនាំចេញដោយមិនស្របច្បាប់ ឬការកេងប្រវ័ញ្ចនានាលើស្ត្រី និងកុមារ។

កិច្ចប្រជុំនេះ ដឹកនាំដោយលោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋ គ ខ ប ជ ព្រមទាំងមានការអញ្ជើញចូលរួមពីព្រះរាជអាជ្ញារង តំណាងស្នងការនគរបាលខេត្ត កងរាជអាវុធហត្ថ មន្ទីរអង្គភាពជុំវិញជាសមាជិក និងអង្គការដៃគូជាតិ អន្តជាតិ ផងដែរ ដែលមានចំនួនចូលរួមសរុប ៥៤នាក់ ស្រី៣៥នាក់ នៅបន្ទប់ប្រជុំសាលាខេត្តសៀមរាប។ អង្គប្រជុំបានធ្វើការពិភាក្សាលើបញ្ហាមួយចំនួន ដែលបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំខែសីហាកន្លងទៅ និងបានដាក់ចេញនូវផែនអនុវត្តបន្តរួមមាន៖

១,ចុះពិនិត្យទៅលើបញ្ហាគ្រួសារដែលឪពុកម្តាយយកកូនដើរសុំទាន (ដើម្បីធ្វើការណែនាំ និងហាមមិនឲ្យនាំយកកុមារទៅសុំទាន)។

២,ចុះពិនិត្យទៅបញ្ហាដែលមានជនបរទេសប្រកបរបរអាជីវកម្មដើររាប់លុយនៅមូលដ្ឋាន (ប្រើយន្តរបស់គណៈបញ្ជាការឯកភាពក្រុង ស្រុក)។

៣,ពិនិត្យទៅបញ្ហានៃការទទួល និងបញ្ជូនដីការពីសាលាដំបូងខេត្ត ទៅអង្គភាពជំនាញអនុវត្តដីការ។

៤,ពិនិត្យលើការងាររៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០២១ សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥,ជំរុញឲ្យគ្រប់ស្ថាប័នទាំងអស់ បន្តធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គ្រប់អ្នកពាក់ព័ន្ធ, ការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ការផ្តល់សេវានិងកិច្ចការពារកុមារ ឲ្យបានទូលំទូលាយ។

### ត្រឹម២លើក! ថៃចាប់ពលករខ្មែរ១៣នាក់ ក្រោយឆ្លងព្រំដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២០ ម៉ោង ១៧:៣២ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន១៣នាក់ ត្រូវបានសមត្ថកិច្ចថៃក្នុង ស្រុកតាប្រាយ៉ា ខេត្តស្រះកែវចាប់ខ្លួន ក្រោយឆ្លងព្រំដែនតាមរយៈមេខ្យល់ខ្មែរ និងថៃកាលពីវេលាទៀបភ្លឺថ្ងៃទី២៦ កញ្ញា ឆ្នាំ២០២០ នៅក្នុងឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ឈមទឹកដីកម្ពុជា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ពលករទាំង១៣នាក់ខាងលើគេមិនទាន់ស្គាល់អត្តសញ្ញាណនៅឡើយទេ (ប្រុស៥នាក់ ស្រី៨នាក់) ហើយត្រូវសមត្ថកិច្ចចាប់ ២ទីតាំងផ្សេងគ្នា ក្នុង

ឃុំស្រុកកើតហេតុខាងលើ។ ពលករចំនួន៥នាក់ (ស្រី៣នាក់) ត្រូវសមត្ថកិច្ចថៃចាប់ពេលកំពុងរង់ចាំរថយន្ត និង៨នាក់ទៀត (ស្រី៥នាក់) ត្រូវគេចាប់ពេលកំពុងជិះរថយន្តចេញពីចំណុចស្ថានីយប្រេងឥន្ធនៈមួយ ក្នុងឃុំស្រុកដដែលនេះ។

យោងតាមការសាកសួរ ពលករទាំងនេះប្រាប់ថា ខ្លះគ្រោងទៅរកការងារធ្វើនៅក្រុងបាងកក, ឆាក់ធឹនសៅ, នគររាជសីមា, នុនថាក់បុរី, ណាខនណាយុក និងខេត្តមីនបុរី ដោយចំណាយប្រាក់សម្រាប់ថ្លៃរថយន្ត និងមេខ្យល់ម្នាក់ៗជាង៣០០០បាត និងខ្លះ៣០០០បាត ។ ពលករទាំង១៣នាក់ និងអ្នកបើកបររថយន្តជាជនជាតិថៃម្នាក់ក្រោយឃាត់ខ្លួនបានប្រគល់ទៅតម្រួតស្រុកតាប្រាយ៉ា ដើម្បីចាត់ការបន្ត។ ពិតជារឿងដដែលៗដែលខាងថៃចាប់បានបន្តបន្ទាប់ខណៈខាងកម្ពុជាគ្មានអ្នកចេញមុខទទួលខុសត្រូវរហូត៕ (កែសម្រួលដោយ ៖ ធីតា)

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៤៣នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 28-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៣នាក់ ស្រី ១២នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣៣នាក់ បានធ្វើដំណើរចូលប្រទេស តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 28-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៣នាក់ ស្រី ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័កត្រួតពិនិត្យសុខភាពវាស់កំដៅរួចបានអនុញ្ញាតឲ្យពួកគាត់ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៣នាក់

https://www.facebook.com/GDIOfficial 28-09-2020

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៣នាក់ ស្រី ២៧នាក់៕

## ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែន អំពាវនាវដល់ប្រជាពលរដ្ឋកុំឲ្យលួចឆ្លងដែនខុសច្បាប់ទៅប្រទេសគេបន្តទៀត

http://cambodiapolice.com/policekh/ 2:29 pm 28 កញ្ញា 2020

**ភ្នំពេញ ៖** ឯកឧត្តម ឧត្តមសេនីយ៍ឯក លៀង ភារម្យ ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែន បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ គប្បីកុំលួចឆ្លងដែនខុសច្បាប់ទៅប្រទេសជិតខាងបន្តទៀត ខណៈការលួចឆ្លងដោយប្រថុយប្រថាននេះវានឹងប្រឈមគ្រោះថ្នាក់ជាច្រើនដោយយថាហេតុណាមួយនោះ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មានបន្ទាប់ពីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងលើកទិសដៅការងារអនុវត្តសម្រាប់ខែតុលា ឆ្នាំ២០២០នេះ នៅនាយកដ្ឋាននគរបាលការពារព្រំដែន ដែលស្ថិតនៅសង្កាត់ព្រែកឯក ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០នេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក លៀង ភារម្យ បានលើកឡើងថា នគរបាលការពារព្រំដែនគ្រប់ច្រកទាំងអស់តែងតែធ្វើការឃាត់ខ្លួន និងអប់រំជាច្រើនលើកច្រើនសារមកហើយ ដល់បងប្អូនប្រជាពលរដ្ឋខ្មែរយើង ដែលបានលួចឆ្លងដែនខុសច្បាប់ ដើម្បីទៅរកការងារធ្វើនៅប្រទេសជិតខាង។ ប៉ុន្តែពួកគាត់មួយចំនួនទៀតនៅតែបន្តលួចឆ្លងដែន ដោយខុសច្បាប់ដដែលតាមរយៈមេខ្យល់ដោយមិនខ្លាចគ្រោះថ្នាក់ ខ្លាចឆ្លងនូវជំងឺផ្សេងៗ និងមិនខ្លាចអាជ្ញាធរថៃចាប់ខ្លួនជាដើមនោះ។

ទាក់ទងនឹងបញ្ហាតាមបណ្តោយព្រំដែនកម្ពុជា និងប្រទេសជិតខាងនេះដែរ ឯកឧត្តម ឧត្តមសេនីយ៍ឯក លៀង ភារម្យ ក៏បានលើកឡើងផងដែរថា នាពេលបច្ចុប្បន្ននេះតាមបណ្តោយព្រំដែនរបស់កម្ពុជាមានសភាពស្ងប់ស្ងាត់ល្អពុំមានករណីអ្វីធំដុំនោះទេ ក្រៅពីបញ្ហាមួយចំនួនលើតំបន់មិនទាន់បានឯកភាពគ្នា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ករណីនេះត្រូវបានថ្នាក់លើកំពុងដោះស្រាយគ្នាដោយសន្តិវិធី និងមិនមានការផ្ទុះអាវុធដាក់គ្នានោះឡើយ។

សូមបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំប្រចាំខែនោះ ឯកឧត្តម ឧត្តមសេនីយ៍ លៀង ភារម្យ ក៏បានក្រើនរំលឹកឲ្យកងកម្លាំងទាំងអស់ត្រូវពង្រឹងសមត្ថភាព ជំនាញវិជ្ជាជីវៈ គោរពវិន័យរបស់កងកម្លាំង ជាពិសេសគោរពបទបញ្ជារបស់ថ្នាក់ដឹកនាំ និងបានអំពាវនាវដល់បងប្អូននគរបាលការពារព្រំដែនទាំងអស់ បន្តយកចិត្តទុកដាក់អនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួនបន្ថែមទៀតផងដែរ នូវវិធានការការពារមេរោគកូវីដ១៩ ជំងឺគ្រុនឈឹក និងមេរោគផ្សេងៗទៀត ស្របទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ហើយមួយវិញទៀតក៏ត្រូវប្រុងប្រៀបជាប់និច្ចក្នុងកិច្ចការពារបូរណភាពទឹកដី និងសន្តិសុខសណ្តាប់ធ្នាប់ នៅតាមខ្សែបណ្តោយព្រំដែនជាមួយប្រទេសជិតខាងឲ្យបានល្អប្រកបដោយសន្តិវិធីផងដែរ៕

# ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អំពាវនាវឱ្យពលករដែលវិលត្រឡប់មកពីប្រទេសថៃចូលរួមប្រយុទ្ធនឹងជំងឺកូវីដ១៩ ផ្ដើមចេញពីការធ្វើអនាម័យខ្លួនជាប្រចាំ

https://gdlf-kh.com/ 2020/09/29/ Kao sophy ខេត្តស្វាយរៀង

ខេត្តស្វាយរៀង៖ នារសៀលថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០នេះ លោកជំទាវ ឯក សុវណ្ណការៈ អភិបាលរងខេត្តស្វាយរៀង តំណាងឯកឧត្តម ម៉ែន វិបុល អភិបាលខេត្តស្វាយរៀង បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយពលករដែលវិលត្រឡប់មកពីប្រទេសថៃ ចំនួន ១១៥នាក់ ស្ថិតក្នុងឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ពិធីដែរក៏មានការចូលរួមពីកងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ ព្រមទាំងអាជ្ញាធរដែនដីជាច្រើនរូបទៀត ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានបន្តថា៖ ថ្ងៃនេះក្រុមការងារបានចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋចំណាកស្រុកមកពីប្រទេសថៃ ដើម្បីឈ្វេងយល់ និងការរស់នៅរបស់ពលករអំឡុងពេលកូវីដ១៩ ហើយក៏ចង់ដឹងអំពីស្ថានភាពរបស់ស្រុករមាសហែក ក្នុងការទប់ស្កាត់ និងឆ្លើយតបបញ្ហាប្រឈមរបស់ជំងឺកូវីដ១៩ ចំពោះប្រជាពលរដ្ឋដែលចំណាកស្រុកមកពីប្រទេសថៃផងដែរ។ លោកជំទាវបានបន្តថា អាជ្ញាធរមូលដ្ឋាន និងមន្ត្រីដែលពាក់ពន្ធ័ទាំងអស់ ត្រូវបន្តចូលរួមផ្សព្វផ្សាយអំពីវិធានការការពារ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ របស់រាជរដ្ឋាភិបាល គណៈកម្មការប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ១៩ថ្នាក់ជាតិ និងគណៈកម្មការប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ១៩ថ្នាក់ខេត្ត ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ពិសេសការដាក់ឲ្យនៅដាច់ដោយឡែក ១៤ថ្ងៃដោយស្ម័គ្រចិត្ត សម្រាប់អ្នកដែលទើបត្រឡប់ពីធ្វើការក្រៅខេត្ត និងក្រៅប្រទេស ដើម្បីសុវត្ថិភាពក្រុមគ្រួសារ និងសង្គមជាតិទាំងអស់គ្នា។

លោកជំទាវក៏បានអំពាវនាវ និងសំណូមពរ ដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមឲ្យមានការយោគយល់លើចំណាត់ការក្នុងគ្រាដ៏លំបាកនេះ និងសូមចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីសេចក្តីសុខនិងសុវត្ថិភាពសុខភាពផ្ទាល់ខ្លួនផង និងដើម្បីសុវត្ថិភាពសុខភាពសម្រាប់អ្នកដទៃ និងសហគមន៍ទាំងមូលផង នៅក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះ។ លោកជំទាវ ជូ ប៊ុនអេង និងក្រុមការងារ បាននាំយកអំណោយចែកជូនដល់ពលករចំនួន១១៥នាក់ ក្នុងម្នាក់ៗ ទទួលបានគ្រឿងឧបភោគបរិភោគមួយចំនួន និងឃីត ១ កញ្ចប់ផងដែរ ៕

## អបអរសាទរកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តការងារ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com/ 2020/09/29/ Kao sophy ខេត្តស្វាយរៀង

ខេត្តស្វាយរៀង៖ នាព្រឹកថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០នេះ នៅសាលប្រជុំ អគារ ខ សាលាខេត្ត គណៈកម្មាធិការ គ.ខ.ប.ជខេត្តស្វាយរៀង បានរួមសហការជាមួយអង្គការឆាលហ្វាន់ ក្រោមកិច្ចសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព នៃការអនុវត្តការងារ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

អញ្ជើញចូលរួមដោយគណៈអធិបតី និងអ្នកចូលរួមមានលោកជំទាវ ឧ.ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គខបជ ខេត្តស្វាយរៀង លោក ប្រាសាន់វើម៉ា នាយកប្រចាំប្រទេសអង្គការឆាលហ្វាន់កម្ពុជា និងលោកនាយកអង្គការឆាលហ្វាន់ប្រចាំខេត្តស្វាយរៀង តំណាងពីស្ថាប័នតុលាការខេត្ត តំណាងកងកម្លាំងទាំងបី ប្រធានក្រុមជំនួយកិច្ចការ បង្ការទប់ស្កាត់ និងការពារជនរងគ្រោះ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ តំណាងពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ប្រធាន អនុប្រធានមន្ទីជុំវិញខេត្ត អាជ្ញាធរដែនដី កងរាជអាវុធហត្ថអភិបាលក្រុង ស្រុក សង្កាត់ និងអង្គការដៃគូអភិវឌ្ឍ មួយចំនួន សរុបវត្តមានសរុប ៩០នាក់ ។

គោលបំណងនៃកិច្ចប្រជុំនេះ ដើម្បីចែករំលែករបាយការណ៍ និងលទ្ធផលនៃកិច្ចសហការលើគម្រោងសហគមន៍កុមារមេត្រីនៅខេត្តស្វាយរៀង រយៈពេល២៤ខែ ព្រមទាំងលទ្ធផលនៃសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ និងពិភាក្សាលើទិសដៅអនុវត្តបន្តសម្រាប់អនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២០។ កិច្ចប្រជុំនេះ ក៏បានចែករំលែកអំពីកិច្ចសហការក្នុងការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគម្រោងសហគមន៍កុមារមេត្រីប្រឆាំងការជួញដូរកុមារ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព៕

## ការលួចឆ្លងដែនដោយខុសច្បាប់ បានបន្ថែមទម្ងន់លើវិបត្តិកូវីដ១៩

http://btv.com.kh/ 29/09/2020

សៀមរាប ៖ លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានបង្ហាញកង្វល់ថា វាជាទម្ងន់បន្ថែមលើដំណោះស្រាយ ខណៈពេលដែលពលរដ្ឋខ្មែរមួយចំនួន នៅតែលួចឆ្លងដែននៅក្នុងអន្តរកាល នៃវិបត្តិកូវីត១៩នេះ។ នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប កាលពីថ្ងៃទី២៨ ខែកញ្ញា ម្សិលមិញ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានបញ្ជាក់ថា មកដល់ពេលនេះ ក្រុមការងារជំនាញបានរកឃើញថា ប្រជាពលរដ្ឋខេត្តសៀមរាប ដែលបានធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ចំនួនជាង៥ម៉ឺននាក់ ក្នុងនេះការធ្វើចំណាកស្រុកដោយស្របច្បាប់ មានចំនួនតែជាង ២ម៉ឺននាក់ ហើយការធ្វើចំណូលស្រុកមកវិញ មានចំនួនជាងបីម៉ឺននាក់។ ក្រុមអ្នកចំណូលស្រុកទាំងនេះ មានមួយចំនួន បានព្យាយាមឆ្លងដែនត្រឡប់ទៅវិញ ដោយផ្សងនឹងគ្រោះថ្នាក់ជាច្រើន ដោយសារតែការចាញ់ឧបាយកលមេខ្យល់ ដែលទាំងនោះ គឺជាក្តីកង្វល់មួយ។ លោកស្រី បានបន្ថែមថា មូលហេតុមួយចំនួន នៃការលួចឆ្លងដែនជាថ្មី របស់ពលរដ្ឋខ្មែរទាំងនោះ ក្រៅពីការអូសទាញ ក៏មានមួយចំនួនដែរ ជាពលករស្របច្បាប់ បានធ្វើចំណូលស្រុកមកវិញដោយខុសច្បាប់ នៅពេលដែលព្រំដែនត្រូវបានបិទ។ ការឆ្លងដែនក្នុងពេលដែលច្រកព្រំដែនត្រូវបានបិទ វាជាករណី ខុសច្បាប់រួចទៅហើយ ប៉ុន្តែវាក៏កំពុងបិតក្នុងវិបត្តិកូវីដ១៩ថែមទៀត ដែលទាំងអស់នេះបានក្លាយជាបន្ទុក ដ៏ធ្ងន់ធ្ងរសម្រាប់ការរកដំណោះស្រាយ។

លោកស្រី យូ សុភាព បានបញ្ជាក់ថា យ៉ាងណាក៏ដោយ ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានសហការជាមួយរដ្ឋបាលខេត្ត រៀបចំកម្លាំងទទួលពលរដ្ឋ ខ្មែរ ដែលបានធ្វើចំណូលស្រុកវិញ ប្រចាំការនៅតាមបណ្តាច្រកទ្វារព្រំដែន ដូចជា ប៉ោយប៉ែត ម៉ាឡៃ និង អូរបីជាន់ ជាដើម ជាមួយនឹងការអនុវត្តតាមវិធានសុវត្ថិភាព ដែលដាក់ចេញដោយក្រសួងសុខាភិបាល ធ្វើ ចត្តាឡីស័ក ឧបត្ថម្ភអាហារ ដឹកជញ្ជូនទៅកាន់មូលដ្ឋាន តាមដានសុខភាព បង្ការទប់ស្កាត់រលកទី២ ចូល ក្នុងសហគមន៍៕ អត្ថបទ៖ ងឹន គឹមឡេង

## ឃាត់ខ្លួនមនុស្សស្រី៨នាក់ដែលសង្ស័យបង្កប់ឲ្យមានការជួញដូរផ្លូវភេទជាមួយភ្ញៀវក្នុងបារបាំងឃីហោ ហាន់នី ហាន់នីបារ

http://nokorwatnews.com/ 29-09-2020

ភ្នំពេញ៖ កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ សហការជាមួយសមត្ថកិច្ចមូលដ្ឋាន បានឃាត់ខ្លួនមនុស្សស្រី៨នាក់ ដែលសង្ស័យថា បានបង្កប់ឲ្យមានការជួញដូរផ្លូវភេទជាមួយភ្ញៀវក្នុងបារបាំងមួយកន្លែង។

ការចុះបង្ក្រាបនេះបានធ្វើឡើងកាលពីវេលាម៉ោង៨៖៤០នាទីយប់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងហាងមួយកន្លែងឃីហោ "ហាន់នីហាន់នី បារ ( Honey Honey Bar )ជិតផ្សារសូរិយ៉ាម៉ល ស្ថិតនៅតាមបណ្តោយផ្លូវលេខ៥១ កែងផ្លូវលេខ ១៧២ ក្នុងសង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ តាមប្រភពព័ត៌មានពីនគរបាលបានឱ្យដឹងទៀតថា នៅមុនពេលឈានដល់ការចុះបង្ក្រាបនៅទីតាំងនេះ កម្លាំងនគរបាលជំនាញ បានធ្វើការស្រាវជ្រាវឃើញថាទីតាំងខាងលើនេះបើកភោជនីយដ្ឋានបារ មានបង្កប់បម្រើសេវាផ្លូវភេទ លុះដល់វេលាម៉ោងកើតហេតុទើបកម្លាំងជំនាញចុះប្រតិបត្តិការធ្មក់ចូលទីតាំងនេះធ្វើការហ៊ុមព័ទ្ធដើម្បីត្រួតពិនិត្យតែម្តង ។ តាមប្រភពព័ត៌មានពីជនរងគ្រោះបានឱ្យដឹងថា ជារៀងរាល់ថ្ងៃទីតាំងហាងនេះបានបើករកស៊ីចាប់ពីម៉ោង៦ល្ងាចរហូតដល់ម៉ោង៦ព្រឹក ដោយភ្ញៀវខ្លះចូលផឹកស៊ី និងភ្ញៀវខ្លះចូលមករកសេវាផ្លូវភេទតែម្តង។

សូមបញ្ជាក់ផងដែរថា ក្រោយចប់ប្រតិបត្តិការ ទីតាំងខាងលើនេះត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីរង់ចាំគោលការណ៍ជាថ្មី។ ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះ កម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សស្រី៨នាក់ ក្នុងនោះ(អនីតិជន៣នាក់) និងដកហូតវត្ថុតាងរួមមានស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើប្រាស់មួយចំនួនផងដែរ បាននាំយកមកការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីបន្តការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់៕ **ដោយ៖ វ៉ាវ៉ា**

## មន្ត្រីនគរបាលការពារព្រំដែនគោកទាំង៤ ត្រូវបង្កើនការយកចិត្តទុកដាក់ការពារទប់ស្កាត់បទល្មើសព្រំដែន

http://nokorwatnews.com/ 29-09-2020

ខេត្តបន្ទាយមានជ័យ៖ ថ្លែងក្នុងពិធីប្រកាសផ្ទេរភារកិច្ចតែងតាំងមុខតំណែង និងដំឡើងឋានន្តរស័ក្តិដល់មន្ត្រីនគរបាលជាតិ វរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យនៅបញ្ជាការដ្ឋានវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១ នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ សិទ្ធ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានជំរុញឲ្យមន្ត្រីនគរបាលការពារព្រំដែនគោកទាំង៤ ត្រូវបង្កើនការយកចិត្តទុកដាក់ការពារ ទប់ស្កាត់បទល្មើសព្រំដែន ទំនិញគេចពន្ធ អំពើភេរវកម្ម ពលករឆ្លងដែនខុសច្បាប់។ លោកបន្ថែមថា មន្ត្រីនគរបាលការពារព្រំដែនគោក ក្រៅពីកិច្ចការងារទប់ស្កាត់បទល្មើសព្រំដែនហើយ ត្រូវសហការជាមួយមន្ត្រីនគរបាលអធិការដ្ឋានគ្រប់ស្រុក/ក្រុង ដើម្បីការពារ រក្សាសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ ក្នុងមូលដ្ឋានដែលខ្លួនបានគ្រប់គ្រង។ មន្ត្រីនគរបាលត្រូវចេះគោរពវិន័យកងទ័ព គោរពបទបញ្ជាថ្នាក់លើដែលបានប្រគល់ភារកិច្ចជូន ត្រូវទទួលខុសត្រូវចំពោះការងាររបស់ខ្លួនដែលថ្នាក់លើដាក់ឲ្យ មានសាមគ្គីភាពផ្ទៃក្នុង សហការជាមួយអាជ្ញាធរ និងកងកម្លាំងផ្សេងៗដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលាក្នុងករណីប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ ទឹកជំនន់ អគ្គិភ័យ និងហាមដាច់ខាតការកេងប្រវ័ញ្ចទ្រព្យសម្បត្តិរបស់រដ្ឋ៕ **វណ្ណា**

# ប្រថុយទៅធ្វើការស្រុកថៃ ដឹងអីអស់លុយ ខាតពេល ប្រឈមជាប់គុកទៀត

http://kampucheathmey.com/ 30/9/2020 7:42 Am

ខេត្តបន្ទាយមានជ័យ៖ ខ្មែរម្នាក់លួចដឹកពលករខ្មែរ៤នាក់ ទៅធ្វើការងារខុសច្បាប់នៅស្រុកថៃ ត្រូវអាជ្ញាធរថៃចាប់ឃាត់ខ្លួនជិះតាមរថយន្តនៅព្រឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២០។ បើតាមការអះអាងរបស់សមត្ថកិច្ចថៃបានឲ្យសមត្ថកិច្ចខ្មែរដឹងថា កម្លាំងទាហានការពារព្រំដែនថៃប្រចាំស្រុកអារញ្ញយ៉ាប្រាថេត ខេត្តស្រះកែវ បានធ្វើការឃាត់រថយន្តម៉ាកនីសាន់ មួយគ្រឿង ពាក់ស្លាកលេខ២៤៤៧ ឈុនបុរី បើកដោយបុរសជនជាតិខ្មែរ ឈ្មោះ យ៉ឹង បូរី ភេទប្រុស អាយុ ៣៩ឆ្នាំ ស្រុកកំណើតរស់នៅភូមិតាផូ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ក្រោយពីសមត្ថកិច្ចថៃបានធ្វើការឆែកឆេរក្នុងរថយន្ត រកឃើញពលរដ្ឋខ្មែរចំនួន៤នាក់បន្តទៀត មិនមានមិនមានប្រវត្តិចេញចូលប្រទេសថៃ និងឯកសារពាក់ព័ន្ធហើយអាជ្ញាធរថៃបានបញ្ជូនខ្លួនជនជាតិខ្មែរទាំង៥នាក់នេះកាន់អធិការដ្ឋានតម្រួតប៉ុស្តិ៍អារញ្ញយ៉ាប្រាថេតដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

បើតាមការអះអាងរបស់ពលករខ្មែរទាំង៤នាក់បានឲ្យដឹងថា ដោយសារក្នុងសម័យកូវីដ១៩នេះ ពួកគេគ្មានការងារធ្វើ ហើយក្នុងគ្រួសារជួបប្រទះការខ្វះខាត ទើបបបួលគ្នាបង្ខំចិត្តលួចឆ្លងដែនខុសច្បាប់ ប្រុងទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ឆ្លងដែនខុសច្បាប់។ បើមិនជោគជ័យតាមបំណង ប្រឈមនឹងគេចាប់បញ្ជូនត្រឡប់មកវិញក៏ដោយ ក៏នៅតែប្រថុយ ក្រែងបានសុខដឹងអីខកបំណងជដែល អស់ទាំងប្រាក់ ខាតទាំងពេលវេលាត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកបន្តថែមទៀត៕ អត្ថបទ៖ វ៉ាន់ ណាង

## អាជ្ញាធរថៃចាប់ពលករខ្មែរ ៥នាក់លួចឆ្លងដែនខុសច្បាប់នៅតំបន់ព្រំដែនកម្ពុជា

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា 2020-09-29

អាជ្ញាធរថៃចាប់ពលករខ្មែរចំនួន៥នាក់ លួចឆ្លងដែនចូលទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់នៅព្រឹកថ្ងៃទី២៩ កញ្ញា។ សារព័ត៌មាន ៧៧ខាវដិត (77Kaoded) របស់ថៃ ចុះផ្សាយនៅថ្ងៃទី២៩ កញ្ញាថា ពលករខ្មែរទាំង៥នាក់ រួមមានប្រុស ៤នាក់ និងស្រីម្នាក់ ដោយមានអាយុចន្លោះពី ២២ ដល់ ៣៧ឆ្នាំ និងមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ។ ពួកគេត្រូវបានទាហានឈុតខ្មៅរបស់ថៃ ចាប់ខ្លួនក្នុងពេលធ្វើដំណើរនៅតំបន់ព្រំដែនក្នុងស្រុកតាផាយ៉ា (Taphya) ខេត្តស្រះកែវ (Srakao) ក្បែរច្រករបៀងព្រំដែនបឹងត្រកួន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរទាំងនោះទៅឃុំខ្លួននៅប៉ុស្តិ៍ប៉ូលិសស្រុកអារញ្ញ ដើម្បីចាត់វិធានការតាមច្បាប់។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ សុផល មានប្រសាសន៍ថា មួយរយៈនេះអាជ្ញាធរថៃបានដាក់កម្លាំងការពារយ៉ាងតឹងតែងនៅតំបន់ព្រំដែនកម្ពុជា និងថៃ ដើម្បីទប់ស្កាត់ពលករខ្មែរលួចឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ ដោយសារព្រួយបារម្ភខ្លាចឆ្លង ជំងឺកូវីដ១៩។ លោកប្រាប់ថា ពលករខ្មែរភាគច្រើនដែលអាជ្ញាធរថៃចាប់ខ្លួនអំឡុងពេលការរាតត្បាតជំងឺកូវីដ១៩ ភាគច្រើន ពួកគេត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ។ លោកឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរប្រមាណពី ៥០ ទៅជាង ១០០នាក់ក្នុងមួយថ្ងៃត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារបព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 29-09-2020

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារបព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកមុំបី ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 29-09-2020

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៥៩នាក់៕